ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2012, 15:04
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៧៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr. Matteo CRIPPA)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក វ៉េន ពៅ

លោក សំ សុគង់

លោក គឹម ម៉េងឃី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ជេត វណ្ណលី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អេនគ្រូ អ៊ីអ៊ុនហ្វ៊ី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក យុន គីម ហៅ ខាំ (TCW-797) | ខ្មែរ |
| លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក យុន គីម ហៅ ខាំ** (TCW-797)
សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖..........................................................................ទំព័រ ៥
សួរដោយលោក សេង ប៊ុនឃាង ផ្ដើមពី៖ ...................................................................ទំព័រ ៩
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី៖....................................................................ទំព័រ១៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងសប្តាហ៍នេះ ចាប់ពីថ្ងៃនេះរហូតដល់អាចលទ្ធភាពព្រឹកថ្ងៃសុក្រ ទី២២ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្ម ដែលមានរហស្សនាម TCW-797 ហើយនិង TCW-321។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមានអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួម នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ពេលនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោកមេធាវីអន្តរជាតិការពារឲ្យលោក អៀង សារី គឺលោកមេធាវី កាណាវាស អវត្តមានដោយមិនមានមូលហេតុ និងជនជាប់ចោទ អៀង សារី មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការពីបន្ទប់រង់ចាំខាងក្រោម។

លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯសាក្សីដែលអង្គជំនុំជម្រះបានកោះហៅ មកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ គឺសាក្សី ដែលមានរហស្សនាម TCW-797 និងសាក្សីបម្រុង ដែលមានរហស្សនាម TCW-321។ សាក្សីទាំងពីររូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីទាំងពីរបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយមុននឹងចូលមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ។ ហើយសាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

[០៩:០៣:៣៩]

កត់សម្គាល់ផងដែរ អំពីវត្តមានលោកមេធាវី លឹម ប៊ុនហេង ដែលជាមេធាវីប្រឹក្សាដែលអង្គជំនុំ

ជម្រះ និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញផ្តល់ជូនដល់សាក្សី តាមសំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងបន្ទប់សវនាការ ដោយផ្ទាល់ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

អនុសាសន៍របស់វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យ ថែទាំសុខភាពព្យាបាលជនជាប់ចោទ នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានផ្តល់យោបល់នៅក្នុងកិច្ចដំណើរការសវនាការ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ នេះ ថាជនជាប់ចោទគួរតែត្រូវបានផ្តល់ការអនុញ្ញាតឲ្យនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយហេតុលោក អៀង សារី មានអាការៈវិលមុខ ហេវហត់ ពិសេសនៅពេលឡើងកាំជណ្តើរ និងពុំអាចផ្តល់លទ្ធភាពអង្គុយយូរបាន។

[០៩:០៥:២០]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះ លោក អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:០១]

បង្គាប់ឲ្យផ្នែកបុគ្គលិក ផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់ពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

សូមអញ្ជើញលោកមេធាវី តើលោកមានបំណងនិយាយអំពីបញ្ហាអី? លោកចងចាំឲ្យច្បាស់ថា លោកចង់និយាយអី លោកសង្ខេបអំពីប្រធានបទដែលលោកមានបំណងនិយាយជាមុនសិន ដើម្បីឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកនិយាយ ឬមិនអនុញ្ញាត។

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំចង់ជម្រាបជូនថា ថ្ងៃនេះគឺថាទាក់ទងនឹងសាក្សី។ ថ្ងៃនេះគឺថាល្ងាចពីម្សិលមិញហ្នឹងគឺថា យើងមើលសំណើតាមវិធាន៨៧ គឺថាទាក់ទងទៅនឹងគោលបំណងនៃការសួរផ្ទាល់សាក្សី។ សំណើរបស់យើងត្រូវបានដាក់ចូលជាអង់គ្លេស និងខ្មែរជូនហើយ គឺថាយើងបានដាក់ស្នើ ហើយយើងបានមានឯកសារតែមួយទំព័រកន្លះទេ ហើយៗចំណុចសំខាន់នៅព្រឹកនេះ ប៉ុន្តែខ្ញុំសូមស្នើតុលាការថា សូមជម្រាបជូនពីលក្ខណៈនៃសំណើនេះ គឺថាយើងសូមឲ្យមានសេចក្ដីសម្រេចរហ័សលើករណីនេះ ហើយប្រហែលថ្ងៃនេះ ហើយយើងអាចនឹងស្ដាប់មតិភាគីផ្សេងៗទៀតផងដែរ។

[០៩:០៧:៣០]

ហើយក៏ចង់សូមឲ្យមានសេចក្ដីសម្រេចផ្ទាល់មាត់ថ្ងៃនេះ ដើម្បីបន្តការសួរសាក្សីនៅថ្ងៃស្អែក។ ខ្ញុំយល់ហើយគឺថា អង្គជំនុំជម្រះមិនអាចដោះស្រាយទាំងអស់ទេ ប៉ុន្តែនេះសំណើមួយខ្លីទេ យើងចង់បានសេចក្ដីសម្រេចមុនពេលដែលនឹងសួរដេញដោលសាក្សី ជាពិសេសក្នុងករណីសាក្សី TCW-797។ បាទ សូមអរគុណ។

[០៩:០៨:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១១:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះកត់សម្គាល់លើសំណើសុំរបស់មេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ដែលបានលើកឡើងអំពីសំណើរបស់ខ្លួន អម្បាញ់មិញនេះ ហើយអង្គជំនុំជម្រះមិនទាន់បានទទួលជាក់លាក់នូវឯកសារដែលដាក់ដោយ-- សំណើរសុំដែលដាក់ដោយក្រុមមេធាវីការពារ នួន ជា នៅឡើយទេ។ ហើយពេលណាយើងពិនិត្យទទួលបានឯកសារនោះ យើងនឹងពិនិត្យពិចារណាដោះស្រាយ។ ប៉ុន្តែអង្គជំនុំជម្រះក៏សូមកត់សម្គាល់ផងដែរ ថាការដាក់ឯកសារ-- អ៎! ការដាក់សំណើរបស់ក្រុមមេធាវីការពារក្ដី នួន ជា ហាក់ដូចជាមានការយឺតយ៉ាវ បើធៀបនឹងពេលវេលានិងសេចក្ដីណែនាំអនុវត្ត ដែលអង្គជំនុំជម្រះបាន

ចេញសេចក្តីណែនាំរួចហើយ។

[០៩:១២:០៩]

មន្ត្រីរដ្ឋបាលតុលាការ កោះអញ្ជើញសាក្សី TCW-797 ចូលមកកាន់បន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យអ្នកឯងនិយាយទេ។ យើងបានកត់សម្គាល់នូវសំណើរួចហើយ។ កត់សម្គាល់ទាំងពីរ អ្នកឯងបានដាក់ហើយ យើងបាននឹងពិនិត្យបញ្ហានេះ។ ទីពីរ យើងកត់សម្គាល់ថា ការដាក់សំណើសុំ បែបនេះ វាយឺតពេល។ ពីព្រោះបានណែនាំច្រើនហើយ អំពីការស្នើសុំដាក់ឯកសារថ្មីមកពិភាក្សាដេញដោលចំពោះមុខអង្គជំនុំជម្រះ។ នេះជាការកត់សម្គាល់របស់អង្គជំនុំជម្រះ ចំពោះសំណើរបស់លោក។

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១៣:៣២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម សហសេវិក-- សហភាតា និងសាធារណជនទាំងអស់។ សម្រាប់សាក្សីរូបនេះ មេធាវីនាំមុខផ្ទេរសិទ្ធិជូនលោក វ៉ែន ពៅ ហើយនៅក្នុងនោះមានលោកស្រី អេលីហ្សាបេត នឹងធ្វើអន្តរាគមន៍ដោយផ្ទាល់។ ហើយសុំអនុញ្ញាតលោកប្រធាន ចំពោះករណីនេះ ហើយមានចំណុចមួយទៀត ដែលមានការកត់សម្គាល់ គឺថាអម្បាញ់មិញ លោក អ៊ីនូហ្វ៊ី បានលើក-- អ៎! បានងើបឈរ ហើយយើងខ្ញុំសង្កេតឃើញថា មានស្លាកកមួយ ដែលមានលក្ខណៈចម្លែកសម្រាប់យើងខ្ញុំជាមេធាវី ហើយអាចជាស្លាកកពាណិជ្ជកម្ម ដែលសរសេរថា “អាយ” ហើយសញ្ញា “បេះដូងពណ៌ក្រហម” ហើយនិង “ដា១” ដែលអាចជាឡូហ្គូលពាណិជ្ជកម្មមួយ ដែលមេធាវីជាធម្មតាមិនមានសិទ្ធិពាក់ទេ។ តើករណីនេះ តើយ៉ាងម៉េចទៅវិញ លោកប្រធាន?

សូមអរគុណ។

[០៩:១៤:៤១]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

នេះគឺជាឡូហ្គូលបញ្ជាក់ពីទស្សនៈទេ មិនមែនជាផ្សាយពាណិជ្ជកម្មទេ លោកប្រធាន បាទ។

[០៩:១៥:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ងើបឈរ!

លោកដកស្លាកសញ្ញាចេញ! ស្លាកសញ្ញានេះនៅក្នុងកិច្ចដំណើរការសវនាការជារូបនៃមន្ត្រីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការនីតិវិធី ក្រៅពីសញ្ញាដែលមាននៅក្នុងការកំណត់នៅក្នុងរូបនេះ គឺមិនឱ្យប្រើប្រាស់ទេ។ សូមលោកដកនូវស្លាកសញ្ញាដែលខុសប្លែកប្រក្រតីនេះចេញ!

**លោក អេនទ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំមិនអាចដកដោយស្ម័គ្រចិត្តទេ បើសិនជាតុលាការបង្គាប់ឱ្យខ្ញុំដក ខ្ញុំនឹងដកចេញបាទ។

**ប្រធានអង្គជំនុំ៖**

យើងបង្គាប់ឱ្យលោកដកចេញឥឡូវនេះ!

[០៩:១៦:១៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីសាក្សី! តើលោកឈ្មោះអ្វីដែរលោក?

**លោក យុន គីម៖**

**ឆ៖** ខ្ញុំបាទឈ្មោះ យុន គីម។

**ស៖** ក្រៅពីឈ្មោះ យុន គីម តើលោកមានធ្លាប់ប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** ឈ្មោះហៅក្រៅ ខាំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក យុន គីម។ នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ការផ្តល់សក្ខីកម្មរបស់លោកនៅចំពោះមុខអង្គជំនុំជម្រះ ដោយនៅទីនេះប្រើប្រាស់បីភាសា ត្រូវឆ្លងកាត់ការបកប្រែភាសាទៅជាបារាំង ហើយនិងភាសាអង់គ្លេស និងភាសាខ្មែរ។ អ៊ីចឹងបីភាសា ហើយដើម្បីសម្រួលក្នុងការនិយាយឱ្យបានត្រឹមត្រូវ ហើយនិងជាក់ច្បាស់ ហើយមានការបកប្រែត្រឹមត្រូវនោះ សូមលោករង់ចាំរហូតដល់ពេលក្បាលមីក្រូធ្វើប្រតិបត្តិការ បានន័យថា វាមានភ្លើងសញ្ញាក្រហមនៅចំពោះមុខលោក សូមលោកចាប់ផ្តើមនិយាយ ដើម្បីពេលដែលលោកនិយាយទៅសំឡេងរបស់លោកហ្នឹងស្របចូលទៅក្នុងប្រព័ន្ធការបកប្រែភាសា និងផ្សព្វផ្សាយសំឡេងសម្រាប់ភាគីពាក់ព័ន្ធ ក៏ដូចជាសាធារណជនដែរ។

[០៩:១៧:៤៨]

**សួរដោយប្រធានអង្គជំនុំ៖**

លោក យុន គីម តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ អំពីថ្ងៃខែឆ្នាំកំណើតរបស់លោក?

**លោក យុន គីម៖**

**ឆ៖** ខ្ញុំកើតនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៤២។

**ស៖** បាទ អរគុណ។ តើទីលំនៅសព្វថ្ងៃរបស់លោកហ្នឹង នៅទីកន្លែងណាដែរ?

**ឆ៖** ទីលំនៅបច្ចុប្បន្នរបស់ខ្ញុំបាទនេះ នៅភូមិវត្តន: ឃុំវត្តន: ស្រុកសំបូរ ខេត្តក្រចេះ។

**ស៖** បាទ អរគុណ។ តើលោកប្រកមមុខរបររកស៊ីធ្វើអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** បច្ចុប្បន្នតួនាទីរបស់ខ្ញុំធ្វើជាមេឃុំនៅឃុំវត្តន:។ ហើយមុខរបរប្រចាំថ្ងៃរបស់ខ្ញុំ គឺធ្វើស្រែចម្ការ។

**ស៖** បាទ អរគុណ។ លោក យុន គីម តើឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំបាទនេះឈ្មោះ យុន ហាក់។

[០៩:១៨:៥៨]

**ស៖** ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអីដែរ?

**ឆ៖** ម្ដាយ-- ម្ដាយបង្កើតរបស់ខ្ញុំបាទនេះ ឈ្មោះ ថាម ជ្រី។

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអីដែរ?

**ឆ៖** ប្រពន្ធរបស់ខ្ញុំបាទនេះឈ្មោះ លន់ អេងស៊ាន។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំបាទមានកូនប្រាំមួយនាក់-- អ៎! ប្រាំពីរនាក់។ ប្រុសប្រាំមួយ ស្រីមួយ។

**ស៖** លោក យុន គីម តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានញាតិលោកហិត ឬក៏ញាតិពន្ធជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាជនជាប់ចោទទាំងបីរូបទេ មាន នួន ជា, អៀង សារី, លោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ នេះជាការពិត។

**ស៖** ហើយរបាយការណ៍ក្រឡាបញ្ជីដែលបាននិយាយថា លោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយ មុនពេលចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ នេះជាការពិត។

**ប្រធានអង្គជំនុំ៖**

លោក យុន គីម ក្នុងនាមលោកជាសាក្សីដែលត្រូវមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ អង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចដូចខាងក្រោមនេះ៖

ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរកិច្ចនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធ-ភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សី លោកត្រូវសក្ខីកម្មក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ ដោយលោកត្រូវឆ្លើយតបទៅនឹងរាល់សំណួរដែល-- ទាំងឡាយដែលភាគី ឬអង្គជំនុំសួរចំពោះលោក លើកលែងតែក្នុងករណីការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

[០៩:២១:៤៣]

លោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹងបានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

តើលោកយល់ដែរឬទេ?

**លោក យុន គីម៖**

បាទ ខ្ញុំបាទស្តាប់បាន។

**ប្រធានអង្គជំនុំ៖**

នៅថ្ងៃនេះ អង្គជំនុំជម្រះកត់សម្គាល់ផងដែរនូវមេធាវីប្រឹក្សាដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានផ្តល់ដល់សាក្សីនូវមេធាវីប្រឹក្សាមួយរូប។ ហើយសូមបញ្ជាក់ជាថ្មី ដើម្បីជាប្រតិចារឹក សូម

លោកមេធាវីបញ្ជាក់ប្រាប់អំពីឈ្មោះ ការិយាល័យ ឬក៏និងអត្តលេខរបស់លោក លោកមេធាវីប្រឹក្សា។

**លោក លឹម ប៊ុនហេង៖**

សូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ លឹម ប៊ុនហេង អត្តលេខ៦៨៩ មានការិយាល័យតាំងនៅអគារលេខ ៣៥ សេ.ដេ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

[០៩:២៣:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក យុន គីម តើក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ តើលោកដែលបានផ្តល់សម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើមានតើការធ្វើសម្ភាសន៍ហ្នឹងប៉ុន្មានដងដែរ?

**លោក យុន គីម៖**

**ឆ៖** ក្នុងរយៈពេលកន្លងមកនេះ ខ្ញុំបានធ្វើសម្ភាសន៍ពីរដង ម្តងនៅសំបួរ ម្តងទៀតនៅនឹងភូមិជ្រោយបន្ទាយ។

**ស៖** បាទ អរគុណ។ តើលោកអាចចងចាំបានទេថា នៅឆ្នាំណាដែរ? មិនចាំដល់ខែទេ ត្រឹមតែប្រហែលជាក្នុងឆ្នាំណាក៏បានដែរ? បើចាំថ្ងៃខែឆ្នាំល្អ ប៉ុន្តែបើមិនអាចចាំទេ ត្រឹមតែខែ ឬក៏ឆ្នាំក៏បានដែរ?

**ឆ៖** ខ្ញុំប្រហែលជាឆ្នាំ២០០៩។

**ស៖** បាទ អរគុណ។ នៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬអាន ឬស្តាប់ការអានរបស់អ្នកណាម្នាក់នៅកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេត ដើម្បីជាការរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ លោកមេធាវីរបស់ខ្ញុំបាទនេះ បានអានឲ្យខ្ញុំស្តាប់នូវអត្ថបទដែលបាន សួរខ្ញុំកាលពីពេលមុន។

**ស៖** បាទអរគុណ។ បើតាមសមត្ថភាពដែលអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានស្តាប់ការអាន ដើម្បីរំឭកការចងចាំនេះ វាពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ ឬក៏ផ្តល់នូវចម្លើយជាមួយនឹងអ្នក

ស៊ើបអង្កេតកាលពីពេលមុនដែលលោកអះអាងថា កាលពីឆ្នាំ២០០៩ ដែរឬទេ?

**ឆ៖** ខ្ញុំឃើញថាសេចក្ដីក្នុងឯកសារនោះគឺ ស្របតាមដែលខ្ញុំឆ្លើយ គ្រាន់តែមានចំណុចខ្លះដូចជា ឆ្នាំ១៩៧៣ និង៧៤នេះ ត្រង់ថាខ្ញុំបានចូលរួមប្រជុំជាមួយលោក នួន ជា។ បាទ ក្នុងឯកសារដាក់ ១៩៧៤ ហើយតាមខ្ញុំនឹកទៅឃើញថា ប្រហែល ១៩៧៣។

[០៩:២៦:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀត។ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋមខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

[០៩:២៦:៥៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**លោក សេង ប៊ុនឃាង៖**

**ស៖** សួស្ដីលោក យុន គីម ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោកនៅពេលនេះ។ សំណួរដំបូងរបស់ខ្ញុំគឺចង់សួរលោកថា ក្នុងរយៈពេលដែលលោកបំពេញការងារនៅខេត្តក្រចេះ ឱ្យបក្សកុម្មុយនីស្ដកម្ពុជា ជាពិសេសក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកធ្លាប់បានដឹង ឬក៏ឮ ឬក៏ឃើញមានថ្នាក់ដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាណាដែលទៅកាន់ខេត្តក្រចេះនោះដែរទេ?

**លោក យុន គីម៖**

**ឆ៖** ក្នុងអំឡុងដែលខ្ញុំបំពេញតួនាទី ខ្ញុំភ្លាប់មិនបានទេ ប៉ុន្ដែ គ្រាន់តែឆ្នាំ១៩៧៣ លោក នួន ជា បានទៅប្រជុំនៅក្នុងឃុំដារ កន្លែងហ្នឹង។ បាទ នៅក្នុងឃុំដារ ស្រុកក្រចេះហ្នឹង បានប្រមូលមេឃុំទាំងអស់នៅក្នុងខេត្តក្រចេះ។ ខេត្តក្រចេះយើងអង្គាល់នុ៎ង គឺមានតែបីស្រុកទេ គឺស្រុកសំបូរ ស្រុក

ក្រចេះ និងស្រុកស្នួល ដែលគេកំណត់ថា ជាតំបន់៥០៥។ នៅពេលហ្នឹង គឺលោក នួន ជា បាន-- ជួបលោកម្តងពេលហ្នឹង ហើយក្រៅពីហ្នឹងទៀត អត់ដែលបានជួបមេដឹកនាំថ្នាក់លើទេ។

[០៩:២៨:២៩]

**ស៖** បាទ សូមអរគុណ។ តើលោកនៅចាំទេថា ពេលនោះលោក នួន ជា បានទៅធ្វើអ្វីខ្លះនៅពេលនុ៎ង មាន-- គាត់បានលើកឡើងពីបញ្ហាអ្វីខ្លះ? ហើយសូមលោកជួយជម្រាបជូនអង្គសវនាការផង?

**ឆ៖** នៅពេលនោះ គឺលោក នួន ជា បានទៅប្រជុំណែនាំអំពីបញ្ហាសហករណ៍ គឺគាត់បានជម្រាបដល់អង្គប្រជុំឲ្យដំណើរការអនុវត្ត ការធ្វើសហករណ៍ ព្រោះយើងចាប់ផ្តើមដំបូង យើងមិនត្រូវតក់ក្រហល់ទេ។ យើងត្រូវធ្វើមានក្រុមប្រវាស់ដៃ កន្លែងណាដែលគេមិនសូវយល់យើងធ្វើប្រវាស់ដៃសិន កន្លែងណាគេយល់គួរសមទៅ ធ្វើសហករណ៍កម្រិតទាប ហើយនិងកន្លែងណាគេយល់ខ្លាំងទៅធ្វើសហករណ៍កម្រិតខ្ពស់។ ហើយគាត់បានជម្រាបដល់អង្គប្រជុំថា ដាច់ខាតមិនឲ្យធ្វើសហគមន៍ទេ។ បាទ នេះខ្ញុំ-- ពេលប្រជុំគឺគាត់បានបញ្ជាក់ប៉ុណ្ណឹង ហើយនិងដកពិសោធការងារពាក់ព័ន្ធនឹងសហករណ៍អីហ្នឹង ផលវិបាក ផលស្រួល គាត់បានណែនាំច្បាស់លាស់ដែរ។

[០៩:២៩:៤៧]

**ស៖** បាទ អរគុណ។ នៅពេលដែលលោក នួន ជា គាត់ទៅណែនាំអំពីការបង្កើតសហករណ៍នៅទីនោះ តើគាត់មានបានណែនាំពីមូលហេតុ ឬក៏គោលបំណងអ្វីទេ ក្នុងការបង្កើតឲ្យមានសហករណ៍ហ្នឹង?

**ឆ៖** ពេលនោះគឺគាត់កំណត់ថានៅក្នុងប្រទេសយើងបច្ចុប្បន្នដោយសង្គ្រាម វាខ្ទេចខ្ទាំ ផលវិបាកលើឧបករណ៍ផ្សេងៗ ដូច្នេះយើងមានតែរួមគ្នា ប្រមូលផ្តុំគ្នាធ្វើជាសហករណ៍ ធ្វើជាក្រុមប្រវាស់ដៃទើបបានប្រជាជនយើងអាចរស់បាន។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេថា នៅខេត្តរបស់លោកហ្នឹង សហករណ៍ដែលកើតដំបូងគេហ្នឹង កើតនៅពេលណាដែរ?

**ឆ៖** នៅខេត្តក្រចេះហ្នឹង គឺក្រោយពីលោក នួន ជា បានអប់រំណែនាំ ចុះទៅតាមស្រុករៀងៗខ្លួនវិញនេះ ក៏រៀបចំដំណើរការសហករណ៍នេះឡើង។ ប៉ុន្តែដោយឡែកនៅស្រុកសំបូរ ពេលនោះគឺលេខាបក្សស្រុកដែលមានឈ្មោះ ចែត គាត់ចេញពី ដ-៣ ពីដារហ្នឹងទៅ គាត់ឲ្យប្រជុំនៅស្រុកទៀត។ គាត់ថាយើងមិនបាច់ធ្វើសហករណ៍ទេ មិនធ្វើប្រវាស់ដៃ យើងធ្វើសហគមន៍។ រួចពេលហ្នឹងខ្ញុំបានថា បើអីចឹង

មិនក្បត់ថ្នាក់លើហើយ? គាត់ថា អ្ហែ ឥឡូវត្រូវតែធ្វើ បង្ខំបណ្ដោយបាទ។ ហ្នឹងគាត់ថ្នាក់ឋានៈលេខាបក្សស្រុក។ រួចដល់អ៊ីចឹងទៅទូទាំងស្រុកសំបូរ វាទៅជាដីសហគមន៍ទៅ។ បាទ មិនត្រឹមតែធ្វើការងាររួមទេ ដល់ឲ្យហូបបាយរួមទៀតបាទ។

[០៩:៣១:៥០]

**ស៖** បាទ អរគុណ។ ចុះលោកចាំដែលទេថា សហករណ៍ដែលកើតមាននៅក្នុងខេត្តក្រចេះហ្នឹងមានរហូតដល់ពេលណាដែរ?

**ឆ៖** នៅក្នុងខេត្តក្រចេះហ្នឹង គឺសហករណ៍វាមានជាបន្តបន្ទាប់មករហូតដល់ឆ្នាំ១៩៧៩ តែម្ដងបាទ។

**ស៖** បាទ អរគុណ។ ចុះលោកអាចចាំបានទេថា រចនាសម្ព័ន្ធរដ្ឋបាលរបស់សហករណ៍ហ្នឹងមានការផ្លាស់ប្ដូរអ្វីទេ ចាប់បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** កាលពីដំណើរការសហករណ៍ដំបូងគឺ ដូចជាឃុំតូចៗ មួយឃុំហ្នឹងជាសហករណ៍ នៅជាក្រោមការគ្រប់គ្រងរបស់ឃុំទេ។ ដល់មកចូលឆ្នាំ៧៧ ដូចជាខ្ញុំ នៅឆ្នាំ១៩៧១ ដល់ ៧៦ ខ្ញុំធ្វើមេឃុំនៅឃុំវឌ្ឍនៈ។ ដល់មកឆ្នាំ៧៧ ខ្ញុំមកនៅធ្វើមេឃុំ ឃុំសំបូរ។ ពេលនោះ ឃុំសំបូរបែងចែកសហករណ៍ជាពីរ។ មួយហៅថាសហករណ៍សំបូរ មួយទៀតហៅថាសហករណ៍ស្រែខឿន។ បាទ ហើយពេលហ្នឹងគេដកខ្ញុំមកនៅសហករណ៍ស្រែខឿន បាទ។ ឯ-- ហ្នឹងគឺ-- ឯការបែងចែក ហ្នឹង មេ ភូមិអីបាត់អស់ហើយពេលហ្នឹង គឺទៅជាមេ-- មុខព្រួញ ទៅជាគណៈមុខព្រួញមានគ្នាបីនាក់។ ដូចថាមួយមុខសញ្ញាមួយៗទៅ មុខសញ្ញាការងារទៅវិញហើយដល់ពេលហ្នឹងបាទ។

[០៩:៣៤:០០]

**ស៖** បាទ អរគុណ។ ចុះនៅក្នុងសហករណ៍ហ្នឹង តើលោកដឹងទេថា មានមនុស្សប្រភេទណាខ្លះដែលធ្វើការនៅក្នុងសហករណ៍ហ្នឹង?

**ឆ៖** បាទ នៅក្នុងសហករណ៍ហ្នឹង គឺទាំងអស់គ្នា គឺធ្វើការនៅក្នុងសហករណ៍ គឺមានដូចជានៅរយៈពេលក្រោយឆ្នាំ៧៦ ហ្នឹង នៅតាមសហករណ៍ទាំងអស់ គឺមនុស្សចម្រុះ។ បាទមានមនុស្សចម្រុះគឺមានតាំងពីអ្នកជម្លៀសចេញពីភូមិឃុំផ្សេងៗ ពីព្រោះជម្លៀសនេះមានពីរប្រភេទ។ ប្រភេទមួយនោះគឺអ្នកដែលនៅឃុំខ្លះ ដែលជាឃុំចាស់របស់គេរំដោះយូរហើយហ្នឹង ក៏មានជម្លៀសទៅនៅឃុំណាដែលមនុស្សតិចដែរ ហើយក្រោយមកទៀតមានបងប្អូនយើង អ្នក១៧មេសា។ អ៊ីចឹងទាំងអស់គ្នា គឺនៅជាក្នុង

សហករណ៍ទាំងអស់បាទ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមលើកអំពីអ្វីដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រម-- អ្នកស៊ើបអង្កេតដែរថា ដែលមានក្នុងឯកសារ E3/368 ដែរថាការដែលលោកនៅជាមេឃុំវត្តឬនៈហ្នឹងមានជនជាតិចាមដែលគេបញ្ជូនមក ហើយពួកគេត្រូវបានដាក់លាយឡំជាមួយនឹងអ្នកមូលដ្ឋាន ដោយគ្រាន់ចាត់ទុកថាប្រជាជនថ្មី។ ហើយពេលនោះលោកក៏ឃើញបាន អ៎!មានអ្នក១៧មេសា ដែលជម្លៀសចេញពីទីក្រុងភ្នំពេញជាង១០០គ្រួសារដែរ។ សំណួររបស់ខ្ញុំសួរថា តើលោកដឹងទេថាមូលហេតុអីបានជាត្រូវយកជនជាតិចាម ហើយនិងអ្នកជម្លៀសពីភ្នំពេញមកដាក់លាយឡំជាមួយអ្នកនឹងអ្នកមូលដ្ឋានអ៊ីចឹង?

**ឆ៖** ចំពោះជនជាតិចាមដែលជម្លៀសទៅនៅជាមួយនឹងសហករណ៍របស់ប្រជាពលរដ្ឋនេះ គឺទៅមុនពួក១៧មេសា បាទ ពួកហ្នឹងទៅមុនៗ ហើយមិនមានបែងចែកថាជា អ្នកថ្មីអ្នកអីទេ គឺកំណត់ថាជាជនធម្មតាបាទ។ ហើយដល់ក្រោយមកទៀតទេ បានឃើញមានជម្លៀសអ្នក១៧មេសា ទៅនៅតាមមូលដ្ឋាន។

[០៩:៣៦:៤២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងបន្តទៅសំណួរប្រធានបទមួយទៀតទាក់ទងទៅនឹងការចាប់ខ្លួន។ លោកមានដែរ-- លោកមានចាំទេថានៅ-- តើមានថ្នាក់ដឹកនាំណាខ្លះធ្លាប់បានបញ្ជាឲ្យមានការចាប់ខ្លួនមនុស្សដែលស្ថិតនៅក្រោយការគ្រប់គ្រងរបស់លោកដែរទេ នៅពេលនោះក្នុងសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចនោះ?

**ឆ៖** នៅពេលដែលខ្ញុំទៅកាន់កាប់នៅឃុំសំបូរ នៅឃុំសំបូរនេះគឺមានបញ្ជាមួយពីខាងថ្នាក់ស្រុកបាទ ឲ្យនាំឈ្មោះ តាឈី មួយ។ បាទ តាឈី ហ្នឹងគាត់ជាអតីតមេឃុំចាស់។ ហើយគេមិនប្រាប់ថាគេចាប់ខ្លួនគាត់ទេ គេប្រាប់ថាឲ្យយកសម្ភារៈទៅជាមួយផង មានដូចជា កាំបិតអ៊ីចឹង ព្រោះដកយកទៅជួយការងារគេបាទ។ ហើយដល់គេចាប់យកមកបាត់ខ្លួនគាត់រហូត។ បានខ្ញុំគិតថា ប្រាកដជាគេចាប់ខ្លួនហើយតាហ្នឹង។ កាលហ្នឹងខ្ញុំទៅនៅសំបូរបានប៉ុន្មានខែ ស្រាប់តែឃើញបញ្ជាហ្នឹង អាហ្នឹងថ្នាក់ស្រុកបាទ។

**ស៖** បាទ អរគុណ។ តើលោកដឹងទេថា មានថ្នាក់លើណាផ្សេងទៀតបញ្ជាមកថ្នាក់ស្រុកហ្នឹងឲ្យធ្វើការចាប់ខ្លួនហ្នឹងដែរទេ?

[០៩:៣៨:២៩]

**ឆ៖** ចំពោះបញ្ហានេះ ខ្ញុំក្តាប់អត់បានដែរ ខ្ញុំមិនដឹងថ្នាក់ណាបញ្ជាមកពីលើមកទៀតទេ។ ព្រោះខ្ញុំដូចខ្ញុំបានជម្រាបពីមុនអ៊ីចឹង លោក នួន ជា បានណែនាំថាឲ្យធ្វើសហករណ៍កម្រិតទាប កម្រិតខ្ពស់ទៅដល់ ស្រុកឯនោះៗ អត់គោរពតាមបញ្ជាខាងលើនោះ ទៅដល់ឲ្យធ្វើសហគមន៍បណ្តោយ។ បាទ អ៊ីចឹងបានខ្ញុំគិតថាជំនាន់ហ្នឹងថ្នាក់លើផ្តល់អំណាចធំពេកទៅដល់ថ្នាក់ខេត្ត ថ្នាក់ស្រុក ព្រោះសិទ្ធិៗនោះធំណាស់បាទ។

**ស៖** ចុះទាក់ទងទៅនឹងចម្លើយរបស់លោកដែរនៅក្នុងឯកសារ E3/368 ហ្នឹងលោកបានជម្រាបអ្នកស៊ើបអង្កេតថា ផ្នែកសេដ្ឋកិច្ចគឺ តាឃិន ហើយគាត់ត្រូវបានគេចាប់ខ្លួនក្នុងឆ្នាំ១៩៧៨។ តើលោកដឹងទេថា មូលហេតុអីបានជាគេចាប់ខ្លួន តាឃិន ហ្នឹង?

[០៩:៣៩:៣៦]

**ឆ៖** ចំពោះរឿង តាឃិន គេចាប់ខ្លួននេះ ខ្ញុំក្តាប់អត់បានដែរ ប៉ុន្តែគ្រាន់តែ តាឃិន ហ្នឹងពីមុនគាត់នៅសេដ្ឋកិច្ចស្រុកដល់ក្រោយមកគាត់មកទទួលខុសត្រូវសេដ្ឋកិច្ចរបស់ខេត្តក្រចេះ នៅភ្នំពេញហ្នឹង។ រួចដល់ឆ្នាំ៧៨ហ្នឹង វាមានសភាពមួយចាប់ច្រើនណាស់៧៨ ហ្នឹង គឺបើខាងស្រុកសំបូរខ្ញុំ មេឃុំចង់ចាប់ទាំងអស់។ បាទនៅសល់ពីរបីទេ ហើយគណៈស្រុកអីគេចាប់រលីង ហើយខេត្តហ្នឹងក៏ចាប់អស់ដែរដើម៧៨ហ្នឹង ហើយខ្ញុំអត់ដឹងថា ខាងណាអ្នកចាប់អ្នកអី ប៉ុន្តែគ្រាន់តែ បន្ទាប់មកឃើញយោធាទៅទទួលខុសត្រូវនៅកន្លែងខ្ញុំបាទ។

**ស៖** បាទ អរគុណ។ ហើយនៅក្នុងឯកសារដដែលនេះ ក៏លោកបានបញ្ជាក់ដែរថា បន្ទាប់មកមាន រឿន ជាប្រធានស្រុក និងទទួលបន្ទុកសេដ្ឋកិច្ចផង ហើយបន្ទាប់មកទៀត គេដាក់ឈ្មោះ យន ឲ្យទទួលបន្ទុកសេដ្ឋកិច្ចជំនួស រឿន វិញ។ តើលោកដឹងទេថា មូលហេតុបានជាមានការផ្លាស់ប្តូរអ្នកដែលទទួលបន្ទុកសេដ្ឋកិច្ចនេះច្រើនលើកច្រើនសាអ៊ីចឹង?

**ឆ៖** ក្រោយពីសភាពការណ៍ដែល ខ្ញុំដូចបានជម្រាបហ្នឹង ចាប់គណៈស្រុកជាបន្តបន្ទាប់មកខាងយោធាដំបូងមានតែម្នាក់ទេ បាទទៅកាន់កាប់នៅកន្លែងនោះ ដល់ក្រោយមកឃើញបានពីរនាក់ៗគឺមាន រឿន ជាមួយ ឈូក ហ្នឹង។ អ៊ីចឹង រឿន ក្តាប់អីទាំងអស់ ដល់ក្រោយមកបានបន្ថែមមនុស្សទៀតអ៊ីចឹងការផ្លាស់ប្តូរគ្នាអារឿងសេដ្ឋកិច្ចនេះ មិនជាមិនមែនជាការអីប្លែកទេ ពីព្រោះពីមុនមនុស្សតិច។ ម្នាក់ឯងធ្វើការច្រើនមុខទៅ ដល់រួចទៅផ្លាស់-- ដល់មានអ្នកថ្មីមកថែមទៀត ផ្ទេរការងារខ្លះឲ្យអ្នកដែលមករួមការងារហ្នឹង។

[០៩:៤១:៥៨]

**ស៖** ចុះនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកដឹងទេថា នរណាគេដែលជាអ្នកទទួលបន្ទុក ឬក៏ទទួលខុសត្រូវធំជាងគេផ្នែកសេដ្ឋកិច្ចនុំង?

**ឆ៖** ទូទាំងប្រទេស ខ្ញុំក្តាប់អត់បានដែរ។ ខ្ញុំអត់ដឹង បាទ។

**ស៖** បាទ អរគុណ។ ជាមួយគ្នានេះដែរ លោកក៏បានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត ដែរថា ដែលសួរលោកទាក់ទងទៅនឹងថា នរណាជាប្រធានប-៣ ហើយលោកបានឆ្លើយថា លោកជាប្រធាន ហើយ ពេន ជាអនុ មើលការខុសត្រូវលើយុវជន យុវនារី ដែលដំបូងមាន៤៥០នាក់។ ហើយក្រោយមក មានយុវជន យុវនារី ចំនួនជាង២០០នាក់ ដែលគេបញ្ជូនមកពីឃុំតាម្ញូង ស្រុកមេមត់ ដោយអ្នកមកពី តាម្ញូងនោះ ត្រូវបានគេចោទថា មានជាប់ខ្សែរយៈជាមួយយួន។ សំណួរសួរថាតើមនុស្សទាំង២០០នាក់ ហ្នឹង គេយកមកឲ្យលោកធ្វើអ្វីខ្លះចំពោះពួកគេដែរ?

[០៩:៤៣:១៩]

**ឆ៖** នៅខែ៤ ឆ្នាំ១៩៧៨ គឺនៅសំបូរហ្នឹង គេប្រមូលយុវជន យុវនារីទៅនៅប-៣។ ប-៣ នេះ គឺជាការដ្ឋានមួយដែលគេចាប់កម្មាភិបាល ទៅដាក់នៅទីនោះកាលពីមុនខែ៤ ឆ្នាំ១៩៧៨។ ដល់គេដក កម្មាភិបាលដែលយកទៅថា ធ្វើជាអ្នកទោសហ្នឹងអស់ចេញពីហ្នឹងទៅ គេយកយុវជន យុវនារីទៅដាក់ នៅកន្លែងហ្នឹង។ ដល់ដាក់នៅកន្លែងហ្នឹងគឺ មានចំនួនដំបូង៤៥០នាក់ ហ្នឹងយុវជន យុវនារីនៅក្នុងស្រុក សំបូរ គេឲ្យយោធាគ្រប់គ្រង។ ហើយដល់យោធាគ្រប់គ្រង ប្រើអាជ្ញាពេកវាមានបញ្ហា ដល់បញ្ហាគេសុំ ឲ្យខ្ញុំហ្នឹងមកទទួលខុសត្រូវយុវជន យុវនារីទាំង៤៥០នាក់ នៅកន្លែងហ្នឹង។

[០៩:៤៤:១៣]

ដល់ក្រោយមក មានគេបញ្ជូនយុវជន យុវនារីពីឃុំតាម្ញូង តាម្ញូងយើងនៅក្នុងស្រុកមេមត់ ពួក ហ្នឹងឲ្យមកចូលរួមជាមួយនឹងអង្គភាពនៅស្រែរ៉ុង។ មកនេះគឺអត់មានអី មកចូលរួមជួយធ្វើស្រែចម្ការ ធម្មតា ពីព្រោះពេលនោះគេខ្ញុំថ្ងៃ០១ ខែ៦ ឆ្នាំ៧៨ ហ្នឹង គេឲ្យខ្ញុំទៅនៅប-៣ហ្នឹង ទៅនៅស្រែរ៉ុង គេដាក់ ផែនការឲ្យខ្ញុំរានដី១០០ហិកតា ហើយដីដែលមានហើយមានតែបួនហិកតា ហើយដល់គេបន្ថែមកម្លាំង មកទៀតបាន វាសរុបទៅប្រហែល៧០០នាក់។ បាទ ដល់អ៊ីចឹង ខ្ញុំក៏គ្រោះថ្នាក់ពេលហ្នឹងដែរ ពីព្រោះ សហករណ៍គេស្នងហើយ បើយើងមិនទាន់រានដីផង ថាឲ្យធ្វើបាន១០០ហិកតា អ៊ីចឹងជាបញ្ហាមួយ។ នេះខ្ញុំ-- ក្រុមហ្នឹងគឺមកជួយការងារនៅត្រង់ហ្នឹងទេ ប៉ុន្តែក្រោយមកបានប្រហែលជាពីរខែក្រោយមកគេ

ដកទៅបាត់អស់ អត់ដឹងយកទៅណា ខ្ញុំអត់ដឹង។

[០៩:៤៥:២០]

**ស៖** ចុះលោកចាំទេថា អ្នកណាអ្នកដកយកទៅណាអស់ហ្នឹង អ្នកណាបញ្ជាឲ្យដក?

**ផ៖** ខ្ញុំក្តាប់អត់បានដែរ ព្រោះពេលហ្នឹងគឺការដ្ឋានដែលខ្ញុំនៅនេះ នៅក្រោមការគ្រប់គ្រងរបស់ស្រុកសំបូរ។ បាទ ដំបូងមានលោក ឈូក អនុប្រធានស្រុកហ្នឹង គាត់ទទួលខុសត្រូវ។ ដល់ក្រោយមកទៀត ស្មានលោក ឈូក ហ្នឹងហើយដែលទទួលខុសត្រូវ ស្រាប់គាត់ថា ឲ្យកម្លាំងហ្នឹងគេសុំយក គេដកយកទៅវិញហើយ ថាយកមកកំពង់ធំ ប៉ុន្តែមិនដឹងយកទៅខាងណា ខ្ញុំអត់ដឹងដែរ។

**ស៖** បាទ អរគុណ។ ទាក់ទងនឹងចំណុចមួយទៀត គឺទាក់ទងទៅនឹងការចូលរួមប្រជុំរៀនសូត្រនយោបាយ ថាតើលោកធ្លាប់បានចូលរួមប្រជុំ ឬក៏រៀនសូត្រនយោបាយជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាណាខ្លះដែរទេ នៅក្នុងអំឡុងពេលដែលកម្ពុជាប្រជាធិបតេយ្យកាន់អំណាចហ្នឹង?

**ផ៖** ខ្ញុំបានចូលរួមរៀនជាញឹកញាប់ដែរ ជាមួយនឹងថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំស្រុក ពីព្រោះនៅស្រុកហ្នឹងគឺដូច-- ក៏ជាសមាជិកគណៈកម្មាធិការគណបក្សខេត្តដែរ អ៊ីចឹងគឺបានរៀនជាមួយថ្នាក់ស្រុក និងថ្នាក់ខេត្តហ្នឹង។

[០៩:៤៧:០៣]

**ស៖** បាទ អរគុណ។ ចុះលោកធ្លាប់ដែលមករៀននៅទីក្រុងភ្នំពេញទេ?

**ផ៖** ជំនាន់នោះ ខ្ញុំអត់ដែលបានមករៀននៅភ្នំពេញទេបាទ។

**ស៖** នៅពេលដែលលោកបានចូលរៀនជាមួយនឹងថ្នាក់ស្រុក ថ្នាក់ខេត្តហ្នឹង តើលោកបានទទួលឯកសារអ្វីខ្លះនៅក្នុងវគ្គរៀនសូត្រនោះដែរទេ?

**ផ៖** នៅពេលរៀនសូត្រហ្នឹងគឺ ខ្ញុំបានរៀននៅក្នុងទង់បដិវត្ត បាទ។

**ស៖** ចុះនៅពេលនោះលោកមានដឹងដែរទេថា ទង់បដិវត្តនេះអ្នកណាជាអ្នករៀបចំតាក់តែងឡើងដែរ?

**ផ៖** ទង់បដិវត្តនេះ ខ្ញុំដឹងថា មជ្ឈិមបក្សជាអ្នកចាត់ចែង។

**ស៖** បាទ អរគុណ។ ចុះទាក់ទងទៅនឹងខ្លឹមសារ ដែលមាននៅក្នុងទង់បដិវត្តនេះ តើខ្លឹមសារហ្នឹងមានលើកឡើងអំពីមតិរបស់ថ្នាក់ដឹកនាំ ឬក៏សុន្ទរកថារបស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាណាដែរទេ?

[០៩:៤៨:៥៦]

**ឆ៖** ក្នុងទង់បដិវត្តនេះ យូរពេកទៅខ្ញុំភ្លេចចង់អស់ហើយ ប៉ុន្តែគ្រាន់តែដឹងថាមានការណែនាំអំពីការធ្វើសហករណ៍ បញ្ហាណែនាំពីបញ្ហាការងារផ្សេងៗ។

**ស៖** បាទ អរគុណ។ តើលោកដឹងទេថា នៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង តើទស្សនាវដ្ដីទង់បដិវត្តហ្នឹង គេចេញផ្សព្វផ្សាយប៉ុន្មានថ្ងៃក្នុងមួយដង?

**ឆ៖** ចំពោះឯកសារទង់បដិវត្តនេះ ខ្ញុំក្ដាប់អត់បានច្បាស់ថា ប៉ុន្មាន មិនបានច្បាស់លាស់ដែររឿងប៉ុន្មានថ្ងៃ ប៉ុន្មានខែអី អាហ្នឹងគ្រាន់តែពេលណាបានមក ខាងស្រុកគេឱ្យទៅបានទទួលទៅ។

**ស៖** បាទ អរគុណ។ អ៊ីចឹងលោកដឹងទេថា ទស្សនាវដ្ដីទង់បដិវត្តហ្នឹង គេធ្វើឡើងសម្រាប់ចែកចាយឱ្យអ្នកអ្នកណាខ្លះដែរ?

**ឆ៖** ទង់បដិវត្តនេះគឺចែកសម្រាប់តែជួរថ្នាក់ដឹកនាំគណបក្ស ដូចជាមួយឃុំអ៊ីចឹង បានតែមួយសម្រាប់ជាត្រីវិស័យអនុវត្តការងារ។

**ស៖** បាទ អរគុណ។ ទាក់ទងទៅនឹងទស្សនាវដ្ដីទង់បដិវត្តនេះ តើលោកនៅចាំអំពីទម្រង់ ឬក៏រូបរាងរបស់ទស្សនាវដ្ដីនេះដែរទេ? សូមលោកជួយរៀបរាប់ជូនអង្គសវនាការ អំពីរាងរៅរបស់វាតើយ៉ាងម៉េចខ្លះបាទ?

**ឆ៖** ខ្ញុំចង់ភ្លេចអស់ដែរហើយ ប៉ុន្តែគ្រាន់ថា ដែលរាង-- មានទង់មួយនៅនឹងៗទស្សនាវដ្ដីហ្នឹង ហើយមិនធំប៉ុន្មានទេ ម៉ាល្មម។

**លោក សេង ប៊ុនឃាង៖**

បាទ ឥឡូវខ្ញុំអស់សំណួរហើយ ហើយខ្ញុំនឹងប្រគល់វេទិកានេះឱ្យសហការីរបស់ខ្ញុំសួរបន្តទៀតបាទ។ សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សីផងដែរបាទ។

[០៩:៥១:២៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកសាក្សី យុន គីម! ខ្ញុំចង់ត្រឡប់ទៅរក ទៅក្រោយវិញបន្តិច។ តើលោកអាចជម្រាបខ្ញុំបានទេ តើលោកនៅចាំបក្សកុម្មុយនីស្តកម្ពុជា ហើយប្រសិនជាលោកចាំ ថាតើលោកក្លាយជាសមាជិកនៅពេលណា? ហើយអ្នកណាជាអ្នកណែនាំឲ្យលោកចូលបក្សកុម្មុយនីស្តកម្ពុជានោះ?

**លោក យុន គីម៖**

**ឆ៖** ខ្ញុំបានចូលក្នុងសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧១ ហើយអ្នកដែលនាំខ្ញុំចូលគឺឈ្មោះ ចែត ជាលេខាបក្សស្រុកសំបូរ។

[០៩:៥៣:០៥]

**ស៖** នៅក្នុងចម្លើយរបស់លោកនោះ លោកឆ្លើយនោះថា លោកបានកើតនៅក្នុងស្រុកក្រូចឆ្មារ ប៉ុន្តែខ្ញុំឃើញថា លោកបានចូលបក្សនៅក្នុងស្រុកក្រចេះ។ ថាតើលោកអាចប្រាប់ខ្ញុំបានទេ នៅពេលណាដែលលោកបានប្ដូរពីក្រូចឆ្មារមកនៅក្រចេះនោះ នៅស្រុកក្រចេះបាទ?

**ឆ៖** ខ្ញុំកើតនៅក្នុងស្រុកក្រូចឆ្មារ នៅឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ នៅពេលដែលខ្ញុំអាយុបាន១០ឆ្នាំ គឺនៅឆ្នាំ១៩៥០ ប្រទេសជាតិគឺមានអសន្តិសុខ នៅតាមម្ដុំខាងខ្ញុំនោះដូចពួកគ្រូអ៊ំ គ្រូអីអ៊ីចឹង ដើរជម្រិតលុយអ្នកស្រុកពេលយប់ទៅ ហើយដោយឪពុកខ្ញុំមិនអាចទ្រាំបាននឹងការកៀបសង្កត់ទាំងសងខាង ពេលនោះគឺពួកគ្រូអ៊ំមកយកលុយមួយសាទៅ ដល់ដឹងដល់ខាងប៉ូលិស ប៉ូលិសទៅសម្លុតមួយសាទៀត។ ដល់អ៊ីចឹងហើយគាត់ក៏សម្រេចចិត្តផ្លាស់ទីលំនៅទៅរស់នៅភូមិរកាកណ្ដាល ឃុំក្រចេះ ខេត្តក្រចេះ នៅក្បែរទីក្រុងក្រចេះហ្នឹង។ បាទ ខ្ញុំទៅរស់នៅទីនុ៎ង ហើយខ្ញុំក៏បានរៀនសូត្រអីនៅនុ៎ងខ្លះទៅ ហើយដល់ពេលខ្ញុំឈប់រៀន ខ្ញុំសម្រេចចិត្តទៅផ្សងព្រេងធ្វើកសិកម្មនៅក្នុងយុវវ័យ នៅឆ្នាំ១៩៦២ ខ្ញុំទៅនៅភូមិវឌ្ឍនៈហ្នឹងបាទ។ ទៅនៅធ្វើស្រែចម្ការជាមួយអ្នកស្រុកហ្នឹង បាទខ្ញុំអត់មានប្រពន្ធកូនទេអង្កាល់នោះបាទ ហើយរហូតដល់ឆ្នាំ៦៩ បានខ្ញុំយកប្រពន្ធ។ ដល់មកឆ្នាំ៧០ រដ្ឋប្រហារទៅ ក៏សភាព-ការណ៍ហ្នឹងវាអ៊ីចឹង។ ដូច្នេះដំណើររឿងនៃជីវិតរបស់ខ្ញុំអ៊ីចឹង។ សូមមានមតិប៉ុណ្ណេះ។

[០៩:៥៥:០៤]

**ស៖** សូមអរគុណ ដែលលោកបានពន្យល់ តើលោកអាចប្រាប់ខ្ញុំបានទេ មុនពេលដែលលោក--គេអនុញ្ញាតឲ្យចូលសមាជិកបក្ស។ តើលោកត្រូវមានការអប់រំ ឬក៏ទទួលការបណ្ដុះបណ្ដាលអំពីមាគ៌ា

បក្ស ឬក៏គោលនយោបាយបក្សអ្វីទេ?

**ឆ៖** ក្រោយរដ្ឋប្រហារនេះ គឺសភាពការណ៍នៅក្នុងប្រទេសជាតិនេះ ក៏វាមានការច្របូកច្របល់ដែរ ដែលមានពួកដែលខ្លះឱកាសនិយម វាធ្វើជាក្រុម ថាវាជាអ្នកស្នេហាជាតិអីហ្នឹង ដូចជា ពួក ឃុត ឧត្តម វង្សវឌ្ឍនា អីនាំប្រជាជនមកពីស្រុកសំបូរហ្នឹងច្រើនណាស់ មកស្លាប់នៅកំពង់ធំហ្នឹង។ ពេលហ្នឹងខ្ញុំអត់បានចូលសភាពអីទេ ព្រោះខ្ញុំមើលឃើញទៅអត់ស្រួល។ ដល់ក្រោយមក គឺមានចលនាបដិវត្តន៍នេះ ខ្ញុំគិតថាវាជាចំណុចមួយល្អដែរ។ ដូច្នេះហើយខ្ញុំក៏បានចូលរួម ដោយបានទៅរៀនសូត្រ ទៅអី នៅស្រុកជាច្រើនដងទៅ ហើយទីបំផុតក៏ខាងស្រុកហ្នឹង ក៏បានចាត់បញ្ចូលខ្ញុំទៅជាសមាជិកគណបក្សកុម្មុយនីស្តកម្ពុជាទៅ បាទ។

[០៩:៥៦:៣៥]

**ស៖** លោកបានប្រាប់យើងថា គេបានតែងតាំងលោកធ្វើជាប្រធាននៃឃុំវឌ្ឍនៈ នៅក្នុងឆ្នាំ ១៩៧១ ហើយលោកបន្តធ្វើតំណែងហ្នឹង រហូតដល់ចុងឆ្នាំ១៩៧៦។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរលោកមួយចំនួនអំពីតួនាទីលោកជាប្រធានឃុំ។ តើលោកអាចប្រាប់យើងខ្ញុំបានទេ ឃុំវឌ្ឍនៈនោះ មានទីតាំងនៅកន្លែងណាដែរបាទ?

**ឆ៖** ឃុំវឌ្ឍនៈនេះ គឺជាផ្នែកមួយនៃស្រុកសំបូរ បាទ។ ពីមុនឆ្នាំ១៩៧១នេះ គឺឃុំវឌ្ឍនៈនេះ ស្ថិតនៅក្នុងឃុំកំពង់ចាម។ ឃុំកំពង់ចាមនេះ ជាឃុំមួយដែលមានទីតាំងនៅលើកោះរងាវ ដែលជាកោះធំជាងគេនៅក្នុងប្រទេសកម្ពុជា។ ហើយដល់មកឆ្នាំមួយពាន់ប្រាំបួនរយ-- អ៎ នែ៎ ទីតាំងនៅហ្នឹង ហើយចម្ងាយពីក្រុងក្រចេះទៅដល់ឃុំវឌ្ឍនៈនេះ គឺប្រហែលជា២៤គីឡូ ប៉ុន្តែត្រូវឆ្លងទន្លេទៀត នៅត្រើយស្តាំទន្លេមេគង្គបាទ។ នេះទីតាំងរបស់ឃុំវឌ្ឍនៈ។

[០៩:៥៨:០៥]

**ស៖** តើត្រូវដែរទេ ឃុំវឌ្ឍនៈនោះ នៅៗនៅច្រាំងខាងលិចនៃទន្លេមេគង្គ ហើយស្រុកសំបូរ និងស្រុកក្រចេះ ឬក៏ឃុំសំបូរនៅខាងត្រើយខាងកើតនៃទន្លេមេគង្គ។ តើអីចឹងឬទេ?

**ឆ៖** បាទ ពិតហើយ។ ឃុំវឌ្ឍនៈនេះ នៅត្រើយខាងលិចទន្លេមេគង្គ បាទ។ នៅព្រំប្រទល់ជាប់ជាមួយស្រុកព្រែកប្រសប់។ ឯឃុំសំបូរនៅខាងកើតទន្លេមេគង្គ ហើយឃុំទល់មុខនឹងឃុំវឌ្ឍនៈនេះ ហៅថា ឃុំសណ្តាន់។ បើយើងទៅតាមផ្លូវចាស់ ផ្លូវពីដើមទៅខេត្តស្ទឹងត្រែង ទៅដល់ឃុំសណ្តាន់ហ្នឹង មានផ្លូវមួយបត់ទៅខាងកើត អាហ្នឹងបានផ្លូវទៅស្ទឹងត្រែង។ ប៉ុន្តែឥឡូវនេះ យើងមានផ្លូវថ្មី គឺជិតដល់ទីក្រុង

ក្រចេះ មានផ្លូវមួយកាត់ទៅស្ទឹងត្រែងតែម្តងបាទ។

[០៩:៥៩:២១]

**ស៖** សូមអរគុណ សូមលោករៀបរាប់ជូនតុលាការ។ ថាតើអ្វីជាតួនាទី និងភារកិច្ចរបស់លោក កាលពីលោកធ្វើប្រធានឃុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** តួនាទីប្រធានឃុំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺបញ្ហាធំបំផុត គឺបញ្ហាសេដ្ឋកិច្ច ធ្វើយ៉ាងម៉េចកែលម្អកសិកម្ម បាទ។ ពីព្រោះជំនាន់នោះ គឺថ្នាក់លើណែនាំសំខាន់បំផុត ឲ្យដោះស្រាយបញ្ហាទឹកធ្វើស្រែ មានការធ្វើទំនប់តូច ទំនប់ធំ ទៅតាមសភាពជាក់ស្តែងនៅក្នុងមូលដ្ឋានមួយៗ ហើយនិងការងារគឺគ្រប់មុខនៅក្នុងសង្គម គឺថែរក្សាសណ្តាប់ធ្នាប់ដល់ប្រជាពលរដ្ឋ គិតគូរសំខាន់បញ្ហាសុខភាពប្រជាពលរដ្ឋ គឺនៅគ្រប់មូលដ្ឋានហ្នឹង គឺមានមន្ទីរពេទ្យ ទោះជាមានថ្នាំល្អ មិនល្អក្តី ក៏មានកន្លែងសម្រាប់ប្រជាជនសម្រាកព្យាបាល មានកន្លែងសម្រាលកូនដោយមានការបណ្តុះបណ្តាលឆ្មប ជាឆ្មបមធ្យមដែរ កាលជំនាន់នុ៎ងបាទ។

**ស៖** តើឃុំមានផ្នែកយោធា ហើយនិងផ្នែកសន្តិសុខដែរឬទេ?

**ឆ៖** នៅក្នុងឃុំនេះគឺមាន១រចនាសម្ព័ន្ធរបស់ឃុំមាន មេឃុំទទួលខុសត្រូវរួម ហើយមានអនុប្រធានទទួលផ្នែកយោធា និងសមាជិកម្នាក់ទទួលសេដ្ឋកិច្ច និងសមាជិកម្នាក់ទៀតទទួលផ្នែកសន្តិសុខ និងម្នាក់ទៀតគឺទទួលសង្គមកិច្ច និងវប្បធម៌។ មានប្រាំរូបនៅក្នុងគណៈកម្មាធិការហ្នឹង។

[១០:០១:៣៣]

**ស៖** តើលោកអាចរៀបរាប់ប្រាប់ខ្ញុំបានទេ អំពីការទទួលខុសត្រូវរបស់ផ្នែកខាងសន្តិសុខ ហើយនិងខាងយោធាហ្នឹង តើមានតួនាទីខុសគ្នាដូចម្តេចរវាងហៅផ្នែកពីរនេះបាទ?

**ឆ៖** ខាងផ្នែយោធានេះគឺមានតួនាទីជំនាន់ហ្នឹងគឺ សម្រាប់មើលសណ្តាប់ធ្នាប់នៅក្នុងមូលដ្ឋាន គឺឧបមាថាបើមានបញ្ហាអី គឺកម្លាំងយោធានេះមានឈ្លប។ បាទ អ៊ីចឹងទទួលខុសត្រូវលើក្នុងមូលដ្ឋានហ្នឹងប្រហែលមានបញ្ហាអីកើតឡើងគឺឈ្លបនេះជាអ្នកទទួលខុសត្រូវ ហើយឯបញ្ហាសន្តិសុខនេះ មានតែម្នាក់ ឬពីរនាក់ទេ គ្រាន់តែថាមានបញ្ហាអីគ្រាន់រាយការណ៍ឲ្យទៅមកខាងឃុំ ឬក៏ឲ្យទៅថ្នាក់លើប៉ុណ្ណឹងពាក់ព័ន្ធនឹងការងារសន្តិសុខហ្នឹង។

**ស៖** ហើយនៅក្នុងសម័យកាលនោះ ដែលលោកជាប្រធានឃុំវឌ្ឍនៈនោះ តើអ្នកណាជាថ្នាក់លើដែលលោកទទួលបញ្ជា ឬក៏លោករាយការណ៍ទៅឲ្យថ្នាក់លើនោះ?

**ឆ៖** ថ្នាក់លើរបស់ឃុំគឺស្រុក។ ស្រុកនេះគឺដំបូងនៅ ស្រុកសំបូរខ្ញុំនេះ គឺមាន តាចែត ហ្នឹង ដល់ក្រោមមកទៀតមានគឺ តាចែត ហ្នឹងត្រូវផ្លាស់ប្តូរមកនៅក្រចេះទៅ ឡើងលោក ផាន បាទ។ ដល់ក្រោយមកលោក ផាន ហ្នឹងក៏ត្រូវផ្លាស់មកក្រចេះទៀតទៅ ឡើងលោក នី។ លោក នី ហ្នឹងដល់ក្រោយមកទៀត ដល់ឆ្នាំ៧៨ ហ្នឹងត្រូវចាប់ខ្លួន។ ដល់លោក នី ត្រូវចាប់ខ្លួនទៅ ឡើងលោក វឿន ហ្នឹងរហូតដល់យើងរត់តែម្តង។

[១០:០៣:៥៥]

**សៈ** សូមអរគុណដែលលោកបានឆ្លើយ ហើយខ្ញុំនឹងជជែកតទៅទៀតថ្ងៃនេះអំពីឆ្នាំ១៩៧៨ ហើយនៅក្នុងឃុំវឌ្ឍនៈក្រៅពីឃុំវឌ្ឍនៈ តើមានឃុំអ្វីទៀតទេ នៅក្នុងស្រុកសំបូរនេះ?

**ឆ៖** នៅក្នុងឃុំសំបូរ កាលពីជំនាន់មុន៧៩នេះ គឺយើងមានឃុំវឌ្ឍនៈមួយ, ឃុំសណ្តាន់ទីពីរ, ទីបីឃុំសំបូរ, ទីបួនឃុំកោះខ្ញែរ, ទីប្រាំឃុំបឹងចារ, ទីប្រាំមួយ ឃុំកំពង់ចាម, ទីប្រាំពីរ ឃុំក្បាលដំរី ទីប្រាំបី ឃុំអូរត្រែង និងទីប្រាំបួន ឃុំស្រែជិះ។ មានតែប្រាំបួនឃុំពេលនោះ ប៉ុនមកដល់បច្ចុប្បន្ននេះឃុំអូរត្រែងនេះ អត់មានឈ្មោះទេ គេបង្កើតទៅជាឃុំអូរគ្រៀងវិញ ហើយនិងថែមឃុំរលួសមានជ័យមួយទៀត ទៅជាដប់ឃុំបច្ចុប្បន្ន។

**សៈ** តើមន្ទីរស្រុកសំបូរនោះមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** ទីតាំងស្រុកសំបូរ កាលពីជំនាន់លោក ចែត នៅគាត់បោះទីតាំងនៅឃុំកំពង់លើ នៅគេហៅភូមិស្វាយចេក នៅក្នុងឃុំកោះខ្ញែរ បាទចម្ងាយពីសំបូរប្រហែលជាបីគីឡូជាង ថាបួនគីឡូម៉ែត្រចុះ ហើយដល់មកក្រោយមកទៀត គឺជំនាន់លោក ផាន គាត់ធ្វើអីហ្នឹង លោក នី អីហ្នឹង គាត់មកបោះទីតាំងមួយនៅខាងក្រោមទីរួមស្រុកបច្ចុប្បន្ននេះ ប្រហែលជាប្រាំ-ប្រាំមួយរយម៉ែត្រនៅខាងក្រោមហ្នឹង បាទ នៅតាមមាត់ទន្លេដដែលហ្នឹ ប៉ុន្តែគ្រាន់តែថានៅខាងក្រោមទីរួមស្រុកម្តង នៅក្នុងទឹកដីឃុំសំបូរ។

[១០:០៦:០៧]

**សៈ** លោកបានបញ្ជាក់ថា មានស្រុកបីនៅក្នុងខេត្តក្រចេះ គឺនៅតំបន់៥០៥ មានស្រុកសំបូរ មានស្រុកក្រចេះ ហើយនិងស្រុកស្នួល។ តើលោកអាចប្រាប់យើងខ្ញុំបានទេ ថាតើអ្នកណាជាលេខាស្រុកទាំងបីនោះនៅស្រុកក្រចេះ និងស្រុកស្នួលនោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំៗក្តាប់អត់បានដែរ បញ្ហាស្រុកពីរទៀតនោះ ស្រុកស្នួល និងស្រុកក្រចេះហ្នឹង ខ្ញុំអត់ដឹងពីណាធ្វើអីផងបាទ។ ឯស្រុកសំបូរ ដំបូងលោក ចែត ហ្នឹងគាត់ធ្វើលេខា ដល់គេផ្លាស់គាត់ទៅ អត់មាន

អ្នកណាមក ដូចថាដោយឡែកៗទៀតទេ ក្នុងរចនាសម្ព័ន្ធហ្នឹង ព្រោះគ្រាន់តែថា ខ្ញុំគិតថា អ្នកណាឡើងធ្វើចៅហ្វាយស្រុក ប្រហែលជាអ្នកហ្នឹងជាលេខាហើយ បាទមកក្រោយ ពីព្រោះអត់ឃើញមនុស្សផ្សេង។

[០៩:០៧:២០]

**ស៖** សូម-- យើងនឹងនិយាយអំពីថ្នាក់តំបន់នៅពេលនេះ នៅក្នុងចម្លើយដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ លោកបាននិយាយថា លេខាតំបន់៥០៥ ពីឆ្នាំ១៩៧១ ដល់១៩៧៦ មាន តាយ៉ុ, តាយី ជាអ្នកនៅបន្ទាប់នៅក្នុងឆ្នាំ១៩៧៦ ហើយនិងដល់ឆ្នាំ១៩៧៨ ហើយប្រធានបន្តមកទៀតនោះ គឺម្លូង។ សំណួរដែលខ្ញុំចង់សួរលោកនោះ គឺថាតើលោកបានជួបគាត់ញឹកញាប់ទេ តាយ៉ែម តាយី ដែលពួកគាត់ធ្វើការជាលេខាស្រុកក្រចេះនោះ កាលណោះបាទ?

**ឆ៖** អ៊ូ! ខ្ញុំសូមជម្រាបថា លោក យ៉ែម នេះគាត់ជាលេខាបក្សខេត្ត មិនមែនរបស់លេខាបក្សស្រុកទេ គឺគាត់ជាលេខាបក្សខេត្ត។ ដល់ក្រោយមក គឺផ្លាស់គាត់បាត់ទៅ ហើយឡើង លោក យី ហ្នឹងគាត់បន្តការងារហ្នឹង។ ក្នុងជំនួបជាមួយនឹងលេខបក្សខេត្តនេះ គឺបានជួបនៅពេលសន្និបាតនៅខេត្តម្តងៗ ហើយនិងពេលចូលវគ្គ បាទចូលវគ្គ ជួនកាលមួយឆ្នាំអីចឹងទៅ មានវគ្គ ជួន២០ថ្ងៃ ជួន១៥ថ្ងៃ វគ្គប្រចាំឆ្នាំបាទ ជួបតែពេលហ្នឹង។

[១០:០៩:១៩]

**ស៖** លោកបានបញ្ជាក់ថា ការប្រជុំនៅក្នុងថ្នាក់ខេត្ត ហើយវគ្គសិក្សាជួនកាលគឺថា ចំណាយពេល១៥ថ្ងៃ ហើយក្រៅពីវគ្គសិក្សាប្រចាំឆ្នាំថា តើមានការប្រជុំសន្និសីទ ឬក៏សន្និបាតអ្វីទៀតទេនៅថ្នាក់ខេត្តនោះ ក្រៅពីអ្វីដែលលោកបានលើកឡើង?

**ឆ៖** នៅខេត្តហ្នឹង ខាងខ្ញុំអត់សូវបានប្រជុំទៀងទាត់ទេ ព្រោះអត់-- ក្រៅពីការបើកសាលាសាលា ហើយនិងសន្និបាតហ្នឹង អត់បានមកប្រជុំអីទៀតទេ។ ការប្រជុំមានតែធ្វើនៅថ្នាក់ស្រុក។

**ស៖** ចាតើអ្នកណាខ្លះ អ្នកដែលទៅចូលរួមវគ្គសិក្សាប្រចាំឆ្នាំដែលលោកជម្រាបថា វគ្គនោះមានរយៈពេលដល់ទៅ១៥ ថ្ងៃនោះ?

**ឆ៖** វគ្គដែលមួយសាៗនេះ គឺមានគណបក្សឃុំបាទ ហើយនិងពេលខ្លះគឺមានរហូតដល់ថ្នាក់ភូមិបាទ។ មានថ្នាក់ភូមិក៏មានបង្រៀនដែរ ហើយនិងថ្នាក់ស្រុក ហើយនិងតាមក្រសួងមន្ទីរផ្សេងៗជុំវិញខេត្តហ្នឹងចូលរួមទាំងអស់គ្នាហ្នឹង ទាំងយោធាក៏រៀនជាមួយគ្នាបាទ។

**សះ** ព្រឹកមិញនេះ លោកបានប្រាប់សហព្រះរាជអាជ្ញាជាតិថា អំពីវគ្គសិក្សាដែលបានរៀនអំពីទង់បដិវត្ត តើវគ្គហ្នឹង វគ្គជាមួយគ្នានឹងវគ្គប្រចាំឆ្នាំនៅខេត្ត ឬក៏មានវគ្គផ្សេងទៀតនៅក្នុងពេលនោះដែលលោកបានសិក្សាអំពីទស្សនាវដ្ដីទង់បដិវត្តនោះ?

[១០:១១:៣៥]

**ឆះ** ពេលរៀនគ្រប់វគ្គហ្នឹង ខ្ញុំសន្និដ្ឋានថា ជាខ្លឹមសារដែលដកស្រង់មួយចំណែកធំពីទង់បដិវត្តពីព្រោះអត្ថន័យហ្នឹងគឺ ព្រោះទង់បដិវត្តជាឯកសារសម្រាប់ណែនាំផ្លូវក្នុងការអនុវត្តរាល់ការងារ។

**សះ** តើលោកបានសិក្សាអំពីទង់បដិវត្តនៅក្នុងកិច្ចប្រជុំ ឬក៏វគ្គសិក្សានៅថ្នាក់ស្រុកដែរឬទេ?

**ឆះ** កន្លងមកនេះ គឺក្នុងការរៀនសូត្រយើងមិនដែល យើងយកទង់ហ្នឹងមកអាន ហើយនាំគ្នារៀននោះទេ គ្រាន់តែថា ទង់ហ្នឹងចែកៗ ទៅតាមមូលដ្ឋាន ប៉ុន្តែដល់យើងយកទង់នឹងមកមើលទៅ ន័យនៃការរៀនសូត្រហ្នឹងក៏ជាខ្លឹមសារនៃទង់ហ្នឹងដែរ។

**សះ** ខ្ញុំដូចមិនទាន់ច្បាស់នៅពេលដែលគេចែកទង់បដិវត្តហ្នឹង គឺចែកទៅឲ្យអ្នកចូលរួមទាំងអស់គ្រប់គ្នាទេ ទង់បដិវត្តនោះបាទ?

[១០:១៣:០២]

**ឆះ** ខ្ញុំបានជម្រាបរួចហើយថា ទង់បដិវត្តនេះ មួយឃុំគេឲ្យតែមួយក្បាលទេបាទ គឺឲ្យមកគណ:កម្មាធិការបក្សឃុំ អត់មានចែកទូលាយទេបាទ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**សះ** តើខ្ញុំយល់ត្រូវដែរទេ បើសិនជាលោកចង់អានទង់បដិវត្តដោយខ្លួនឯង លោកទៅៗមន្ទីរស្រុកដើម្បីទៅអានបានទេ ឬក៏យ៉ាងដូចម្ដេចបាទ?

**ឆះ** កន្លងមកយើង ជំនាន់នោះអត់មានបណ្ណាល័យអីសម្រាប់ដាក់អានចំហទេ គឺគ្រាន់ថា បើចែកមកខ្ញុំអីចឹង ឧបមាថា ទង់ចែកមកខ្ញុំហើយ ខ្ញុំមើលនៅក្នុងគណ:កម្មការបក្សឃុំរបស់ខ្ញុំទៅ។ បាទអត់មាននៅស្រុកនោះ គេអត់មានដាក់ចំហអីទេ គឺមាននៅតាមឯកជនរៀងខ្លួន តាមបុគ្គល។

[១០:១៤:០៩]

**សះ** សូមអរគុណលោកច្រើន ដែលលោកបានឆ្លើយបំភ្លឺបែបនេះ។ នៅក្នុងចម្លើយរបស់លោកដែលលោកបានផ្ដល់ជូនទៅសហចៅក្រមស៊ើបអង្កេតនោះ លោកក៏បានបញ្ជាក់សមាជិកផ្សេងទៀតនៅក្នុងតំបន់-- នៅក្នុងគណ:តំបន់៥០៥ គឺ ខឿន ដែលជាអ្នកទទួលខុសត្រូវខាងយោធាតំបន់ ហើយនិងកង ទទួលខុសត្រូវខាងសន្តិសុខក្នុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៧។ តើលោកនៅចាំសមាជិកផ្សេងទៀតទេ

នៅក្នុងតំបន់៥០៥ នៅក្នុងគណៈតំបន់នោះ ក្រៅពីលេខាទាំងប៉ុន្មានដែលលោកបាននិយាយនេះ? គឺ ខឿន ហើយនិង គួន ហើយនិង កង នោះ តើលោកនៅចាំអ្នកផ្សេងទៀតដែរឬទេបាទ?

**ឆ៖** កង ខ្ញុំចាំ ក្រៅពីហ្នឹងដូចជាខ្ញុំអត់សូវស្គាល់ អត់មានស្គាល់ពីណាទៀតហ្នឹងនៅក្នុងគណៈតំបន់ ឯ ភឿន នេះគាត់នៅយោធាស្រុកទេ ស្រុកសំបូរ។ ភឿន អត់មែននៅក្នុងគណបក្សខេត្តទេ។ ឯ មឿន នេះ គឺជាអ្នកមកទទួលខេត្តក្រចេះនៅពេលដែលចាប់ យី ចាប់ គួន អីហ្នឹងរួចទៅមានឈ្មោះ មឿន មកនៅ។ មឿន ជាមួយ ឃុន មកនៅទទួលខេត្តក្រចេះហ្នឹង ហើយឈ្មោះហ្នឹងខ្ញុំមិនទាន់ស្គាល់ផង មិនដឹងមួយណាផង ពីព្រោះបានតែបន្តិចទៅវត់ហើយ។

**ស៖** តើ មឿន នោះមកពីស្រុកណានៅពេលដែលគាត់មកជំនួស តាយី គាត់មកធ្វើជាលេខាតំបន់នោះបាទ?

[១០:១៦:១៥]

**ឆ៖** ឈ្មោះ មឿន នេះ ឃុន នេះ ខ្ញុំក្តាប់អត់បានដែរ អត់ដឹងមកពីស្រុកណាដែរ ពីព្រោះខ្ញុំអត់បានស្គាល់ ស្រួលបួលផងបាទ។

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើស្រុកក្រចេះជាតំបន់ស្វយ័តមួយដែរឬទេ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំក្តាប់បានតាមរយៈស្រុកសំបូរ គេបានប្រាប់ខ្ញុំថា តំបន់យើងនេះ គឺជាតំបន់ស្វយ័តនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ថ្នាក់មជ្ឈិម។ ហើយពីមុនតាមខ្ញុំដឹងថា នៅក្នុងភូមិភាគឦសាន ពីព្រោះដល់មកក្រោយមកទៀតទេបានថា បំបែក ផ្តាច់ចេញពីភូមិភាគឦសានទៅជាតំបន់ស្វយ័ត។

[១០:១៧:២៥]

**ស៖** ថាតើតំបន់ក្រចេះនោះបានកាត់ចេញពីភូមិភាគឦសានហ្នឹងនៅឆ្នាំណា ដែលក្រោយមកដែលក្លាយជាតំបន់ស្វយ័តនោះ?

**ឆ៖** ខ្ញុំក្តាប់អត់បានដែរ បើសិនជា តាមខ្ញុំស្មានប្រហែលជាឆ្នាំ១៩៧៧ ហើយយ៉ាងទៅជាតំបន់ស្វយ័ត ចុង៧៦ ដើម៧៧ មក។ នេះការស្មានទេ ព្រោះខ្ញុំអត់ច្បាស់។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើខុសគ្នាដូចម្តេចអំពីតំបន់ជាផ្នែកនៅក្នុងភូមិភាគ ហើយតំបន់មួយជាតំបន់ស្វយ័ត។ តើវាខុសគ្នាដូចម្តេច?

**ឆ៖** តាមខ្ញុំគិតថា តំបន់-- បាទនៅក្នុងភូមិភាគ តំបន់ហ្នឹងត្រូវ រាល់ការងារត្រូវទាក់ទងជាមួយ

ភូមិភាគផ្ទាល់។ ឯតំបន់ស្វយ័តគឺទាក់ទងជាមួយនឹងមជ្ឈិមផ្ទាល់ ជាមួយថ្នាក់លើ។ ឡើងមកភ្នំពេញតែម្តងមិនបាច់ចាំទៅភូមិភាគ។

[១០:១៨:៥៣]

**ស៖** សូមអរគុណលោកសាក្សី។ សហព្រះរាជអាជ្ញាជាតិ ហើយខ្ញុំបានសួរលោកមួយចំនួនអំពីទង់បដិវត្ត ហើយខ្ញុំចង់សួរសំណួរមួយចំនួនដើម្បីបំភ្លឺ។ តើលោកនៅចាំទេនៅឆ្នាំណា នៅពេលដែលលោកបានឃើញទស្សនាវដ្តីទង់បដិវត្តដែលគេបោះពុម្ពផ្សាយ ដែលបានចែកនោះ ជាពិសេសអ្វីដែលខ្ញុំចង់ដឹងនោះគឺ តើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬនៅក៏មុនហ្នឹង ឬក៏មុនថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥ នោះមានដែរ?

**ឆ៖** ខ្ញុំ ការចងចាំរបស់ខ្ញុំដូចជាមិនច្បាស់លាស់បាទ។ បើខ្ញុំច្បាស់ គឺក្រោយយើងរំដោះ ១៧ មេសា ៧៥ គឺខ្ទង់ហ្នឹង មានក្រោយហ្នឹងទេ បើតាមខ្ញុំ-- ព្រោះខ្ញុំអត់ច្បាស់ដែរត្រង់ហ្នឹង។

**ស៖** ហើយខ្ញុំចូលទៅប្រធានបទមួយផ្សេងទៀត តើលោកអាចប្រាប់ខ្ញុំបានទេ នៅពេលណាដែលខេត្តក្រចេះត្រូវបានរំដោះដោយខ្មែរក្រហម? តើលោកនៅចាំទេ ខេត្តក្រចេះហ្នឹងកម្ពុជាប្រជាធិបតេយ្យគេរំដោះនៅពេលណា?

**ឆ៖** ភូមិភាគឦសានគឺ ពិសេសគឺខេត្តក្រចេះៗ នេះគឺក្រោយរដ្ឋប្រហារ ១៨ មេសា(ស៊ីក) ១៩៧០ ប្រហែលជាបានពីរខែប៉ុណ្ណឹងយ៉ាង តាមខ្ញុំវាមិនច្បាស់ដែរ ទីក្រុងក្រចេះគឺត្រូវរំដោះ។ ពួកខាងទាហាន លន់ នល់ នេះរត់ចោលខេត្តអស់ហើយ អត់មាននៅសល់ទេ។ ដូច្នេះគឺខ្មែរក្រហមកាន់កាប់តាំងពីពេលនុ៎ងមក។

**ស៖** នៅពេលដែលខ្មែរក្រហមបានកាន់កាប់នៅខេត្តក្រចេះនោះ តើគេអនុញ្ញាតឲ្យប្រជាជនរស់នៅក្នុងទីក្រុង និងទីប្រជុំជនដែរឬទេ? ឲ្យគេ-- ឲ្យពួកប្រជាជនដំណើរការទីផ្សារលក់ដូរមុខរបរធម្មតាដែរឬទេ?

[១០:២១:៣៦]

**ឆ៖** នៅពេលរំដោះហើយនៅឆ្នាំ១៩៧០ ទីផ្សារនៅមានធម្មតា អត់មានបញ្ហាអីទាំងអស់។ បាទ ដំណើរការរកស៊ីអី អ្នកណារកអីរកទៅ។ បាទ មានបញ្ហាចោទ ចោទតែបញ្ហាដឹកទំនិញចុះឡើង វាពិបាកអីចឹងបងប្អូនយើងត្រូវធ្វើដំណើរតាមកង់ទៅ ខ្លះទៅខាងកំពង់ធំ ខ្លះទៅខាងស្នួល ដឹកតាមកង់ មានការលំបាកប៉ុណ្ណឹង ឯកាណូតអត់បានទេ ព្រោះខ្លាចគ្រាប់។ ពិសេស គ្រាប់ខាង លន់ នល់។

**សៈ** តើលោកនៅចាំដែរឬទេនៅពេលដែលបក្ស-- មេដឹកនាំបក្សហ្នឹងចាប់អារម្មណ៍ ឬក៏យកចិត្តទុកដាក់អំពីថាផ្សារហ្នឹងគួរឲ្យដំណើរការ ឬគួរបិទនៅក្រចេះហ្នឹង។ តើលោកនៅចាំទេ?

**ឆៈ** ខ្ញុំអត់បានចាំដែរបញ្ហាហ្នឹង។

**លោក ខេល លីសាក់៖**

លោកប្រធាននៅពេលនេះ ខ្ញុំចង់បានការអនុញ្ញាតដើម្បីបង្ហាញទង់បដិវត្តមួយជូនលោកសាក្សីដែលឲ្យលោកបញ្ជាក់គឺចុះក្នុងខែសីហា ឆ្នាំ១៩៧៥ ជាទង់បដិវត្តមួយគឺឯកសារ E3/5 ហើយសេចក្ដីដកស្រង់ដែលខ្ញុំចង់សួរទៅសាក្សីនោះគឺនៅខ្មែរ ERN 00063316, ERN អង់គ្លេសនោះគឺ 00401480 រហូតទៅដល់ 81, បារាំង ERN 00538956។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ មុននឹងខ្ញុំបន្ត។

[១០:២៣:៤៩]

**សួរដោយលោក ខេល លីសាក់៖**

**សៈ** សូមលោកសាក្សី ខ្ញុំនឹងជូនឯកសារលើក្រដាស។ តើលោកអាចអានបានទេ ឬក៏លោកចង់ឲ្យខ្ញុំអានជូនលោកស្ដាប់បាទ?

**លោក យុន គីម៖**

**ឆៈ** ខ្ញុំអាចអានបានដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ។

[១០:២៥:០០]

**សួរដោយលោក ខេល លីសាក់៖**

**សៈ** ទំព័រដែលខ្ញុំត្រូវសួរលោកនោះ គឺទំព័រជាភាសាខ្មែរ 63361 ហើយមុននឹងចូលទៅទំព័រនោះ សូមឲ្យលោកមើលនៅក្របខាងមុខបន្តិចទៅ ហើយសូមលោកជម្រាបមកខ្ញុំវិញ។ ថាតើក្របមុខនៃក្រុមបដិវត្តន៍នេះ ដែលលោកបានឆ្លើយជូនទៅនឹងសហព្រះរាជអាជ្ញាជាតិពីមុននោះ។

**លោក យុន គីម៖**

**ឆៈ** បាទ ហ្នឹងឯកសារហ្នឹង។

**ស៖** ផ្នែកមួយនៃទស្សនាវដ្ដីទង់បដិវត្តនេះ គឺមានសេចក្ដីដូចតទៅនេះ សម្រង់៖ "ផ្សារក្រចេះនៅប្រហែលតែជំនាន់ចាស់ដដែល"។ ហើយខ្ញុំសូមចាប់បន្តទៅទៀត។ លោកបានរៀបរាប់ឆ្នាំ១៩៧១ នៅក្នុងផ្នែកមួយនៃទង់បដិវត្តនេះ ដែលថា៖ "ផ្សារក្រចេះនៅប្រហែលតែជំនាន់ចាស់ ហុងដារិន ឡើងរឹងចុះ ឯឈ្មួញយើងខោមិនអាចមិនអាវ ដើរក្ដីសៗបានសេចក្ដីថា វានៅធ្វើម្ចាស់នៅឡើយ។ ឯយើងវិញនៅធ្វើប៉ូលិសដូចជំនាន់សីហនុ ជំនាន់អានល់។ ដូច្នេះពាណិជ្ជកម្មនេះ បម្រើជីវភាពប្រជាជនអត់បាន បម្រើសង្គ្រាមរបស់ជាតិអត់បានទេ។ ឃើញច្បាស់ដល់កណ្ដាលឆ្នាំ៧៣ យើងចេញមិនរួចទេ ប្រមូលប្រជាជនអត់បានទេ គឺឈ្មួញធ្វើម្ចាស់។ វាចែកនេះ ចែកនោះឲ្យប្រជាជនខាងសម្ភារៈពាណិជ្ជកម្ម តាមផ្លូវនេះទៀត យើងចេញមិនរួចទេ"។ បញ្ចប់ការដកស្រង់។ តើត្រង់ចំណុចនេះអាចជួយរំឭកទៅដល់លោកថា នៅពេលនោះគឺថា បក្សមានការព្រួយបារម្ភដែលថាផ្សារនៅក្រចេះនេះ គឺថានៅតែបើឲ្យដំណើរដដែលនោះ?

[១០:២៧:៣៥]

**ឆ៖** ចំពោះបញ្ហាផ្សារក្រចេះឲ្យនៅដំណើរការដដែលនេះ គឺខាងខ្ញុំនេះអត់ដែលបានទទួលការណែនាំពីបញ្ហាផ្សារផងដែរទេ ព្រោះខ្ញុំនៅជនបទឆ្ងាយ។

**ស៖** តើនៅចាំបានទេ នៅពេលណាមួយដែលផ្សារទាំងអស់នៅក្រចេះ រួមទាំងផ្សារនៅក្នុងឃុំរបស់លោក លោកនៅចាំពេលដែលថាផ្សារទាំងអស់នោះត្រូវបានបិទដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំអត់បានចាំច្បាស់ ព្រោះនៅខាងឃុំរបស់ខ្ញុំនេះ អត់មានទីផ្សារ ប៉ុន្តែខ្ញុំគ្រាន់តែគិតថា នៅពេលដែលឈប់ចាយលុយ ប្រហែលជាឆ្នាំ១៩៧៤ យើងអត់មានការចាយលុយដូចមុនទៀតទេ។ ប៉ុន្តែខាងពាណិជ្ជកម្មដោះដូរ គឺនៅមានៗ ឧទាហរណ៍ថា នៅដូចខាងស្រុកអីគេមានរបស់របរដោះដូរជាមួយប្រជាពលរដ្ឋដែរ ដូចជា ថ្នាំពេទ្យ ដូចជាស្ករអីចឹង នៅមាន។ ឯទីផ្សារបិទថ្ងៃណា ឈប់ថ្ងៃណា អីហ្នឹងខ្ញុំអត់បានច្បាស់លាស់។ ប៉ុន្តែខ្ញុំគិតថា នៅពេលដែលអស់លុយ ទីផ្សារហ្នឹងវាត្រូវថយ ថយចុះហើយ។

[១០:២៩:២៤]

**ស៖** តើលោកចាំទេ ថាហេតុអ្វីបានជាគេបញ្ជប់ឲ្យមានចរាចរសាច់ប្រាក់នៅក្នុងខេត្តក្រចេះក្នុងឆ្នាំ១៩៧៤ នោះ?

**ឆ៖** បញ្ហានេះខ្ញុំក្ដាប់អត់បានច្បាស់លាស់ដែរ បាទ។ គ្រាន់តែលុយលែងចាយ គឺចប់តែម្ដង។

ប៉ុន្តែមុននឹងឈប់ចាយលុយ គឺវាមានផលវិបាកព្រោះគេហួបរួម ស៊ីរួមអស់ទៅហើយ អ៊ីចឹងអត់មានអីចាយទៀត។ អ៊ីចឹងការចាយលុយបញ្ចប់នៅពេលដែលសហករណ៍កើតហ្នឹង។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក លោកសាក្សី។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យុន គីម គឺយើងបាន-- សហការីខ្ញុំបានសួរអំពីកិច្ចប្រជុំ ដែលលោកបាន

ចូលរួមក្នុងឆ្នាំ៧៣ ដែល នួន ជា ផ្តល់ការណែនាំអំពីសហករណ៍ ការបង្កើតសហករណ៍នោះ។ ខ្ញុំចង់សួរសំណួរមួយចំនួន ទាក់ទងទៅនឹងអង្គប្រជុំនោះ។ តើអង្គប្រជុំ ដែលលោកចូលរួមជាមួយលោក នួន ជា នោះគឺមានរយៈពេលប៉ុនណាដែរ?

**លោក យុន គីម៖**

**ឆ៖** រយៈពេលដែលខ្ញុំចូលរួមប្រជុំជាមួយលោក នួន ជា នៅឆ្នាំ១៩៧៣ នៅភូមិដារនេះគឺ រយៈពេលមួយថ្ងៃពេញបាទ ពីព្រឹកដល់ល្ងាច។

**ស៖** ហើយសក្ខីកម្មដែលលោកបានផ្តល់ជូនពីព្រឹកមិញនេះគឺ លោករៀបរាប់អំពីការញែកឲ្យដាច់ពីគ្នារវាងក្រុមប្រវាស់ដៃ និងសហករណ៍កម្រិតទាប និងសហករណ៍កម្រិតខ្ពស់។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើក្រុមប្រវាស់ដៃ ហើយនិងសហករណ៍កម្រិតទាប និងកម្រិតខ្ពស់នោះវាមានលក្ខណៈបែបណាដែរ?

[១០:៥៥:៤៨]

**ឆ៖** អឺ! ការបែងចែកជាបីផ្នែក គឺមានក្រុមប្រវាស់ដៃ ក្រុមសហករណ៍កម្រិតទាប និងសហករណ៍កម្រិតខ្ពស់ មានភាពខុសគ្នា។ គឺក្រុមប្រវាស់ដៃគឺ ប្រមូលប្រជាពលរដ្ឋយើង ប្អូនដប់ ឬដប់ប្រាំគ្រួសាររួមគ្នាធ្វើការងារជាមួយ តែអត់មានដាក់សម្ភារៈអីរួមទេ គ្រាន់ថាលើកវេរជួយគ្នាទៅវិញទៅមក។ បាទ នេះក្រុមប្រវាស់ដៃ ឯភោគផលគឺធ្វើដីរៀងខ្លួន បាទអត់មានបែងចែកអីទេ។

ឯសហករណ៍កម្រិតទាបនេះ តាមការណែនាំគឺគាត់បានថា ឲ្យបងប្អូនខ្លះគេមានដីគួរសមដែរ ពួកនេះគឺគេមានសម្ភារៈអី អ្នកខ្លះក៏គ្មានគោ គ្មានក្របី ប៉ុន្តែភាគច្រើនគឺមាន គេរួមគ្នាធ្វើទៅ។ ដល់បែងចែកនៅលើការឯកភាពគ្នា ពិសេសគឺដូចថាដកគោប៉ុន្មានទៅ ហើយដកតាមកម្លាំងពលកម្មទៅ។ នេះគឺតាមការណែនាំអឺចឹង។

[១០:៥៦:៥៥]

ឯសហករណ៍កម្រិតខ្ពស់ គឺយើងបញ្ចូលឧបករណ៍ទាំងអស់។ បាទ មានដីក៏យើងដាក់រួមគ្នា មានគោក្រី រទេះសាឡីហ្នឹងក៏រួមគ្នា ហើយធ្វើទាំងអស់គ្នា។ ឯដល់បែងចែក គឺយើងបែងចែកទៅតាមកម្លាំងពលកម្ម។ នេះគឺសហករណ៍ កម្រិតខ្ពស់គឺអឺចឹង។ ប៉ុន្តែ ជាក់ស្តែងនៅក្នុងឃុំដែលខ្ញុំនៅនេះ អត់បានធ្វើសហករណ៍កម្រិតទាប កម្រិតខ្ពស់ ឬប្រវាស់ដៃទេ ពីព្រោះពេលនោះឈ្មោះ ចែត ដែលជាលេខាបក្សស្រុក គាត់បញ្ជាឲ្យធ្វើសហគមន៍ទាំងអស់តែម្តង។ ដូច្នេះ ខ្ញុំសូមជម្រាបការងារនេះប៉ុណ្ណឹង។

[១០:៥៧:៥៦]

**សៈ** គំនិតថ្មីដែល ចែត បានយកមកបង្ហាញនោះ តើលោកយល់ទេ? លោកយល់ថា តើវាមកពីគោលនយោបាយមជ្ឈិមបក្ស ឬក៏វាជាគំនិតមួយដែលឈ្មោះ ចែត នេះគាត់បានផ្តួចផ្តើម ដោយខ្លួនឯងផ្ទាល់តែម្តង?

**ឆះ** នៅពេលនោះ ខ្ញុំបានមានយោបល់ដែរ ព្រោះពេលប្រជុំហ្នឹង លោក នួន ជា ប្រជុំនៅភូមិដារចប់ហើយ ដល់ទៅដល់លោក ចែត ប្រាប់ថា មិនឲ្យកុំអាលទៅមូលដ្ឋានវិញ នាំគ្នាទៅជួបជុំគ្នានៅសំបូរ។ ដល់ទៅជួបជុំគ្នានៅសំបូរហ្នឹង គាត់ថា យើងអត់ធ្វើសហករណ៍កម្រិតទាប កម្រិតខ្ពស់ ឬប្រវាស់ដៃទេ នៅស្រុកយើងគឺត្រូវតែធ្វើសហគមន៍ទាំងអស់គ្នា។ បើ-- គាត់ថា ពេលនោះគាត់និយាយថា បើសមមិត្តណាមិនហ៊ានចាត់តាំង អ៎! មិនហ៊ានឃោសនា ចាំគាត់ទៅឃោសនា ឲ្យទៅចាត់តាំងទៅឲ្យទៅរៀបចំធ្វើជាសហគមន៍ហ្នឹងទៅ ប៉ុន្តែឯការឃោសនាចាំគាត់ទៅឃោសនា។ គាត់ធ្វើអ៊ីចឹង ហើយពេលនោះ ខ្ញុំមានយោបល់ដែរ ខ្ញុំថា អ៊ីចឹងមិន-- ខ្ញុំមាត់របុិលរប៉ូចដែរ ខ្ញុំថា អ៊ីចឹងមិនខុសពីថ្នាក់លើហើយ បើថ្នាក់លើណែនាំអ៊ីចេះ គាត់ទៅធ្វើអ៊ីចុះ។ គាត់ថា អ្ហែ៎ស្រេចតែគាត់។ ដល់អ៊ីចឹង ខ្ញុំគិតថា គំនិតតាចែត នេះគឺមិនល្អជាមួយថ្នាក់លើទៅហើយ ប៉ុន្តែដោយខ្លាចអំណាចគេ គឺចេះតែអនុវត្តតាមទៅ។

[១០:៥៩:៣៤]

ដូចនៅឃុំខ្ញុំគឺ ខ្ញុំបានណែនាំប្រជាពលរដ្ឋថា បើថាថ្នាក់លើ-- បើតាចែត គេចុះមកគេថាម៉េចក៏ដោយ យើងនាំគ្នាមិនបាច់ប្រតិកម្មអីទេ ធ្វើយ៉ាងម៉េចឲ្យយើងនៅក្នុងសហគមន៍ហ្នឹងសាមគ្គីគ្នាទៅ។ ដល់អនុវត្តជាក់ស្តែង ពួកយើងទេអ្នកធ្វើ។ ដល់អ៊ីចឹងថ្ងៃមួយនោះ តាចែត មកដល់ហ្នឹង លែងពីម៉ោង ៦ព្រឹក បាទម៉ោង៦មិនទាន់ហ្នឹងភ្លឺ គាត់ទៅទេសនាបណ្តោយ បើពីណាមកមិនទាន់ទេរើបណ្តោយ រើខ្លាំងៗថ្ងៃនុំង ប្រជាជនដូចជាស្ងន់ស្ងោដែរ។ ប៉ុន្តែដល់ក្រោយមកខ្ញុំបានសម្រួលទៅ ក៏មិនប្រតិកម្មអីធំដុំទេ។ បាទ អ៊ីចឹងឃើញថា តាចែត ហ្នឹងគាត់ដំណើរការមិនល្អនៅចំពោះមាគ៌ាដែលថ្នាក់លើណែនាំ បាទ។ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

[១១:០០:៣៣]

**សៈ** តើមានអ្វីកើតឡើងដល់តាចែត នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆះ** តាចែត នេះឈ្មោះដើមគាត់ ឈឹម យួង ហើយខ្ញុំ តាមខ្ញុំដឹងថ្នាក់លើគឺផ្លាស់គាត់ពីសំបូរមកនៅក្រចេះ ដោយសារសីលធម៌ បាទសីលធម៌នារី ព្រោះគាត់មានសីលធម៌អត់ល្អចំពោះនារី។ គាត់

មានបន្ទប់សម្ងាត់គាត់ហ្នឹងមិនដឹងប៉ុន្មានកន្លែងទេ ខ្ញុំក្ដាប់អត់បានដែរ។ នៅលើកោះត្នោតក៏មាន នៅកំពង់លើក៏មាន បន្ទប់សម្ងាត់នោះសម្រាប់ធ្វើការងារជាមួយនារី។ ដោយសារបញ្ហានារីហ្នឹងហើយ ក្នុងនោះក៏មាននារីស្លាប់ដូចជា អ្នកគ្រូមួយនោះគាត់ទទួលខាងអប់រំស្រុកនៅឆ្នាំ១៩៧៣, ៧៤, ៧២អីហ្នឹងគាត់-- ហើយគាត់ច្របាច់កស្លាប់ក្នុងទឹក។ ខ្ញុំមិនដឹងស្លាប់ឆ្នាំណាទេ ប៉ុន្តែគ្រាន់ដឹងថា អ្នកគ្រូនោះគាត់ស្លាប់។ ប៉ុន្តែគេថា អ្នកគ្រូហ្នឹងក៏ខូច តាចែត ហ្នឹងរំលោភលើដែរ។ ហើយដោយសារអ៊ីចឹងហើយបានខាងខេត្តដកគាត់មកនៅក្រចេះ ដល់មកនៅក្រចេះ ក្រោយមកឮថាគេចាប់ខ្លួនគាត់ ពីព្រោះតែអារឿងសីលធម៌ហ្នឹងដែរ។ នេះខ្ញុំបានដឹងអ៊ីចឹង។ ហើយដល់ក្រោយមកទៀត ឮអ្នកភូមិខ្ញុំថា ន៎!ជួបតាចែតនៅឯណា ឯតាម៉ៅ ក្រហម-ក ឯណាខាងស្រុកព្រែកប្រសប់នោះ ថាបែបដូចគេចាប់ក៏មិនដឹង អីមិនដឹងរួចខ្ញុំអត់ច្បាស់។ បាទ ខ្ញុំសូមមានយោបល់ប៉ុណ្ណឹង។

[១១:០២:១៦]

**ស៖** តើក្រោយពេលដែលគេបញ្ជូនគាត់ទៅក្រចេះនោះ តើលោកមានបានជួប តាចែត ម្ដងទៀតទេក្រោយមក?

**ឆ៖** ក្រោយពីគេបញ្ជូនគាត់ទៅក្រចេះ ខ្ញុំបានជួបម្ដង ប៉ុន្តែអត់បាននិយាយគ្នាទេ ថ្ងៃហ្នឹងគឺធ្វើបុណ្យរំឭកខួបជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៦។ បាទ បុណ្យខួបទីមួយនៃការរំដោះឆ្នាំ៧៦ហ្នឹង។ បាទ ជួបម្ដង ប៉ុន្តែអត់បានជួបនិយាយទេ គ្រាន់តែទៅជួបឃើញគាត់នៅលើវេទិកា។ បាទ ម្ដងហ្នឹង។

**ស៖** តើ តាចែត នេះត្រូវបានគេចាប់ខ្លួន ហើយបាត់ខ្លួននេះតើនៅក្នុងឆ្នាំណាដែរ?

**ឆ៖** មិនច្បាស់លាស់ទេ ប៉ុន្តែតាមខ្ញុំស្មានប្រហែលឆ្នាំ១៩៧៦។ បាទ ក្រោយពីបុណ្យហ្នឹងរួចបន្តិចទៅ ឮគេថា បាត់ខ្លួនតាចែត ហ្នឹងហើយបាទ។

[១១:០៣:៤០]

**ស៖** ត្រឡប់ទៅការប្រជុំរបស់លោកជាមួយលោក នួន ជា នៅក្នុងឆ្នាំ១៩៧៣។ តើលោក នួន ជា មានផ្ដល់ការណែនាំអ្វីដែរ ថាតើត្រូវចែករំលែកៗរបបអាហារហ្នឹង ដោយរបៀបម៉េចដែរនៅក្នុងសហករណ៍ហ្នឹង?

**ឆ៖** ពេលដែលជួបហ្នឹង គាត់គ្រាន់ណែនាំឲ្យធ្វើប្រវាស់ដៃ សហករណ៍កម្រិតទាប កម្រិតខ្ពស់ ហើយគាត់បានបញ្ជាក់ទៀតថា ដាច់ខាតកុំឲ្យធ្វើសហគមន៍។ បាទ ឯការបែងចែងកហ្នឹងគឺទៅតាមសភាពជាក់ស្ដែងនៅអង្គភាពមួយៗ។ សំខាន់ គាត់ថាសំខាន់គឺឲ្យតែគេពិគ្រោះគ្នាយ៉ាងម៉េចស្រួល កុំឲ្យ

តែវាមានទំនាស់ ជាបញ្ហាល្អ។ ប៉ុន្តែគ្រាន់ថា បែងចែកទៅតាមកម្លាំងពលកម្មជាមូលដ្ឋាន ប៉ុន្តែចៀសវាងធ្វើម៉េចកុំឱ្យនៅក្នុងសហករណ៍ហ្នឹងវាមានបញ្ហា។ ហ្នឹងខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** នៅក្នុងពេលប្រជុំមួយថ្ងៃជាមួយលោក នួន ជា ហ្នឹង តើមានកម្មវត្ថុអ្វីក្រៅពីការបង្កើតសហករណ៍ដែរឬទេ? ឧទាហរណ៍ដូចជាការបន្តធ្វើសង្គ្រាមជាមួយរបប លន់ នល់ ជាដើមនោះ តើមានប្រធានបទអ្វីថ្មីក្រៅពីហ្នឹងទេ?

[១១:០៥:១៥]

**ឆ៖** បញ្ហាពាក់ព័ន្ធនឹងសង្គ្រាមជាមួយ លន់ នល់ បញ្ហានេះ គឺគាត់បានណែនាំតែចូលទៅដំបូង គឺណែនាំពីសភាពការណ៍។ សភាពការណ៍វាយខ្លាំង ហើយនិងទិសដៅរបស់យើង គឺដំណើរការវាមានការជឿនលឿន វារីវឌ្ឍន៍ទៅមុខ ហើយយើងពិតជារំដោះប្រទេសជាតិអីអ៊ីចឹង គាត់បានណែនាំអ៊ីចឹង។ ប៉ុណ្ណឹង អត់មានបញ្ហាអីទៀតទេ ហើយព្រោះថ្ងៃនោះ គឺថ្ងៃសំខាន់នៃការដែលចង់រៀបចំឱ្យសហករណ៍នៅក្នុងសង្គមកម្ពុជាហ្នឹង។

**ស៖** នៅពេលដែលគាត់និយាយអំពីការវាយប្រហារខ្មាំង តើខ្មាំងហ្នឹង ជាអ្នកណា?

[១១:០៦:១០]

**ឆ៖** ខ្មាំង សត្រូវនៅពេលនោះ គាត់ចង់បញ្ជាក់អំពី លន់ នល់ បាទ។ កម្លាំងរបស់ពួក លន់ នល់ ហ្នឹង ដែលមានអាមេរិកនៅពីក្រោយខ្នង។

**ស៖** តើលោកដឹងថា លោក នួន ជា បានទៅខេត្តក្រចេះញឹកញាប់ទេ មុនឆ្នាំ១៩៧៥ នោះ?

**ឆ៖** ពាក់ព័ន្ធនឹងការអញ្ជើញរបស់លោក នួន ជា ទៅខេត្តក្រចេះនេះ ខ្ញុំអត់បានដឹងទេ កន្លងមក។ ដឹងតែថ្ងៃពេលដែលមកប្រជុំហ្នឹង។ ខ្ញុំដឹងប៉ុណ្ណឹងបាទ។

**ស៖** ទោះបីជានោះជាពេលតែមួយ ដែលលោកជួបជាមួយគាត់ដោយផ្ទាល់ ក៏ប៉ុន្តែតើលោកធ្លាប់បានឮ ថាគាត់បានទៅកាន់ខេត្តក្រចេះនៅពេលមុនៗនោះដែរឬទេ?

**ឆ៖** ខ្ញុំ-- បញ្ហានេះ ខ្ញុំអត់បានដឹងដែរ។ អត់ដែលបានឮពីអ្នកណាប្រាប់ ថាគាត់អញ្ជើញមកញឹកញាប់ ឬក៏យ៉ាងណានោះ។

**ស៖** សូមអរគុណលោក យុន គីម។ ឥឡូវនេះ យើងចូលទៅនិយាយអំពីការជម្លៀសប្រជាជនវិញម្តង។ មុនឆ្នាំ១៩៧៥ គឺ១៧ មេសា ១៩៧៥ តើមានការផ្លាស់ទីប្រជាជន ការជម្លៀសប្រជាជននៅខេត្តក្រចេះទេ ក្រៅពីទីរួមខេត្តក្រចេះដែរទេ? តើមានការជម្លៀសប្រជាជនចេញ ក្រៅពីទីរួមខេត្តក្រចេះ

ដើម្បីទៅកាន់សហករណ៍ដទៃទៀតៗ នៅក្នុងប្រទេសនោះដែរឬទេ?

[១១:០៨:៣០]

**ឆ៖** បញ្ហាជម្លៀសប្រជាជនពីខេត្តក្រចេះ ទៅតំបន់ផ្សេងៗ ខ្ញុំអត់បានដឹងដែរ។ ពីព្រោះដូចជានៅឃុំរបស់ខ្ញុំនេះ ក៏អត់ដែលមានផ្លាស់ទៅណា។ ព្រោះប្រជាជនរស់នៅត្រង់ណា រស់នៅកន្លែងហ្នឹងអត់មានផ្លាស់ប្តូរ។ បាទ ដូចជាមានបងប្អូនជនជាតិចាម ដែលទៅនៅខាងឃុំ កាលខ្ញុំនៅវឌ្ឍនៈអីហ្នឹងហ្នឹងថាទៅពីខាងបូព៌ា ប៉ុន្តែមិនដឹងចេញពីស្រុកណាទេ។ ប៉ុនដល់រួចដឹងថា ពួកហ្នឹងនៅអី ខាងដកស្វាយកាំបិតអី ខាងអី ដល់សួរទៅ។ ហើយចំពោះប្រជាជនៅក្នុងទូទាំងខេត្ត ខ្ញុំក្តាប់អត់បាទ អត់ដឹងជាមានជម្លៀសទៅណា មកណា។

[១១:០៩:៣១]

**ស៖** នៅថ្ងៃ១៧ មេសា ៧៥ តើលោកនៅទីណាដែរពេលនុ៎ង?

**ឆ៖** នៅថ្ងៃទី១៥-- អ៊ំ ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំរស់នៅក្នុងឃុំវឌ្ឍនៈបាទ។

**ស៖** តើនៅពេលណាដែលលោកបានស្តាប់ឮអំពីផែនការរបស់បក្ស ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងតាមចេញពីបណ្តាទីរួមខេត្តផ្សេងៗទៀត? តើលោកបានដឹងជាលើកដំបូងនៅពេលណាដែរ?

**ឆ៖** ពាក់ព័ន្ធនឹងការជម្លៀសប្រជាពលរដ្ឋនេះ គឺខ្ញុំបានដឹងនៅពេលដែលឃើញមានអ្នកថ្មីៗទៅដល់កន្លែងដូចថា ខ្ញុំនៅសំបូរអីចឹង ស្រាប់ឃើញមានមនុស្សមកបន្តបន្ទាប់គ្នា ជិះកតាមកាណូត ជិះកតាមអីមកហ្នឹង គេសួរថា-- អ៊ំ សួរគេថា គេនាំគ្នាទៅណាពួកហ្នឹង? គេថា គេជម្លៀសមកបាទ។ អីចឹងឃើញថាមានគេជម្លៀសអ្នក១៧មេសា តាមកាណូត តាមអីមក មកដល់កន្លែងបណ្តោយ មិនដឹងជា-- ហើយការជម្លៀសនេះមិនដឹងជាមានពីពេលណាមកទៀតទេ ខ្ញុំក្តាប់អត់បានដែរ។

[១១:១១:១០]

**ស៖** ឥឡូវនេះយើងចូលទៅនិយាយអំពីអំឡុងពេលឆ្នាំ១៩៧៥ នៅពេលដែលលោកជាប្រធានឃុំវឌ្ឍនៈ តើលោកបានដឹងថាមានប្រជាជន គេជម្លៀសទៅដល់ឃុំវឌ្ឍនៈដែរឬទេ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបអំមិញអីចឹងគឺ នៅឆ្នាំ៧៥ ហ្នឹងឃើញចាម ជនជាតិអ៊ីស្លាមហ្នឹងមួយចំនួនទៅនៅវឌ្ឍនៈហ្នឹង តាមស្មានពេលនោះប្រហែលជា៣០ ទៅ៤០គ្រួសារ។ ហើយសួរថាមកពីខាង

ណា ថាមកពីខាងភូមិស្វាយកាំបិត បែបខាងដំបែរ ខាងអីហ្នឹង។ ស្វាយកាំបិត បែបនៅខាងហ្នឹងក៏មិនដឹង នៅត្រង់ណាមិនដឹង ខ្ញុំក្ដាប់អត់បានដែរ។ ហើយដល់មក យើងក្រោយរំដោះហើយទេ បានឃើញពេលខ្ញុំទៅនៅសំបូរ បានឃើញបងប្អូនយើងនៅហ្នឹងសំបូររួចទៅហើយ បងប្អូន១៧ មេសា ដែលជម្លៀសមកពីក្រុងភ្នំពេញ ក្រុងអីហ្នឹងបាទ។ ឃើញនៅនឹងសំបូរស្រាប់។ ហើយដល់ក្រោយមកទៀតក៏មានដែរ មានបងប្អូនមកពីតាម៉ូង បាទគេជម្លៀសមក អាហ្នឹងមកដល់៧៨ ចុង៧៧ និងដើម៧៨ បានមានអ្នកមកពីតាម៉ូងទៀត ថាមកពីខាងស្រុកមេមត់។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់បន្តិច គឺប្រជាជនថ្មីដែលលោកបានឃើញ ត្រូវបានជម្លៀសទៅកាន់ឃុំសំបូរនោះ គឺវានៅពេលដែលលោកបានទៅធ្វើជាប្រធានឃុំសំបូរហ្នឹង ឬក៏ប្រជាជននោះ គឺថាការជម្លៀសទៅកាន់ឃុំសំបូរហ្នឹង កើតមានមុនលោកទៅធ្វើជាប្រធានឃុំនោះរួចស្រេចទៅហើយ?

[១១:១៣:២២]

**ឆ៖** នៅពេលដែលខ្ញុំទៅធ្វើមេឃុំនៅសំបូរ ឃើញបងប្អូនយើង១៧ មេសា នៅហ្នឹងស្រាប់ហើយ។ បាទ ទៅមុខខ្ញុំ គេជម្លៀសមកមុនខ្ញុំទៅដល់។ អ៊ីចឹងឃើញ គ្រាន់គេដឹងថាអ្នក ពួកនេះពួកអ្នក១៧ មេសា ប៉ុន្តែអ្នកនៅសំបូរហ្នឹង ឃុំសំបូរហ្នឹងនៅក្បែរឃុំខ្ញុំដែរ ខ្ញុំស្គាល់ច្រើនដែរ ព្រោះអាចដឹងថាអ្នកនេះអ្នក១៧ មេសា អ្នកនេះស្រុកចាស់។

**ស៖** យើងនឹងនិយាយអំពីពេលដែលលោកក្លាយទៅជាប្រធានឃុំសំបូរនៅពេលក្រោយ។ ឥឡូវហ្នឹងខ្ញុំ-- នៅពេលក្រោយ ខ្ញុំនឹងសួរសំណួរមួយចំនួនបន្ថែមទៀត។ តែនៅពេលនេះ ខ្ញុំសូមចូលទៅប្រធានបទស្ដីអំពីការទំនាក់ទំនង និងការរាយការណ៍នៅក្នុងថ្នាក់តំបន់ និងថ្នាក់ស្រុក ក៏ដូចជាថ្នាក់ឃុំនៅក្នុងខេត្តក្រចេះនេះ។ តើលោកអាចប្រាប់មកខ្ញុំបានទេ នៅពេល ទោះបីជាលោកជាលេខាឃុំវឌ្ឍនៈក្ដី លេខាឃុំសំបូរក្ដី ថាតើលោករាយការណ៍ទៅដល់លេខាស្រុកអំពីការកិច្ចការរបស់ក្នុងឃុំរបស់លោកនោះដោយរបៀបណាដែរ?

[១១:១៤:៥៧]

**ឆ៖** ក្នុងរបបខ្មែរក្រហមនេះ គឺយើងជួបជុំគ្នាមួយអាទិត្យម្ដង។ បាទ ទោះជានៅឃុំឆ្ងាយ ក៏ដូចជា ឃុំជិតដែរ មួយអាទិត្យហ្នឹង គឺត្រូវតែជួបជុំគ្នាម្ដង។ យើងរាយការណ៍អំពី ទីមួយសភាពការណ៍ខ្មាំង បាទ បើឃុំណាមានសកម្មភាពអី មិន-- ដូចថាវាទំនាស់នឹងបដិវត្តន៍ហ្នឹងឲ្យរាយការណ៍ទៅ។ ហើយទីពីរ យើងរាយការណ៍អំពីសភាពការណ៍បង្កបង្កើនផល។ សភាពការណ៍បង្កបង្កើនផលហ្នឹង ជាសភាព

ការណ៍ដែលសំខាន់បំផុតក្នុងការរាយការណ៍ ហើយនិងទីបី គឺយើងរាយការណ៍អំពីសុខភាពប្រជាពលរដ្ឋ។ ហើយផ្នែករឬចម៏នេះ គឺក៏មានការរាយការណ៍ដែរ ប៉ុន្តែមានចំណែកណា ព្រោះការរៀនសូត្រនេះអស់មានតែត្រឹមថ្នាក់បី អត់មានទៅដល់ថ្នាក់ណាទៀតទេ។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។ ហើយយើងរាយការណ៍នេះ រាយការណ៍ជូននៅពេលនេះ គឺគណៈកម្មការស្រុកចូលរួម។ អ្នកដែលចូលរួមប្រជុំហ្នឹងគឺជួនកាលមានខាងឃុំនោះមានពីរនាក់ ជួនទៅមកម្នាក់ អត់ទៀង តាមតែការដាក់ផែនការឲ្យទៅពីព្រោះឧបមាប្រជុំមួយអាទិត្យហ្នឹងចប់ ណាត់គ្នាប្រជុំអាទិត្យក្រោយទៀត មិនបាច់ចាំមានសំបុត្រស្នាមទេ ដឹងតែថាដល់ថ្ងៃ គឺត្រូវតែមានមុខ។ នេះខ្ញុំសូមអស់មតិ។

[១១:១៦:៤៤]

**ស៖** ទាក់ទងទៅនឹងការរាយការណ៍របស់លោកអំពីស្ថានភាពខ្មាំង តើនៅពេលហ្នឹង លោកគិតថាអ្នកណាជាខ្មាំងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក្នុងពេលដែលលោកមានការប្រជុំជាមួយនឹងគណៈកម្មាធិការស្រុកនោះ?

**ឆ៖** ក្នុងរបបរាយការណ៍ប្រចាំសប្តាហ៍ ខ្ញុំតែងតែទទួលការទិតៀនពីថ្នាក់ស្រុក ពិសេសលើការរាយការណ៍អំពីសភាពការណ៍ខ្មាំង ពីព្រោះខ្ញុំពិបាករកដែរ រកខ្មាំងវាអត់ឃើញ ព្រោះឃើញតែប្រជាជនគ្នាភ័យខ្លាច ដឹងតែធ្វើការងារ ហើយខ្ញុំគិតថា បើសិនណាបុគ្គលមួយរាយការណ៍ទៅឲ្យគេថាបុគ្គលនេះ ធ្វើការរឡេះរឡោះ មិនច្បាស់លាស់ រាយការណ៍ថា អ្នកនេះធ្វើការមិនល្អអីអីចឹងទៅ វាធ្លាក់មកលើខ្លួនខ្ញុំ។ ខ្ញុំគិតថា បើសិនណារាយការណ៍អីចឹងទៅ បានន័យថាមកពីខ្ញុំហ្នឹងវាអប់រំគេមិនកើតអីចឹងអាសភាពការណ៍ខ្មាំងហ្នឹង ខ្ញុំពិបាករក រកមិនដែលឃើញនឹងគេ ច្រើននឹងគេទេ។ បើឃើញតិចតួចហ្នឹង ក៏ពិបាកដូចជាមិនដឹងជាមានអីទេ។ អីចឹងបានខ្ញុំថា តែរាយការណ៍សភាពការណ៍ខ្មាំងខ្ញុំរកខ្មាំងអត់ឃើញ ពីព្រោះអត់ដូចគេខ្លះ គេថា អាខ្លះខ្មាំងស្ទូងជំរាត់ដើម។ ខ្ញុំថា ជំរាត់ដើម ទាល់តែជន្លេនបានវាដឹងបើយើងនៅលើគោក ធ្វើម៉េចនឹងដឹង។ អីចឹងមានការលំបាក បាទ។ អីចឹងក្នុងការរាយការណ៍សភាពខ្មាំង ខ្ញុំមិនដែលមានខ្មាំងអីដែលរាយការណ៍ជូនទេ បើមានជួនកាល មានម្តងនោះ វាមានខ្មាំង គេថាមានឃើញមនុស្សដើរកាត់ក្រោយភូមិ ស៊ីស្លឹកថ្នឹងអី ពួករត់អីឯនោះម្នាក់ អាហ្នឹងរាយការណ៍បាន ប៉ុន្តែបើថាក្នុងប្រជាជន ខ្ញុំអត់ដែលទេ។ ពីព្រោះនៅ រស់នៅជាមួយខ្ញុំ ខ្ញុំអត់ចេះដែលរាយការណ៍ចោទប្រជាជនឯងនាំឲ្យគេចាប់ គេអីផង។ ដូចជាអ្នកធ្លាប់រស់នៅជាមួយខ្ញុំ អ្នកនៅភ្នំពេញនេះក៏មានច្រើនដែរ។ សូម្បីតែលោកប្រធានអាជហុកនេះ លោក ធន់ សាវ៉ាយ នេះ លោកឈ្មោះ ហួរ អង្គាល់នៅជាមួយខ្ញុំ។ បាទ រួច

បើសិនណាជាក្រៅពីជាមួយខ្ញុំទៅអស់ហើយ។ នៅជាមួយខ្ញុំសូម្បីតែចាងហ្វាងសាលាដំបូងពីដើម លោក តាហម ក៏គាត់រស់-- ទើបតែគាត់ស្លាប់ឆ្នាំទៅដែរ ពីព្រោះគេឲ្យយកហើយ ខ្ញុំតស៊ូបានដែរ រក្សាគាត់បាន លើកលែងតែ តាឈើ មួយ។ តាឈើ គាត់ពួកម៉ាក-- អ្វីជាឪពុកពួកម៉ាកខ្ញុំផង។ រួចខ្ញុំអត់ដឹងរឿងដំបូង បើខ្ញុំដឹងរឿង ក៏ខ្ញុំជួយទប់បានដែរ។ បាទ អ៊ីចឹងបានន័យថាកន្លងមកនេះ ខ្ញុំមិនដែលបានរាយការណ៍អីអាក្រក់ពីប្រជាពលរដ្ឋទេ។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១១:១៩:៥០]

**សៈ** តើប្រធានឃុំដទៃទៀត ត្រូវរាយការណ៍អំពីស្ថានភាពខ្មាំងនៅឃុំរបស់ពួកគាត់នៅក្នុងពេលប្រជុំបែបនេះដែរឬទេ?

**ឆៈ** កន្លងមកនេះ គឺនៅឃុំផ្សេងៗទៀតគឺមាន មានគេរាយការណ៍ខ្មាំងអ៊ីចេះ ខ្មាំងអ៊ីចុះ ប្រជាពលរដ្ឋអ្នកខ្លះនិយាយអ៊ីចេះ អ្នកខ្លះនិយាយអ៊ីចុះ បញ្ហានេះហើយដែលមានប្រជាពលរដ្ឋមួយចំនួនដែលត្រូវជាប់ឃុំឃាំងបាទ នៅក្នុងឃុំផ្សេងៗ។ ហើយការរាយការណ៍នេះជាការមួយដែលស្លាប់ សូម្បីតែមេឃុំខ្លួនឯងហ្នឹងក៏ងាប់បន្តបន្ទាប់ដែរ។ ជាក់ស្តែងដូចនៅក្នុងឃុំសំបួរ ដូចជាគ្មានឃុំណាមួយមិនទទួលគេចាប់ទេ។ ជាក់ស្តែងដូចនៅក្នុងឃុំវឌ្ឍនៈដែលខ្ញុំនៅអ៊ីចឹង ខ្ញុំចេញផុតទៅឡើងលោក អ៊ុង សាម៉ុន។ លោក អ៊ុង សាម៉ុន នេះគាត់ជាប្រធានសន្តិសុខស្រុក គេឲ្យទៅធ្វើមេឃុំនៅវឌ្ឍនៈ ផ្លាស់ខ្ញុំមកនៅធ្វើមេឃុំសំបួរ បានបន្តិចគេចាប់លោក អ៊ុង សាម៉ុន ទៅ។

[១១:២១:០៣]

ដល់លោក អ៊ុង សាម៉ុន ហ្នឹងត្រូវគេចាប់ទៅ គេឲ្យលោក ជួន អឺ! លោក គិន ជួន ហ្នឹងជាមួយលោក ជា ឈើន មកធ្វើឃុំហ្នឹងបន្ត បានបន្តិចទៅគេចាប់ពីរនាក់ហ្នឹងទៅទៀតទៅ គេឲ្យលោក អៀង មកទៀត ដល់បន្តិចគេចាប់លោក អៀង ហ្នឹងទៅទៀត។ បានគេដកលោក ប៉េន ឯនោះពីៗស្រែរុងពីកន្លែងការដ្ឋាន ប-៣ ជាមួយខ្ញុំមកឲ្យធ្វើមេឃុំ ហើយគាត់ក៏ត្រូវងាប់ទៀតនៅពេលដែលធ្វើរវត់៧៩ ហើយហ្នឹង ប្រជាជនវៃគាត់ងាប់ទៅ។ បាទ អ៊ីចឹង ហើយឃុំផ្សេងៗទៀតដូចជា ឃុំកំពង់ចាម ក៏ងាប់ ឃុំបឹងចារ ក៏ងាប់ ៗទាំងគណៈៗបាទ មិនដឹងជាមានបញ្ហាអី ខ្ញុំក្តាប់អប់បានដែរទេ។ ឃុំសំបួរ ដែលខ្ញុំទៅហ្នឹងមកពីគេងាប់អស់ហើយ ផ្លាស់ខ្ញុំទៅបាទ។ រួចឃុំរលួស អ៎! ឃុំរលួសអី ឃុំន៉ែ ក្បាលដំរី ពួកលោក ឆន អីហ្នឹងក៏ងាប់អស់ដែរ គេចាប់។ អ៊ីចឹងបានថា ពិបាកណាស់ មេឃុំហ្នឹងរាយការណ៍ពីគេផង ដល់មានគេរាយការណ៍ពីគាត់ទៀត ងាប់ អ្នែងបន្តគ្នា។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១១:២២:២២]

**ស៖** ប្រធានឃុំដទៃទៀតដែលត្រូវរាយការណ៍ និងកំណត់អំពីមុខសញ្ញាខ្មាំង ថាតើពួកគាត់បានគិតថា អ្នកណាជាខ្មាំងដោយរបៀបណា? តើមានការណែនាំនៅក្នុងទស្សនាវដ្ដីទង់បដិវត្តដែលត្រូវពិចារណាថា អ្នកណាជាខ្មាំងដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាទង់ហ្នឹងបានណែនាំដែរ ប៉ុន្តែខ្ញុំភ្លេចអស់ហើយមិនចាំទេ។ ចំពោះខ្ញុំឃើញគេរាយការណ៍តាមមូលដ្ឋានមួយៗហ្នឹង ខ្ញុំលើកឧទាហរណ៍មួយៗ ឆ្នាំ១៩៧៨ ហ្នឹង លោក យី ហ្នឹងគាត់ឲ្យខ្ញុំទៅវាស់ស្ទង់នៅទំនប់មួយនៅឃុំវត្តឬនៈ ក៏មានកន្លែងមួយវាមានស្ថានភាពល្អ អាចធ្វើទំនប់បាន។ គាត់ថា ឲ្យទៅពិនិត្យ ហើយនិងវាស់វែង តើកន្លែងហ្នឹងអាចធ្វើទំបន់បានដែរឬអត់? ខ្ញុំពិនិត្យទៅឃើញថា ធ្វើបាន វាស់វែងទំបន់ហើយប៉ាន់ស្មានកម្លាំងជូនគាត់រួចហើយ បាទ រួចហើយបានគាត់ឲ្យកម្លាំងមកអង្គាល់នុ៎ង ខ្ញុំថា បើ៥០០នាក់ ត្រូវប្រើពេលបួនខែ បើ ១.០០០នាក់ប្រើពេលពីរខែ។ អាទំនប់បណ្ដោយ ១២០០ម៉ែត្រ ព្រោះខ្ញុំគិតថា អាចម៍ដីម្នាក់អាចៗរែកបានហើយក្នុងម្នាក់មួយម៉ែត្រគូបក្នុងមួយថ្ងៃ។ ដល់គេឲ្យ ១.០០០នាក់មកវារួចក្នុងរយៈពេលពីរខែហ្នឹងដែរ។

[១១:២៣:៥៧]

នៅពេលដែលធ្វើទំនប់ហ្នឹងមានក្មេងម្នាក់វាធ្វើការនៅចម្ការកៅស៊ូ វាឈឺ វាមកផ្ទះ មកផ្ទះ ជួន ហើយនិង ឈីន ហ្នឹងគេទទួលនៅឃុំវត្តឬនៈនៅពេលហ្នឹង ដេញឲ្យក្មេងហ្នឹងទៅវិញ អាក្មេងហ្នឹងថា ខ្ញុំសូមទៅផឹកថ្នាំសិន ដល់សូមទៅផឹកថ្នាំសិន គេអត់ព្រម គេថាអ្អែង បើមិនទៅអញបញ្ជូន។ ខ្ញុំថាអ្អើយ ឈីន អើយកុំគ្នាឈឺហើយឲ្យនៅហ្នឹងទៅ គេអត់ស្ដាប់ខ្ញុំ ដល់អានោះភ័យវារត់ទៅប្រាប់ស្រុកថា ឈីន និងជួន នេះប្រុងក្បត់ហើយបាទ។ ទៅដល់ស្រុកនុ៎ងអត់ពិចារណាទៀតចាប់ ឈីន និង ជួន យកទៅវៃចោលបណ្ដោយ។ ដល់យកទៅវៃចោល បន្តិចក្រោយមក តាវឿន ហ្នឹងគាត់ដឹងថា អាប៊ុន ហ្នឹងរាយ-ការណ៍ភូតចាប់អាហ្នឹងវៃចោលទៀតទៅ។

[១១:២៤:៤៧]

បាទ ដល់អ៊ីចឹងអាហ្នឹងៗរាយការណ៍ហ្នឹងវាអត់ស្រួលទេ ស្ដាប់ជាបន្តបន្ទាប់ ហើយក្នុងការរាយ-ការណ៍ហ្នឹងភាគច្រើនហ្នឹង គឺនិយាយអំពីមនុស្សខ្ជិលច្រអូស មិនធ្វើការងារ មិនដិតដល់ ភាគច្រើនគឺបញ្ហាហ្នឹង ហើយនិងពួកនិយាយមិនសូវល្អ។ និយាយដូចថា ធ្វើបដិវត្តន៍ហ្នឹងវាតឹងរ៉ឹងពេក ព្រោះនៅឃុំខ្លះអនុវត្តវារឹងស្លូកពេក ម៉ោងបីអីវាយអាគាំងឲ្យគ្នាទៅស្រែអ៊ីចឹង អាហ្នឹងវាមិនល្អទេ ព្រោះខ្ញុំឃើញ

អ៊ីចឹង កន្លែងណាធ្វើខ្លាំងអ៊ីចឹង បញ្ហាខ្លាំងអ៊ីចឹងរកបាយឲ្យប្រជាជនហូបអត់ចង់បានទេ វាខ្វះ ពីព្រោះដល់វាហាត់នឿយពេក មនុស្សលែងប្រឹង នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** ទាក់ទងទៅនឹងឧទាហរណ៍ដែលលោកទើបផ្តល់ ថាតើប្រជាជនមានសិទ្ធិរិះគន់ ឬក៏ជំទាស់-- ប្រជាជនដែលរិះគន់ ឬក៏ជំទាស់ទៅនឹងបក្សហ្នឹងត្រូវបានគេចាត់ទុកជាខ្មាំងដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហា យើងធ្វើសន្និបាត កន្លងមកយើងធ្វើសន្និបាត គឺបីខែយើងធ្វើម្តងនៅតាមសហករណ៍បាទ។ ខ្ញុំទៅដល់សំបូរដំបូង ខ្ញុំទៅនៅឃុំសំបូរ ព្រោះខ្ញុំនៅឃុំវត្តន:នេះ គឺបីខែម្តង គឺប្រជាជនមានសិទ្ធិរិះគន់ថ្នាក់ដឹកនាំ ទូលាយ បើកទូលាយ។ លុះដល់ខ្ញុំទៅនៅសំបូរ ដល់ទៅនៅសំបូរខ្ញុំភ្ញាក់ ស្រាប់ដល់ពេលខ្ញុំធ្វើ សន្និបាត ខ្ញុំដាក់ខ្លួនឲ្យអង្គប្រជុំគេទិតៀន ស្រាប់តែគេថា គេសប្បាយចិត្តណាស់ជាលើកដំបូងដែលទិតៀនគណៈ កន្លងមកអត់ហ៊ានថាទេ ព្រោះគណៈខាងនៅសំបូរពីមុន ហ៊ានតែនិយាយថា គេមិនល្អបន្តិច មុខតែជាប់ពិរុទ្ធហើយ បាទ។ ព្រោះខ្ញុំដោយឡែកខុសគេ ចំពោះខ្លួនខ្ញុំខ្ញុំបានគេទិតៀន បើបានគេទិតៀនច្រើន ខ្ញុំអរ។ ពីព្រោះ យកការទិតៀនរបស់គេហ្នឹងមកត្រៀមការពារខ្លួនរបស់ខ្លួនឯងបាទ។ ទោះជាគេទិតៀនខុសក៏អរ ទិតៀនត្រូវក៏រឹតតែអរទៀតបាទ។

[១១:២៧:២០]

អ៊ីចឹងបើកទូលាយបាទ ប៉ុន្តែកន្លែងតិចណាស់តាមខ្ញុំក្តាប់បាន ព្រោះតែមានឋានៈធំខ្ពស់បន្តិច តែថ្នាក់ក្រោមទិតៀនហ្នឹង ចង់ថា មានបញ្ហាគុំកួន មានគំនុំគុំកួនអ៊ីចឹងបាទ។ បើខ្ញុំវិញខុសគេ បើកាលណាគេទិតៀនកាន់តែច្រើន កាន់តែអរបាទ។ នេះ ខ្ញុំសូមមានមតិប៉ុណ្ណឹង ប៉ុន្តែមានកន្លែងគេច្រើនណាស់ដែលៗទិតៀនសុទ្ធតែខ្មាំង។ ខ្ញុំសូមអស់មតិ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះ។ ខ្ញុំចង់សួរអំពីកាលដែលប្រជាជនទិតៀនប្រធានឃុំ ឬក៏គណៈស្រុក។ ខ្ញុំសួរថាតើមានប្រជាជនហ៊ានទិតៀន ឬក៏ប្រឆាំងទៅនឹងបក្ស ឬក៏គោលដៅរបស់-- ទិសដៅរបស់បក្ស ដូច ជាបញ្ហានៃការ-- បញ្ហានៃសម្ងហភាពអីនេះជាដើម។ តើមានគេរាយការណ៍អំពីប្រជាជនបែបនេះដែរឬទេ នៅក្នុងពេលប្រជុំបែបនោះ?

[១១:២៨:៤៧]

**ឆ៖** កន្លងមក ក្នុងការទិតៀនក៏ដោយ ក្នុងការផ្តល់យោបល់ក៏ដោយ គឺមិនមានអ្នកណាប្រឆាំងនឹងមាគ៌ារបស់បក្សទេ។ ឧទាហរណ៍ថា នៅក្នុងសហគមន៍គេលើកតែពីបញ្ហាហូបចុក ឧទាហរណ៍ហូបចុកយើងវាមានការខ្វះខាតយ៉ាងម៉េចយ៉ាងម៉ា អាហ្នឹងគេលើកពីបញ្ហាហ្នឹងទៅ ឬក៏គេលើកអំពី

បើគេកសាងបុគ្គល ឧបមាថា ជួរថ្នាក់ដឹកនាំ ចំណុចខ្វះខាតរបស់ដូចថា ខ្ញុំដាក់ខ្លួនឲ្យគេកសាងអ៊ីចឹង គឺថាការចុះរបស់យើង នៅចំណុចនេះមួយ យើងចុះអត់បានជិតដល់ទេ យើងមិនបានជួយតាមដានទេ មិនបានជួយផ្តល់មតិគេទេ។ អាហ្នឹងគឺមាន។ ដូចថាការហូបចុក ប៉ុន្តែនៅជាមួយខ្ញុំ ខ្ញុំសូមជម្រាបដោយត្រង់ ក្នុងពេលពីឆ្នាំ៧៣ រហូតដល់រត់។ ដល់ខ្ញុំនៅការដ្ឋានវិញទៀត ខ្ញុំអត់ដែលហូបបបរផង។ ខ្ញុំហូបបាយរហូត ពីព្រោះលទ្ធភាពរបស់ឃុំខ្ញុំ កន្លែងណាខ្ញុំនៅ ខ្ញុំអាចរកបាយជូនប្រជាជនហូបបាន ពីព្រោះបើហូបឆ្អែតវាខ្លាំងរហូតដែរហ្នឹង ប្រឡងប្រណាំងក្នុងខេត្តក្រចេះ ខ្ញុំមិនអួតទេ គ្មានពីណាធ្វើឈ្នះខ្ញុំទេ ព្រោះខ្ញុំឲ្យប្រជាជនហូបឆ្អែត។ អត់ដែល-- ខ្ញុំនៅត្រង់ណាក៏អត់ហូបបបរ ពីព្រោះខ្ញុំកម្មាភិបាលជំនាន់នោះដែរ ប៉ុន្តែខ្ញុំអត់មានផ្ទះបាយដោយឡែក។ ខ្ញុំទៅជួបរោងបាយកន្លែងណាហូបត្រង់ហ្នឹង។ បាទ អត់មានឲ្យគេចេះផ្គត់ផ្គង់អី ពីព្រោះខ្ញុំអត់ដែលចាត់ទុកខ្លួនខ្ញុំជាៗថ្នាក់ដឹកនាំផង ខ្ញុំកំណត់ថាខ្ញុំជាប្រជាជនមួយរូបដែលមានតួនាទីបម្រើដល់សង្គមជាតិប៉ុណ្ណឹង។ អត់ដែលមានគិតថាខ្លួនឯងអ៊ីចេះ សូម្បីតែខ្ញុំធ្វើមេឃុំរាល់ថ្ងៃហ្នឹងក៏ខ្ញុំអត់ដែលតាំងខ្ញុំធ្វើជាមេឃុំផង។ ខ្ញុំគ្រាន់តែថាជាប្រជាពលរដ្ឋម្នាក់ខិតខំធ្វើយ៉ាងណាឲ្យភូមិឃុំរបស់ខ្លួនគឺមានសុវត្ថិភាព និងមានការរីកចម្រើនតែប៉ុណ្ណឹង។ បាទ ខ្ញុំសូមអស់មតិ។

[១១:៣១:០៨]

**ស៖** លោកបាននិយាយព្រឹកនេះអំពីវគ្គសិក្សាប្រចាំឆ្នាំ ដែលចំណាយពេល ១៥ថ្ងៃ នៅក្នុងទីរួមខេត្តក្រចេះ។ តើនៅក្នុងការសិក្សាប្រចាំឆ្នាំនេះ តើគេមាននិយាយអំពីខ្មាំង ឬក៏ត្រូវមានការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ដើម្បីស្វែងរកខ្មាំងដែរឬទេ? តើវគ្គសិក្សារៀនសូត្រនោះមាននិយាយពីបញ្ហាទាំងអស់នេះទេ?

**ឆ៖** ក្នុងវគ្គសិក្សាដែលធ្វើប្រចាំឆ្នាំ គឺនៅខេត្តក្រចេះ គឺភាគច្រើនគេធ្វើនៅ-- គេហៅថាភូមិអន្ទង់រៀនៗ នៅក្នុងឃុំកន្ទួត គឺមានកន្លែងសាលានយោបាយមួយនៅម្តុំវត្តអន្ទង់រៀនហ្នឹង នៅក្រោយវត្តហ្នឹង។ បាទ ក្នុងការរៀនសូត្រហ្នឹង យើងរៀនគ្រប់ផ្នែកទាំងអស់ដែរហ្នឹង ពិសេសភាពការណ៍ខ្មាំងហើយនិងសំខាន់បំផុតពាក់ព័ន្ធនឹងការងារបង្កបង្កើនផល។ បាទ បញ្ហាបង្កបង្កើនផលជាចំណុចស្នូលក្នុងពេលយើងរៀនសូត្របាទ។

**ស៖** តើអ្នកណាជាអ្នកបង្រៀន នៅក្នុងវគ្គសិក្សាអប់រំទាំងអស់នោះ?

**ឆ៖** ក្នុងវគ្គសិក្សាអប់រំគឺគណៈតំបន់ បាទគណៈតំបន់ជាអ្នកឧទ្ទេសនាមឯកសារ គឺមានលោក-- មាន តាឃី, តាគួន បាទ។ តាឃី គាត់អប់រំណែនាំពីបញ្ហាពាក់ព័ន្ធនឹងសេដ្ឋកិច្ចខ្លាំង ឯតាគួន គាត់អប់រំ

ណែនាំអំពីបញ្ហាសន្តិសុខ។

[១១:៣៣:១៦]

**ស៖** នៅពេលដែលគេឧទ្ទេសនាមឯកសារ តើឯកសារអ្វីខ្លះដែលគេធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រទាំងអស់នោះបាទ?

**ឆ៖** បាទ ឯកសារមានច្រើន ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង ប៉ុន្តែវាយូរពេកទៅខ្ញុំវាមានការភ្លាំងភ្លេចច្រើន។ ប៉ុន្តែគ្រាន់តែខ្ញុំចាំបានថា ក្នុងនោះវាមានពាក់ព័ន្ធនឹងខ្មាំង ហើយនិងពាក់ព័ន្ធនឹងបញ្ហាបង្កបង្កើនផល។

**ស៖** លោកបាននិយាយថា តាគួន ជាអ្នកធ្វើឧទ្ទេសនាមអំពីសន្តិសុខ ថាតើបញ្ហាអ្វីខ្លះដែលជាប្រធានបទដែល តាគួន គាត់និយាយទាក់ទងទៅនឹងបញ្ហាសន្តិសុខនោះ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខគឺគាត់និយាយអំពីល្បិចដូចថា ល្បិចផ្សេងៗរបស់ខ្មាំង ឯខ្មាំងវាកាលពីមុនយើងខ្មាំង វានៅ-- យើងវៃខ្មាំង អាហ្នឹងវាជាខ្មាំងមួយហើយ ប៉ុន្តែខ្មាំងដែលនៅក្នុងមូលដ្ឋានយើងអ្នកដែលអុចអាល អ្នកដែលបង្កបញ្ហាធ្វើឲ្យអសកម្មក្នុងការងារនៅក្នុងសហគមន៍ អ្នកបំផុសចលនាថា មានដូចថា ខ្មាំងសត្រូវពីខាងក្រៅមកអុកឡុកយើងអ៊ីចឹងបាទ។ អាហ្នឹង គឺជាសភាពការណ៍ខ្មាំងដែលពេលនោះ ដូចហើយ-- ពិសេស គឺថាពាក្យចចាមអារ៉ាមថា ដូចថា យួនចូលលុកលុយយើងអ៊ីចឹង មកមិនយូរទេបន្តិចទៀត ស្រុកទេសយើងចេះប្រែប្រួលអ៊ីចេះប្រែប្រួលអ៊ីចុះ។ អាហ្នឹងគឺឮពាក្យអ៊ីចឹងៗ សុទ្ធតែជាភាសារបស់ខ្មាំងហើយ គេកំណត់បែង-- ឲ្យអ៊ីចឹងបាទ។

**ស៖** យើងបានជជែកអំពីការប្រជុំប្រចាំសប្តាហ៍ ដែលលោកបានចូលរួមនៅគណ:ស្រុក ជាមួយគណ:ស្រុក។ នៅក្នុងពេលដែលលោកជាប្រធានឃុំ តើលោកបានបញ្ជូនរបាយការណ៍លាយលក្ខណ៍អក្សរទៅលេខាស្រុក ឬក៏ទៅមន្ទីរស្រុកដែរឬទេ?

[១១:៣៦:០៤]

**ឆ៖** នៅពេលនោះយើងអត់សូវមានសរសេរជាលាយលក្ខណ៍អក្សរទេ គឺយើងទៅ ទៅដល់រាយការណ៍ផ្ទាល់មាត់ បាទផ្ទាល់មាត់។ ទៅដល់អង្គុយជុំគ្នាអ៊ីចឹង ដំកង់ ពែនជើងជុំគ្នាអ៊ីចឹងទៅ និយាយទៅ។ ពេលខ្លះទៅប្រជុំមានកន្លែងកៅអីអង្គុយទៅ យើងប្រជុំតាមហ្នឹងទៅ បាទ។ អត់ទៀង ជួនកាលអង្គុយដំកង់ ជួនកាល-- ប៉ុន្តែក្រោយពីយើងរំដោះមកយើងរៀបចំមានទីតាំងអីប្រជុំស្រួលបួល។ បើពីមុនយើងពែនជើងជុំគ្នាតែលើផ្ទះគេក៏មានដែរ ដែលគេចាត់ទុកជាទីតាំងមន្ទីរនោះ។

**ស៖** នៅក្នុងវគ្គសិក្សារៀនសូត្រ ឬក៏ការអប់រំនយោបាយដែលលោកបានចូលរួមនោះ តើលោកធ្លាប់ទទួលការណែនាំអំពីគោលនយោបាយបក្ស ទាក់ទងទៅនឹងព្រះពុទ្ធសាសនា ហើយនិងទីវត្តអារាមដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងសាសនា គឺកន្លងមកនេះក៏មានការអប់រំ គេថាយើងធ្វើបដិវត្តន៍ បាទ បដិវត្តន៍យើងកុំឲ្យមានបដិវត្តន៍ពីរដង។ យើងធ្វើបដិវត្តន៍បណ្ដើរ យើងអប់រំប្រជាជនបណ្ដើរ ដើម្បីចៀសវាងកុំឲ្យជឿនៅលើសាសនា។ សាសនាអីក៏ដោយ យើងមិនបាច់ជឿទេ គឺយើងជឿលើបដិវត្តន៍។ អ៊ីចឹងយើងធ្វើតែម្ដងអ៊ីចឹងទៅឲ្យចប់ទៅ ចប់បណ្ដោយកុំឲ្យមានបញ្ហាបដិវត្តន៍វប្បធម៌អីទៀត។ កុំឲ្យដូចនៅចិន នៅចិនយើងដឹងហើយថាឆ្នាំ១៩៦៦ នេះវាមានបដិវត្តន៍វប្បធម៌នៅស្រុកចិន ដែលគេកម្ទេចសាសនាកម្ទេចអីក្រោយ។ ឯស្រុកខ្មែរយើងគាត់ថា កុំឲ្យវាមានបញ្ហាអ៊ីចឹង យើងធ្វើបដិវត្តន៍នេះតែម្ដងឲ្យចប់តែម្ដងទៅ កុំឲ្យវាមានគ្រោះថ្នាក់ដល់ពីរដង។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១១:៣៨:៤៣]

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ រវាងខែមេសា ឆ្នាំ១៩៧៥ រហូត មករា ឆ្នាំ១៩៧៩ តើប្រជាជននៅខេត្តក្រចេះ ត្រូវបានអង្គការគេឲ្យប្រតិបត្តិជំនឿសាសនាដែរឬទេ?

**ឆ៖** ព្រះពុទ្ធសាសនានៅក្នុងខេត្តក្រចេះ បានត្រូវបញ្ចប់នៅឆ្នាំ១៩៧៦ បាទ។ ក្រោយពីយើងរំដោះនៅមានទេ នៅមានលោកសង្ឃទេ។ លោកសង្ឃនៅវត្តខ្ញុំហើយ ឆ្នាំ៧៦ ប្រហែលជារវាងខែ៧ ខែ៨ ហ្នឹង នៅសល់លោកមួយអង្គ ហើយនិងនៅក្រគរហ្នឹង វត្តក្រគរពីរបីអង្គ ព្រោះខ្ញុំជូនលោកវត្តខ្ញុំហ្នឹងមកក្រគរ ដើម្បីរកកាណូតជូនលោកឲ្យទៅស្រុកលោកវិញ លោកនៅឯខាងពាមជាំង ក្នុងស្រុកអូររាំងឪ បាទ។ ដល់អ៊ីចឹងខ្ញុំមក គ្រាន់តែឃើញលោកនៅវត្តក្រចេះនេះពីរបីអង្គ លោកតាៗ អ៊ីចឹងបានន័យថា នៅខេត្តក្រចេះនេះវាអាចអស់លោកសង្ឃនៅឆ្នាំ១៩៧៦ បាទ។ ឯនៅ៧៥ អីនៅមានទេ នៅមានលោកសង្ឃទេ ប៉ុន្តែដឹងថាដល់៧៦ហ្នឹងគឺបញ្ចប់។ ៧៦ មិនមែនដើមទៀត ប្រហែលចុង៧៦។

[១១:៤០:២៨]

**ស៖** ចំពោះព្រះសង្ឃដែលលោកបានបញ្ជូនទៅស្រុកពាមជាំង អូររាំងឪ ថាតើអង្គការគេតម្រូវឲ្យព្រះសង្ឃហ្នឹងសឹក បានន័យថា លាចាកសិក្ខាបទដែរឬទេ?

**ឆ៖** ខ្ញុំបានដឹងថា លោកតាហ្នឹងកាលពីមកហ្នឹងមិនទាន់សឹកទេ លោក ប៉ុន្តែទៅដល់ស្រុកលោក លោកអាចសឹកនៅស្រុក ពីព្រោះក្រោយពីយើងរំដោះវិញ លោកបួសឡើងវិញ។ ប៉ុន្តែឥឡូវនេះ លោក

សុគតទៅវិញហើយ លោកតា ឈ្មោះលោកតា ជា ឈាវ ហ្នឹងគាត់សុំថា កុំឲ្យលោកសឹកឯស្រុកហ្នឹង លោកចង់មកដល់ស្រុកកំណើតលោក កន្លែងឧបឈាលោក បើឧបឈាលោកសឹកហើយ លោកក៏នឹងសឹកខ្លួនឯង បើអត់មានអ្នកផ្សឹក។ ប៉ុន្តែដល់ក្រោយយើងរំដោះ លោកបួសឡើងវិញ ប៉ុន្តែឥឡូវនេះលោកសុគតហើយលោកចាស់ហើយ។

**ស៖** ថាតើវត្តអារាម នៅខេត្តក្រចេះហ្នឹង ជួបស្ថានភាពដូចម្តេចដែរនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

[១១:៤១:៥៦]

**ឆ៖** វត្តអារាមនៅក្នុងខេត្តក្រចេះគឺ ភាគច្រើនរក្សានៅទម្រង់របស់ខ្លួនបាន មិនសូវជាខូចខាតអីប៉ុន្មានទេ អត់មានការរុះរើអីច្រើន ដូចជា នៅក្នុងឃុំខ្ញុំនៅ នៅក្នុងឃុំខ្ញុំនៅនេះអត់ទាន់មាន វត្តអីស្រួលបួល គ្រាន់តែមានតែ ព្រោះលោកហ្នឹងរស់នៅដូចលោក តាឡុង កូនតូបតូចមួយនៅក្នុងព្រៃទេ អត់មានជាវិហារជាអីធំដុំទេ។ ដូចជា វិហារវត្តក្រចេះអី ខ្ញុំឃើញនៅភាពដើមនៅទាំងអស់ អត់មានប្រែប្រួលអីទេ ព្រោះខាងតំបន់អត់ឲ្យទាំងចូលផងនៅក្នុងវិហារនុ៎ង ព្រោះពេលមកប្រជុំអីម្តងម្កាលអី មកដេកនៅនឹងវត្តហ្នឹងគេអត់ឲ្យចូលក្នុងវិហារទេ រក្សាបានល្អ លើកលែងតែសសរវិហារ១០០ វាពុកគេរុះចេញ រុះវិហារចេញ យកទៅប្រើ-- យកឈើប្រើការផ្សេងៗទៀត។ ឯក្រៅពីហ្នឹង ដូចជាអត់មានវិហារណាមួយដែលត្រូវខ្មែចខ្ទាំនោះទេ រក្សាបានភាពដើម។ ខ្ញុំសូមអស់មតិ។

**ស៖** នៅពេលដែលលោកនិយាយថា គេមិនអនុញ្ញាតឲ្យប្រជុំនៅក្នុងវត្តនៅក្នុងវិហារនោះ ថាតើអ្នកណាជាអ្នកណែនាំថា មិនឲ្យទៅប្រជុំនៅក្នុងវិហារក្នុងវត្តនោះ?

**ឆ៖** មិនមែនថា មិនឲ្យព្រះវិហារទេ ប៉ុន្តែនៅវត្តក្រចេះហ្នឹង មានកុដិលោកគ្រូមេគណនោះមានកន្លែងប្រជុំ។ បាទ មានកន្លែងស្នាក់នៅ មានបន្ទប់អីចឹង គេឲ្យៗប្រជុំនៅក្នុងវត្តហ្នឹង ប៉ុន្តែមិនឲ្យចូលទៅលេងក្នុងវិហារទេ មិនឲ្យចូលក្នុងវិហារបាទ។ វិហារហ្នឹងគេបិទទ្វារជិតៗអស់អីចឹងទៅ រួចយើងក៏អត់ហ៊ាននាំគ្នាចូលដែរ បើគេហាមឃាត់ហើយ ថាមិនឲ្យចូលបាទ។

[១១:៤៤:០៥]

**ស៖** ដើម្បីឲ្យខ្ញុំបានយល់ច្បាស់ លោកបានបញ្ជាក់ថា ភាគច្រើននៃវត្តអារាម មិនត្រូវបានបំផ្លាញទេ។ ចុះប្រជាជនត្រូវបានអង្គការគេអនុញ្ញាតឲ្យប្រតិបត្តិ ជំនឿសាសនានៅក្នុងវត្ត នៅក្នុងព្រះវិហារទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺអត់មានលោក គឺអត់មានទេ អត់មានអ្នកទៅប្រតិបត្តិអីក្នុងវត្តទៀតទេ គឺបញ្ចប់បាទ។ ពុំមាន ព្រោះអត់ អស់លោកហើយ អត់មានទៅទៀតទេ ហើយ-- អីចឹងគឺចប់ហើយរឿងវត្ត។

[១១:៤៥:០០]

**ស៖** ចាតើវត្តអារាមខ្លះនៅក្នុងខេត្តក្រចេះ ត្រូវបានបំផ្លាញដែរទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំពិនិត្យមើលវត្តដែលនៅម្តុំជុំវិញខ្ញុំហ្នឹងគឺនៅមានភាពធម្មតា ដូចជាអត់មានរុះរើអីវត្តទេ។ បាទ វត្តនៅជាវត្តធម្មតា ប៉ុន្តែគ្រាន់តែថា វត្តហ្នឹងទៅជាឃ្លាំងទៅ វត្តហ្នឹងទៅជាទីតាំងធ្វើឡទៅ។ កន្លែងខ្លះគេធ្វើឡក្បឿងនៅក្នុងវត្តអីចឹង។ ហើយកន្លែងខ្លះទៅគេយកដាក់ឃ្លាំងសម្ភារៈ។ កន្លែងវត្តខ្លះទៅ គឺមានយុវជន យុវនារី ទៅរស់នៅក្នុងវត្តហ្នឹង ព្រោះមានសាលាមានកុដិអីធំៗ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** តើលោកដឹងថា វត្តដែលគេហៅថាវត្តអន្ទង់វៀន ដែលស្ថិតនៅក្នុងស្រុកក្រចេះនោះដែរឬទេ?

**ឆ៖** វត្តអន្ទង់វៀន គឺពិតជានៅក្នុងស្រុកក្រចេះ ក្នុងឃុំកន្ទួត។ ព្រោះកន្លែងហ្នឹងខ្ញុំឧស្សាហ៍-- ខ្ញុំទៅបានប៉ុន្មានដឹងដែរ ព្រោះមានសាលានយោបាយនៅនុ៎ង ពេលរៀនសូត្រទៅរៀននៅអន្ទង់វៀនហ្នឹងបាទ។ នៅក្រោយវត្តហ្នឹង។

[១១:៤៦:៤៨]

**ស៖** តើលោកស្គាល់-- តើលោកដឹងទេថា តើវត្តអន្ទង់វៀនហ្នឹងមានស្ថានភាពដូចម្តេចទេ? តើវត្តនោះនៅដដែលគង់វង្សរហូតមកសម័យហ្នឹង ឬក៏មានការខូចខាតអ្វីដែរ?

**ឆ៖** ពិតមែនតែខ្ញុំទៅរៀននៅសាលាមួយនៅក្រោយវត្តនុ៎ង ប៉ុន្តែវត្តហ្នឹងស្ថានភាពជាក់ស្តែងនៅវត្តហ្នឹង ខ្ញុំអត់ដែលបានចូលវត្តហ្នឹងទេ។ បាទ តាំងជំនាន់នោះក៏អត់ដែលបានចូល ហើយដល់ក្រោយមកទៀតក៏មិនបានដឹងវត្តហ្នឹងយ៉ាងម៉េចយ៉ាងម៉ាដែរ។ ព្រោះបានដឹងតែថា ខ្ញុំទៅរៀននៅសាលានយោបាយនៅខាងក្រោយវត្តហ្នឹង។ គ្រាន់តែដឹងថាមានវត្ត ប៉ុន្តែសភាពក្នុងវត្តខ្ញុំក្តាប់អត់បាន។

**ស៖** តើលោកបានឮថាវត្តណាមួយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ គឺត្រូវបានរុះរើចេញហើយគេយកឈើ យកអ្វីៗទៅកសាងដូចជាទំនប់អ្វីផ្សេងទៀតដែរឬទេ? លោកធ្លាប់ឮពីបញ្ហានេះទេ?

**ឆ៖** បញ្ហានេះខ្ញុំក្ដាប់អត់បានដែរ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា វត្តសំបូរ វត្តសសរ១០០នេះ ដោយវាពុកវាអីហើយ គេរុះ គេរុះរើវត្តហ្នឹងគឺយកគ្រឿងខ្លះ ហើយនិងគ្បឿងអីហ្នឹងមកសាងសង់មន្ទីរពេទ្យ បាទ។

[១១:៤៨:៥៨]

**សៈ** ឥឡូវនេះខ្ញុំចូលទៅដល់ប្រធានបទមួយផ្សេងទៀត នៅក្នុងវគ្គរៀនសូត្រ ហើយនៅក្នុងការអប់រំនយោបាយដែលលោកបានចូលរួមនោះ ថាតើមានការពិភាក្សា ឬក៏ការនិយាយអំពី ការបង្រៀនអំពីគោលនយោបាយរបស់បក្ស ទាក់ទងទៅនឹងពួកខ្មាំងដែរឬទេ? ឬក៏ពួកវៀតណាមដែរឬទេ?

**ឆ៖** ក្នុងការរៀនសូត្រនយោបាយ បាទ វាទៅតាមសភាពការណ៍។ បាទ នៅពេលខ្លះយើងកាលពីជំនាន់យើងវៃខ្មាំងពួក លន់ នល់ យើងនិយាយអំពីពួក លន់ នល់ និងអាមេរិកាំង។ ហើយដល់មកសម័យក្រោយមកយើង យើងក្រោយយើងរំដោះ យើងមានបញ្ហាជាមួយនឹងវៀតណាម ក៏យើងបានរៀនសូត្រអំពីល្បិចកលរបស់វៀតណាមអ៊ីចឹងដែរ បាទ។ អ៊ីចឹងគឺបញ្ហារៀនសូត្រនេះទៅតាមសភាពការណ៍ជាក់ស្ដែងនៃការវិវឌ្ឍន៍របស់សង្គម។

[១១:៥០:១៥]

**សៈ** ថាតើមានប្រជាជនវៀតណាមដែលរស់នៅក្នុងខេត្តក្រចេះដែរឬទេ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ?

**ឆ៖** មុនថ្ងៃទី១៧ ខែមេសា ១៩៧៥ ខ្ញុំក្ដាប់អត់សូវបានដែរ ពីព្រោះអ៊ីចេះ ព្រោះនៅឆ្នាំ៧៤ ជនជាតិវៀតណាមហ្នឹងរត់ទៅស្រុកច្រើនណាស់ នៅខេត្តក្រចេះ។ ពីមុននៅខេត្តក្រចេះមានច្រើន នៅហ្នឹង អូរឫស្សីក៏មាន នៅហ្នឹងខាងក្រគរក៏មាន មានសឹងគ្រប់ឃុំ។ ប៉ុន្តែដល់ឆ្នាំ១៩៧៤ គឺយួននុ៎ង ពេលដែលកងទ័ពវៀតណាមវាដកទៅ ឆ្នាំ១៩៧៤ យួនហ្នឹង ទៅតាមចង់អស់ បាទ។ ហើយក្រោយមក គឺមាននៅតែពួកបងប្អូនយើង ដែលមានដូចថា យកប្ដីខ្មែរ ឬក៏-- មាន១អ្នកនៅយកប្ដីខ្មែរ អីក៏មាន មានតិចតួច បាទ។

[១១:៥១:៤៥]

**សៈ** តើលោនៅចាំដែរឬទេ ថាក្រោយការរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ ថាតើពួកវៀតណាមដែលនៅខេត្តក្រចេះ នៅសល់នៅឡើយ ត្រូវបានគេជម្លៀស ឬក៏បញ្ជូនចេញទៅប្រទេសវៀតណាមក្រោយពេលរំដោះហ្នឹងដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំក្តាប់អត់សូវបានដែរ គឺក្រោយរំដោះហ្នឹង មិនដឹងជាគេបញ្ជូនឬយ៉ាងណាទេ គឺជនជាតិវៀតណាម។ ប៉ុន្តែគ្រាន់នៅខាងសហករណ៍ខ្ញុំសំបូរ ក្រោយរំដោះហ្នឹង នៅសល់វៀតណាមពីរនាក់ដែរ បាទ។ ម្តាយលោក ម៉ក់តាន់ គឹមលី គាត់យកប្តីខ្មែរ ប៉ុន្តែយាយវើ ជាមួយយាយវ៉ា ហ្នឹង នៅជាមួយខ្ញុំសុខរហូតដែរ អត់អីដែរ។ គាត់រស់នៅ ហើយប៉ុន្តែគាត់ចាស់ ឈឺស្លាប់ពីរបីឆ្នាំហ្នឹងអស់ហើយ នៅតែកូនៗគាត់។

**ស៖** ហើយនៅក្នុងវគ្គសិក្សារៀនសូត្រ ហើយនិងវគ្គអប់រំនយោបាយនោះ ជាការប្រជុំដែលលោកបានចូលរួមនោះ តើលោកនៅចាំ ថាតើមានការពិភាក្សា ឬក៏ការបង្រៀនអំពីនយោបាយបក្សចំពោះចាម? ចំពោះជនជាតិមូស្លីមដែរឬទេ?

[១១:៥៣:២០]

**ឆ៖** ក្នុងការរៀនសូត្រហ្នឹង ដូចជាអត់ដែលពាក់ព័ន្ធជាមួយជនជាតិខ្មែរអ៊ីស្លាមទេ បាទ។ ពីព្រោះដូចកំណត់ថា ជនជាតិខ្មែរអ៊ីស្លាម គឺជាខ្មែរ អត់មានដែលជួបមេរៀនណាមួយ ដែលថាជាជាតិសាសន៍ដទៃទេបាទ។

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ តើប្រជាជនចាមនៅក្នុងខេត្តក្រចេះ ដោយរាប់បញ្ចូលទាំងអ្នកដែលនៅក្នុងឃុំរបស់លោក តើអង្គការអនុញ្ញាតឲ្យពួកគាត់ប្រតិបត្តិសាសនាខ្មែរអ៊ីស្លាម ឬក៏មូស្លីមដែរឬទេ?

[១១:៥៤:១៥]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាសាសនានេះ មិនថាតែសាសនាព្រះពុទ្ធទេ ហើយសាសនាអ៊ីស្លាមក៏ដូចគ្នាដែរ គឺអត់មានអ្នកណាមានសិទ្ធិប្រតិបត្តិបានទេ។ លើកលែងតែគេលួចធ្វើស្ងាត់ៗមិនដឹងទេ ប៉ុន្តែជាក់ស្តែងគឺអត់មានទេ អត់មានឲ្យគោរព ព្រោះកន្លែងខ្លះរហូតដល់បង្ខំគ្នាឲ្យហូបសាច់ជ្រូកទៀតនោះបាទ។ នេះ ខ្ញុំមានមតិប៉ុណ្ណឹង។

**ស៖** តើនៅឃុំណាដែលបង្ខំឲ្យប្រជាជនចាម ខ្មែរអ៊ីស្លាមហូបសាច់ជ្រូកនោះ?

**ឆ៖** បញ្ហានេះ បើតាមខ្ញុំក្តាប់បាន វាស្ទើរតែគ្រប់កន្លែងហ្នឹងបាទ ស្ទើរតែគ្រប់សហករណ៍។ សហករណ៍ណាក៏ដូចសហករណ៍អ៊ីចឹង។ កន្លែងខ្លះតឹងរ៉ឹងរហូតដល់គ្នា ពេលយើងខ្មែរយើងហូបសាច់ជ្រូក គ្នាសុំប្រហុកមិនឲ្យក៏មានដែរបាទ។ ប៉ុន្តែភាគច្រើនណាស់ដែលតឹងរ៉ឹងចំពោះការហូបចុករបស់ជនជាតិអ៊ីស្លាម។

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខេត្តក្រចេះ តើអង្គការអនុញ្ញាតឲ្យជនជាតិចាមស្លៀកពាក់សម្លៀកបំពាក់ប្រពៃណីរបស់ពួកគាត់ទេ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺរបបស្លៀកពាក់នេះ វាដូចជា ចំពោះនៅកន្លែងខ្ញុំវាមានពួកអ៊ីស្លាមទៅតិច ហើយទៅក្រោយ ទៅក្រោយអ៊ីចឹង ឃើញតែស្លៀកពាក់ដូចគ្នា ខ្មៅៗដូចគ្នាទាំងអស់បាទ។ ឯនៅកន្លែងដែលមានអ៊ីស្លាមច្រើន ខ្ញុំក្តាប់អត់បានទេ មិនដឹងជាគេស្លៀកពាក់យ៉ាងម៉េច ឬក៏ការបង្ខិតបង្ខំយ៉ាងម៉េច ក្តាប់អត់បានដែរ ព្រោះឃើញជនជាតិអ៊ីស្លាមទៅកន្លែងខ្ញុំប្អូនដប់ម្ភៃគ្រួហ្នឹង គាត់ស្លៀកពាក់ដូចតែយើងដែរ។ ខ្ញុំសូមអស់យោបល់។

[១១:៥៧:០៥]

**ស៖** តើអង្គការអនុញ្ញាតឲ្យប្រជាជនចាមនិយាយភាសារបស់ពួកគាត់ទេ គឺភាសាចាមម៉ូស្លីមនោះ?

**ឆ៖** ចំពោះភាសាអត់មានបញ្ហាអីទេ គឺគេនិយាយដាក់ភាសារបស់គេទៅតាមដែលគេ នៅផ្ទះគេនិយាយភាសាគេហ្នឹងទៅ ហើយដល់គ្រាន់តែមកដល់កន្លែងការងារជាមួយគ្នា គេនិយាយភាសាខ្មែរយើងទៅ។ បើទៅជួបជុំក្រុមគ្រួសារគេនៅផ្ទះ គេនិយាយភាសាចាមទៅបាទ។ អត់មានអ្នកណាបង្ខិតបង្ខំរឿងភាសានិយាយទេបាទ។

**ស៖** តើប្រជាជនចាម អង្គការអនុញ្ញាតឲ្យគាត់រស់នៅជុំគ្នាជាសហគមន៍ជនជាតិចាមតាមភូមិរបស់គាត់ ឬក៏គេបំបែកពួកគាត់ឲ្យនៅលាយឡំជាមួយប្រជាជនខ្មែរ?

**ឆ៖** ក្នុងការរស់នៅ នៅពេលដូចជាគាត់ជម្លៀសទៅនៅភូមិណាមួយអ៊ីចឹង គេឲ្យនៅជាមួយប្រជាពលរដ្ឋយើងផ្ទះៗណាធំទៅចែករំលែកគ្នានៅ។ អត់មានឲ្យគាត់នៅម្តុំតែគ្នាគាត់ទេ ព្រោះនៅតែម្តុំតែគ្នាគាត់ ក៏វាមានលំបាកកន្លែង ត្រូវទាមទារធ្វើកន្លែងទៀត។ អ៊ីចឹង គឺគាត់នៅទៅរស់នៅ ឧបមាឈ្មោះពូ “ក” ៗគាត់មនុស្សតិច ហើយផ្ទះគាត់ធំ អាចនៅបានមួយគ្រួទៀត ទៅនៅជាមួយគ្នាទៅបាទ។

[១១:៥៨:៥៨]

**ស៖** លោកនិយាយថា សហករណ៍ខ្លះមាននយោបាយរឹងប៉ឹង រឹងមាំ គឺថាមិនឲ្យប្រជាជនចាមហូបប្រហុកទេ ចង់ឲ្យពួកគាត់ហូបសាច់ជ្រូក។ តើលោកអាចពន្យល់បន្ថែមបានជូនតុលាការបានទេចំណុចនេះ?

**ឆ៖** ចំពោះចំណុចនេះ ខ្ញុំមិនអាចបញ្ជាក់ជូនបានទេ ពីព្រោះអ៊ីចេះ ព្រោះថាជូនកាល

សហករណ៍នោះគេកំណត់ជំហររបស់គេ គឺដាច់ខាតត្រូវតែឲ្យហូបអ៊ីចឹង ខ្ញុំលើកឧទាហរណ៍ទេ ប៉ុន្តែបើកន្លែងខ្លះគេធូរស្រាលទៅ ក៏គេសម្រួលទៅតាមហ្នឹងដែរ។ បងប្អូនចាមក៏អត់បានហូប ហើយបងប្អូនចាមមានប្រវត្តិមួយទៀត សំឡេះសត្វ។ បាទ ដូចថា មានកម្មវិធីអ៊ីចឹង ឧបមាថាចូល-- បុណ្យធ្វើបុណ្យ ឬក៏មួយខែម្តងអ៊ីចឹង ចង់ហូបដូចសាច់ជ្រូកអីធម្មតាទេ ដូចគេចង់ហូបគោអីម្តងអ៊ីចឹង គាត់សុំទៅសម្លាប់ ដូចនៅជាមួយខ្ញុំ ខ្ញុំឲ្យស្លាប់ ឲ្យគាត់ទៅសម្លាប់ទៅ យើងផុតបាបបន្តិចដែរ ឲ្យគាត់ទៅសម្លាប់ខ្លួនគាត់ គាត់ឲ្យធម៌ គាត់ថា បើបានសម្លាប់ខ្លួនគាត់ គាត់ហូបដូចស្និទ្ធបន្តិច បើសិនណាជាគេសម្លាប់ វាងាប់ហើយ គាត់ថាគាត់ដូចជាហូបស្ទាក់ស្ទើរម៉េចគាត់នោះ។ អ៊ីចឹងឲ្យគាត់ទៅសម្លាប់ទៅ បាទ។

[១២:០០:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។

ឥឡូវនេះដល់ពេលសមល្មមសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសមស្រប និងផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅរសៀលនេះនៅវេលាម៉ោងប្រាំមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបញ្ជាក់ថា លោក នួន ជា ចង់សូមការអនុញ្ញាតដើម្បីតាមដានពីបន្ទប់ខាងក្រោម ហើយខ្ញុំថាពាក្យ “ដាដា”ហ្នឹង គឺទស្សនទិយម ដាដា គឺនៅក្នុងសម័យសង្គ្រាមលោកលើកទី២។ ក្រោយមកគឺថា ចលនានេះ គឺជំទាស់ទៅនឹងអ្វីដែលគ្មានន័យ ហើយនិងប្រឆាំងនឹងទស្សនៈដែលរងនូវការប្រព្រឹត្តមិនល្អ គឺមិនមែនមានន័យថា “ដាដា” នោះមិនមែនន័យថា កុំសួរ កុំឆ្លើយនោះទេ។ បាទ អានេះជាទស្សនវិទូនៅក្នុងសម័យក្រោយសង្គ្រាមលោកលើកទី២ ហើយយើងខ្ញុំនឹងដាក់លិខិតបោះបង់សិទ្ធិលោក នួន ជា ទៅតាមនីតិវិធីដើម្បីឲ្យគាត់បានទៅតាមដានល្ងាចនេះពីបន្ទប់ខាងក្រោម។

[១២:០២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

[១២:០៣:១០]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការព្រឹត្តិទៅនៅរសៀលថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ឃុំខ្លួនមួយនៅក្រោមសាលសវនាការនេះ។

ដោយឡែកលោក នួន ជា ទុកឲ្យគាត់នៅក្នុងបន្ទប់ដែលមានរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោកខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

អ៎! បង្អង់បន្តិចសិន!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីឲ្យលោក អៀង សារី!

[១៣:៣១:៥៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្តីព្រះរាជអាជ្ញា សួស្តីសហភាតា លោកអ្នកទាំងឡាយដែលនៅក្នុងបន្ទប់ និងក្រៅបន្ទប់សវនាការ។ ខ្ញុំបាទសូមលើកការកត់សម្គាល់ និងសំណូមពរមួយជូនដល់លោកប្រធាន ពីព្រឹកមិញខ្ញុំកត់សម្គាល់ឃើញថា សាក្សីបានឆ្លើយអធិប្បាយរៀបរាប់វែងឆ្ងាយទៅនឹងសំណួរនីមួយៗ។ ដោយហេតុថា យើងអត់មានគោលការណ៍ជំទាស់ទៅនឹងចម្លើយពីរដង។ ខ្ញុំស្នើសុំថា គួរសូមលោកប្រធានណែនាំដល់សាក្សីឲ្យឆ្លើយតែចម្លើយដែលកម្រិតទៅនឹងសំណួរដែលព្រះរាជអាជ្ញាចង់បានជាការត្រឹមត្រូវ ហើយអាចជាការសមល្មមទៅនឹងពេលវេលា ពីព្រោះខ្ញុំកត់សម្គាល់ឃើញថា ពេលសាក្សីឆ្លើយចប់ ព្រះរាជអាជ្ញា ពេលខ្លះគាត់ថា សំណួរហ្នឹង ខ្ញុំនឹងសួរតទៅទៀត ទៅពេលក្រោយ។ អានេះអាចថាពីរដងសម្រាប់សួរផង អាចថាពីរដងសម្រាប់ឆ្លើយផង។ អានេះជាសំណូមពរ និងការកត់សម្គាល់របស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

[១៣:៣៣:០៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

ហើយច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយនិងវិធានផ្ទៃក្នុងដែលកំណត់អំពីនីតិវិធីប្រព្រឹត្តទៅនៅក្នុងការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សីនេះភាគីពាក់ព័ន្ធនៅក្នុងរឿងក្តីនៅតែមានសិទ្ធិ ដូចដែលមានចែងក្នុងវិធាន ក៏ដូចជាច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរក្នុងការលើកឡើងជំទាស់តវ៉ាទៅ

នឹងការតាំងសំណួររបស់ភាគីម្ខាងទៀត។

អង្គជំនុំជម្រះគ្រាន់តែរំឭកថា សេចក្តីជំទាស់ទៅនឹងការតាំងសំណួរនេះសូមឲ្យច្បាស់លាស់ ហើយខ្លីបានហើយថា សំណួរនុ៎ងវាយ៉ាងម៉េច? ជាសំណួរច្រំដែល ជាសំណួរក្រៅអង្គហេតុ ឬក៏មិនពាក់ព័ន្ធ ឬក៏ជាសំណួរនាំមុខជាដើម។ ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការពិចារណាសម្រេចបន្ថែមដូចអ្វីដែលយើងបានធ្វើកន្លងមក។ នេះជាបទប្បញ្ញត្តិដែលចែងច្បាស់លាស់ក្នុងក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយក៏ដូចគ្នាផងដែរ ចែងនៅក្នុងវិធានផ្ទៃក្នុងពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការពិភាក្សាដេញដោលនៅក្នុងពេលសវនាការស្តាប់សក្ខីកម្មសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណី។

[១៣:៣៤:៣១]

ហើយអង្គជំនុំជម្រះក៏មានឆន្ទានុសិទ្ធិនៅក្នុងការសម្រេចដូច្នេះដែរ។ ហើយអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ ថានឹងប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការគ្រប់គ្រងកិច្ចដំណើរការសវនាការឲ្យប្រព្រឹត្តទៅបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាពខ្ពស់នៅក្នុងកិច្ចពិភាក្សាដេញដោល ដោយមិនបណ្តែតបណ្តោយទុកលទ្ធភាពឲ្យភាគីពាក់ព័ន្ធក្នុងរឿងក្តីនេះធ្វើការកត់សម្គាល់ ឬក៏លើកឡើងនូវសេចក្តីថ្លែងការណ៍អ្វីដែលឥតប្រយោជន៍ ឥតឈានទៅរក ស្វែងរកការពិតនោះទេ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រមផងដែរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរ លោកសាក្សី យុន គីម។ ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់ប្រធានបទថ្មីមួយ។ ខ្ញុំនឹងសួរលោកថា តើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ថាតើលោកបានដឹងអំពីការរៀបការដែលថាគេរៀបការឲ្យពួកយោធានោះ។ នារីរៀបការជាមួយយោធាបាទ?

[១៣:៣៥:៥៣]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ គឺនៅក្នុងសហករណ៍ក្តី នៅក្នុងអង្គភាពយោធាក្តី ប៉ុន្តែដោយឡែកអង្គភាពយោធា ខ្ញុំក្តាប់មិនសូវបានទេ ប៉ុន្តែគ្រាន់តែថា ចួនកាលខាងយោធាស្នើមកសហករណ៍ ស្នើមកអង្គភាព ដូចខ្ញុំនៅក្នុងអង្គភាពយុវជនយុវនារីអីចឹង ខាងយោធា គេថា គេសុំនារីប៉ុន្មាន

៣០នាក់ ដើម្បីឲ្យយកទៅធ្វើជាគ្រួសារយោធា។ ហើយក្នុងឱកាសនោះ យើងក៏មិនមែនអត្តនោម័តិថា បង្ខំឲ្យអ្នក-- នាងនេះនាងនោះត្រូវតែទៅដែរ សួរអ្នកស្ម័គ្រចិត្តបាទ។ ចួនកាលមាននារី២០នាក់ អីទៅ ដូចនៅកន្លែងខ្ញុំមានម្តងនោះ ប្រហែលជា២៥នាក់ ស្ម័គ្រចិត្តទៅ។ កាលហ្នឹងខាងកងពល៩២០ គេស្នើ បាទ។ ដល់គេស្ម័គ្រចិត្តអីចឹង យើងក៏ទៅតាមការស្ម័គ្រចិត្តរបស់នារីនោះទៅ។

[១៣:៣៦:៥៤]

ឯការរៀបចំ គ្រាន់តែតាមឮគេថាទេ គេមានពាក់លេខពាក់អីជាគូ។ ឯចំពោះដែលការស្ម័គ្រចិត្ត តើឈ្មោះ ក និងឈ្មោះ ខ ដែលត្រូវគូនឹងគ្នាយល់ព្រមឬមិនយល់ព្រម មិនដឹងទេ ប៉ុន្តែថាតាមខ្ញុំធ្លាប់ស្គាល់មិត្តខ្លះជាយោធាដែរ គេថា អត់ទេ គេស្នើសុំខ្លួនគេដែរ។ ឧបមាគេស្រឡាញ់ឈ្មោះ ក ហើយនិងស្រឡាញ់ឈ្មោះ ខ គេស្នើទៅ អង្គភាពគេឯកភាពក៏រៀបអាពាហ៍ពិពាហ៍ ដោយពេលរៀបការហ្នឹងគ្នាច្រើន អីចឹងវាមានពាក់លេខចំណាំរបស់គេដែរ។ បាទសូមអស់មតិប៉ុណ្ណឹង។

[១៣:៣៧:៤៧]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកថាការស្នើសុំទៅខាងកូនក្រមុំនោះ គឺខាងយោធា ខាងស្នើ។ ថា តើអ្នកណាជាអ្នកបញ្ជូនសំណើមកលោក ដែលថាលោកជាគណៈឃុំពេលនោះ?

**ឆ៖** កន្លងមកនេះខាងយោធាស្នើសុំ គឺគេស្នើសុំតាមរយៈស្រុក។ ស្រុកគេបញ្ជាមកប្រាប់យើង ថាខាងយោធាគេសុំយុវនារីប៉ុន្មាន ថា ៣០នាក់អីអីចឹង បាទ។ ហើយខាងខ្ញុំឯណេះជាអ្នកសម្រេចសួរយោបល់ខាងយុវនារីដែលនៅក្នុងអង្គភាពជាមួយបាទ។ បើគេស្ម័គ្រចិត្តយើងនឹងឲ្យគេទៅ ដោយខាងយោធាគេមកទទួលនៅនឹងកន្លែងបណ្តោយ។

**ស៖** លោកបានបញ្ជាក់ថា ករណីនោះគឺថាមានសំណើមកពីកងពល៩២០ បាទ។ សំណួរ ខ្ញុំចង់សួរថា តើសំណើហ្នឹងចេញមកពីយោធាតំបន់ ព្រមទាំងកងពលរបស់មជ្ឈិមដែរឬទេ ដែលថាស្នើសុំឲ្យបញ្ជូននារីទៅរៀបការនោះ?

[១៣:៣៩:២១]

**ឆ៖** ចំពោះបញ្ហានេះ ខ្ញុំមិនបានដឹងដែរ គ្រាន់តែដឹងថាស្រុកជាអ្នកស្នើបន្តមកទៀត។ ឯថ្នាក់ខាងលើទាក់ទងគ្នាយ៉ាងម៉េច ខ្ញុំក្តាប់អត់បានដែរបាទ។

**ស៖** ខ្ញុំចង់ចូលទៅត្រឡប់ទៅរកសម័យកាលមួយដែលលោកបានធ្វើជាគណៈឃុំសំបូរ។ លោកបានឆ្លើយនៅក្នុងបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ថានៅក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ

១៩៧៧ ហើយលោកបានមកព្យាបាលជំងឺនៅភ្នំពេញ ហើយពេលលោកត្រឡប់ទៅខេត្តក្រចេះវិញ នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៧ គេបានតែងតាំងលោកធ្វើជាគណៈឃុំសំបូរ។ ហើយខ្ញុំនឹងមានសំណួរមួយចំនួនទាក់ទងពីបញ្ហានេះ។ ទីមួយ សួរថាតើលោកទទួលការព្យាបាលនៅមន្ទីរពេទ្យមួយណានៅភ្នំពេញនៅអង្កាល់នោះនោះ?

[១៣:៤០:៣៨]

**ឆ៖** នៅខែ០១ ហ្នឹង ខ្ញុំបានមកសម្រាកពេទ្យនៅខេត្តក្រចេះ ដល់អង្កាល់ហ្នឹងខ្ញុំតឹងច្រមុះ រួចខ្ញុំសង្ស័យ ព្រោះខ្ញុំធ្លាប់មានឫសដូងដុះច្រមុះ។ ខ្ញុំធ្លាប់កាត់ម្តងនៅឆ្នាំ១៩៦៦ រួចវាតឹងច្រមុះពេក ខ្ញុំសុំគេមកដេកពេទ្យក្រចេះ។ ដល់មកដេកពេទ្យក្រចេះ ពេទ្យក្រចេះបញ្ជូនខ្ញុំមកពេទ្យភ្នំពេញហ្នឹង។ កាលហ្នឹងជិះកាណូតមក មកដេកពេទ្យនេះ គេហៅពេទ្យសហភាពសូវៀត បាទ។ ខ្ញុំមកដេកពេទ្យមួយខែ ជាងមួយខែទាល់តែជិតដាច់ខែ០២ គ្រូពេទ្យអត់មានមើលអីផងអង្កាល់ហ្នឹង។ ដល់ថ្ងៃវេនគ្រូវមើលខ្ញុំ ឧបមាថាថ្ងៃអង្គារគេមើល មើលប្អូននាក់អីចឹង ស្រាប់តែដល់ថ្ងៃអង្គារហ្នឹងថាថ្ងៃសម្រាក ពន្យារទៅទៀតទៅពន្យារៗ។ ទាល់តែបានមួយខែជាងបានខ្ញុំសួរលោកគ្រូពេទ្យ ប៉ុន្តែមិនដឹងលោកគ្រូពេទ្យណាទេអង្កាល់ហ្នឹង បានគាត់យកខ្ញុំទៅពិនិត្យទៅ គាត់ថាទេអត់មានដុះសាច់ទេ វាហើមអាស្នែងខាងក្នុង។ គាត់ប្រាប់ថានៅក្នុងច្រមុះយើងមានស្នែងបីជាន់ ហើយចាក់ថ្នាំឲ្យតែមួយម្តុលទៅ ធូរដល់ថ្ងៃហ្នឹងបណ្តោយទៅ។ ចាក់អាក្នុងនុំង ម្តុលវែង អង្កាល់ហ្នឹងខ្ញុំមានរោគអីចឹង ប៉ុន្តែមកដេកពេទ្យសូវៀតហ្នឹងបាទ។ សូមអស់។

[១៣:៤២:១៣]

**ស៖** នៅពេលដែលលោកត្រឡប់ទៅពីភ្នំពេញទៅវិញ ពីមន្ទីរពេទ្យនោះ ថាតើមូលហេតុអ្វីដែលចាត់តាំងឲ្យលោកធ្វើជាគណៈឃុំសំបូរ តែមិនតែងតាំងឲ្យលោកធ្វើជាគណៈឃុំវឌ្ឍនៈទេ? តើលោកដឹងពីមូលហេតុហ្នឹងទេ?

**ឆ៖** ខ្ញុំគេតែងតាំងមុន ខ្ញុំមកដេកពេទ្យ។ បាទ តែងតាំងខ្ញុំរួច ខ្ញុំថាសុំមកដេកពេទ្យសិន។ បាទពេលនោះគឺគណៈឃុំសំបូរ គេចាប់អស់ហើយ បាទ។ លោក ផាន ហ្នឹងជាមួយខ្ញុំមិត្តភក្តិគ្នាដែរ គាត់ធ្វើចៅហ្វាយស្រុក គាត់ថាហៅខ្ញុំជួយការងារនៅនុំង ព្រោះសភាពការណ៍នៅសំបូរវាច្របូកច្របល់ខ្លាំង។ អីចឹងបានជាគេផ្លាស់ប្តូរខ្ញុំហ្នឹង។ ផ្លាស់ប្តូរមុនខ្ញុំមកដេកពេទ្យ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយថា នៅស្រុកសំបូរមានភាពច្របូកច្របល់នោះ ថាតើលោកអាចប្រាប់ខ្ញុំបានច្បាស់ទេថា ប្រច្ចូកច្របូលនោះយ៉ាងដូចម្តេច នៅពេលដែលលោកដឹងនៅកាលនោះនោះ?

[១៣:៤៣:៣០]

**ឆ៖** សភាពការណ៍នៅពេលនោះ គឺច្របូកច្របល់នោះគឺមិនមែនការបះបោរអីទេ។ គណៈ-- គេចាប់គណៈអស់ទៅ បាទគណៈឃុំពីមុនហ្នឹងត្រូវចាប់ខ្លួនបាទ ហើយនៅក្រោយគេហ្នឹង ចាប់លោកឈ្មោះ សំផន។ លោក សំផន ហ្នឹងគាត់មានសីលធម៌នារី គេចាប់គាត់ទៅទៀតទៅ អស់ បាទ។ ដល់អស់ នៅសល់តែ ពេន ម្នាក់ឯង បានគេហៅខ្ញុំទៅ នៅឃុំសំបូរ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** លោកបានបញ្ជាក់ថា នៅពេលនោះ គឺគេបានចាប់គណៈដែលបានប្រព្រឹត្តខុសសីលធម៌។ តើលោកជឿដែរឬថា មានអ្នកផ្សេងទៀតជាសមាជិកគណៈឃុំត្រូវបានគេចាប់ផងដែរនោះ?

**ឆ៖** ខ្ញុំជឿ ដូចលោក សំផន នេះគាត់មានៗពាក់ព័ន្ធនឹងសីលធម៌មែន។ ប៉ុន្តែឯគណៈឃុំផ្សេងទៀតដូចជា បងគ្រីន អី ខ្ញុំភ្លាប់អត់បាន មិនដឹងជាមានបញ្ហាអីបានគេចាប់គាត់។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១៣:៤៤:៥៥]

**ស៖** ឥឡូវនេះ លោកបានប្រាប់តុលាការថា ប្រធានស្រុកដែល ផាន ដែលណែនាំលោកឲ្យទៅធ្វើគណៈឃុំ ថាតើ ផាន ហ្នឹង ដែលធ្វើជាគណៈស្រុកសំបូរ មុនពេលដែលលោកឡើងកាន់ជាគណៈឃុំនៅទីនោះៗ?

**ឆ៖** បាទ នែ៎ ផាន ហ្នឹងទទួលភារកិច្ចជាគណៈស្រុកសំបូរ ហើយផ្ញើរខ្ញុំទៅនៅសំបូរដំបូង គឺមាន ផាន ហ្នឹងគាត់ធ្វើប្រធានស្រុក ហើយខ្ញុំទៅបានមួយបន្តិចហ្នឹង គឺគេដកគាត់មកធ្វើប្រធានស្រុកក្រចេះវិញ ផាន ហ្នឹង ហើយក្រោយមកគេក៏ចាប់ខ្លួនគាត់ទៅ។

[១៣:៤៦:០៥]

**ស៖** លោកបាននិយាយយោងព្រឹកនេះទៅលើហេតុការណ៍មួយដែលថា លោកបានធ្វើជាគណៈឃុំសំបូរ ហើយមានគ្រួសារមួយចំនួនជាសមាជិកក្រុមគ្រួសារ ១៧មេសា ដែលគេឲ្យទៅនៅទីនោះ។ តើលោកបានទទួលការណែនាំថា ត្រូវធ្វើដូចម្តេចជាមួយប្រជាជនថ្មី ១៧មេសា នេះទេ ដែលគេបញ្ជូនទៅឃុំសំបូរនោះ?

**ឆ៖** នៅពេលដែលខ្ញុំទៅកាន់ឃុំសំបូរហ្នឹង ខាងស្រុកគេណែនាំឲ្យបែងចែកមនុស្សជាបីប្រភេទ។ ប្រភេទទីមួយ គឺប្រជាជនចាស់ បាទ គេកំណត់ថា ជាសមាជិកសហករណ៍។ ឯទីពីរទៀតគឺ ប្រភេទប្រជាជនចាស់ដែរ ប៉ុន្តែសមាសភាពដូចថ្នាក់ជីវភាពទ្រង់ខ្ពស់ ហើយពីដើមមក ហើយមិនសូវពេញចិត្តនឹងបដិវត្តន៍គេឲ្យកំណត់ថា ជាសមាជិកត្រៀម។ ឯប្រជាជនថ្មី គេឲ្យ អី ១៧មេសា នេះគេឲ្យកំណត់ជា

សមាជិកផ្ញើ។ ប៉ុន្តែដោយឡែកនៅក្នុងឃុំសំបូរ ខ្ញុំនេះ ខ្ញុំអត់បានបែងចែកអ៊ីចឹងទេ មានតែក្នុងបញ្ជី ហើយអត់ប្រកាសបាទ ពីព្រោះខ្ញុំបានចាត់ទុកអ្នកទាំងអស់នោះ និយាយតែពីសមាជិកសហករណ៍ទាំងអស់គ្នា ព្រោះខ្ញុំគិតថា បើសិនណាខ្ញុំប្រកាសថា មានត្រៀម មានផ្ញើទៅ មានពេញសិទ្ធិទៅ អ្នកពេញសិទ្ធិមុខតែព្រហើនបន្តិចហើយ។ បាទ ដូចអំណាចហ្នឹងវាខ្ពស់ ឯអ្នកគ្នាផ្ញើនោះ គ្នាភ័យខ្លាច។ អ៊ីចឹងវាត្រូវក្នុងសហករណ៍ហ្នឹងវាអត់ ដូចជា ការឯកភាពទេ។ អ៊ីចឹងខ្ញុំចង់ឲ្យប្រជាជនយើងខ្លាំង គឺអត់ឲ្យប្រកាសទេអារឿងហ្នឹងនៅកន្លែងខ្ញុំនៅ។ កន្លែងគេ គេប្រកាស ប៉ុន្តែកន្លែងខ្ញុំ ខ្ញុំអត់ប្រកាសទេ ហើយមិនឲ្យដឹងថា អ្នកណាដឹងថា អ្នកណាត្រៀម អ្នកណាផ្ញើ អ្នកណាពេញសិទ្ធិទេ បាទ និយាយតែពីសមាជិកសហករណ៍ទាំងអស់គ្នា។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៣:៤៨:១៥]

**ស៖** តើគេណែនាំឲ្យលោក ប្រមូលប្រវត្តិរូបពីប្រជាជន ១៧មេសាដែរឬទេ ដើម្បីរកឲ្យឃើញថាតើពួកគាត់មានខ្សែ ឬក៏ជាប់ខាងខ្សែ លន់ នល់ របប លន់ នល់ ដែរឬអត់នោះ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាធ្វើប្រវត្តិរូប អ្នកមកថ្មីនេះ អត់មានបានធ្វើទេនៅក្នុងមូលដ្ឋានខ្ញុំ។ ប៉ុន្តែគេឲ្យធ្វើប្រវត្តិរូប អ្នកដែលសង្ស័យប្រជាជនចាស់បាទ។ ប្រជាជនចាស់មានធ្វើ ដូចជា គេធ្វើថាតើឈ្មោះឧទាហរណ៍ ក ប្រវត្តិរូបហ្នឹងគេធ្វើឈ្មោះ ក។ ក ហ្នឹង កូនឪពុកម្តាយឈ្មោះអី ហើយគាត់មានកូនប៉ុន្មាននាក់ កូនហ្នឹងធ្វើអីខ្លះ ហើយកូនហ្នឹងមានកូនប៉ុន្មានទៅទៀត។ បាទធ្វើតគ្នា។ ហ្នឹងគឺមិនមានធ្វើទូទៅទេ ចុចអ្នកណាដែលគេសង្ស័យ គេចុចឈ្មោះមកឲ្យធ្វើអ៊ីចឹង។ បាទ កន្លងមកមាន។ ឯប្រជាជន ១៧មេសា គ្រាន់តែជំរឿនធម្មតា។

**ស៖** នៅពេលដែលលោកនិយាយថា នៅពេលដែលប្រជាជនដែលគេសង្ស័យត្រូវធ្វើប្រវត្តិរូប។ ថាតើមូលហេតុអ្វី ដែលនាំឲ្យមានការសង្ស័យទៅលើប្រជាជនហ្នឹង? តើគេសង្ស័យពួកគាត់ដោយសារហេតុអ្វី?

[១៣:៤៩:៥៦]

**ឆ៖** ក្នុងការធ្វើនេះ គឺចង់សំដៅសំខាន់ គឺអ្នកដែលនៅក្នុងមូលដ្ឋាន អ្នកចាស់ហ្នឹង គ្រាន់តែមានប្រវត្តិដូចជាមេឃុំចាស់ ដូចជាមានពាក់ព័ន្ធអ្នកធ្វើការរាជការអីអ៊ីចឹង។ បាទ ហើយមិន-- ជាទូទៅគេចុចមក ឧបមាស្រុកគេថា ឲ្យធ្វើប្រវត្តិរូបអ្នកនេះៗ បាទ កន្លងមកយើងធ្វើទៅតាមការចុចរបស់គេហ្នឹងទៅ។

**ស៖** នៅពេលដែលលោកបានត្រឡប់ទៅដល់ឃុំសំបូរ តើលោកបានដឹងទេថា អ្នកកាន់តំណែងមុនហ្នឹងក៏បានធ្វើអ្វីខ្លះចំពោះមនុស្សដែលមានទំនាក់ទំនង ឬក៏ជាប់ខ្សែជាមួយសង្គមចាស់នោះ តើមេឃុំចាស់ហ្នឹងគាត់បានធ្វើវិធានការដូចម្ដេចចំពោះអ្នកទាំងនោះ?

**ឆ៖** បញ្ហានេះខ្ញុំអត់បាន ក្ដាប់អត់បានដែរនៅក្នុងឃុំសំបូរមុនខ្ញុំទៅហ្នឹង មិនដឹងជាគេធ្វើអីខ្លះផង។ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

**ស៖** នៅពេលដែលលោកបន្តតំណែងជាគណៈឃុំសំបូរតើលោកបានដឹងទេ ថាមានមនុស្សមួយចំនួននៅក្នុងឃុំរបស់លោក ដែលមានទំនាក់ទំនង ឬក៏ជាប់ខ្សែជាមួយរបបចាស់ ឬក៏ជាអតីតទាហាននៃរបបចាស់នោះ។ តើលោកបានដឹងទេ?

[១៣:៥១:៤៨]

**ឆ៖** នៅពេលដែលខ្ញុំទៅដល់ឃុំសំបូរហ្នឹង ខ្ញុំអាចដឹងខ្លះដែរ។ បាទ ដឹងថា អ្នកនេះធ្វើនេះពីមុនមក អ្នកនោះធ្វើនោះ។ បាទ ខ្ញុំលើកឧទាហរណ៍ដូចជា អ៊ំឈី អ៊ីចឹងគាត់ធ្វើមេឃុំ ដូចជាអ៊ំហម អ៊ីចឹងគាត់ជាចាងហ្វាងសាលាដំបូងពីដើម ខ្ញុំស្គាល់គាត់តាំងពីដើមមកហើយ ហើយក្នុងនោះទៀតមានលោកគ្រូខ្ញុំពីរបីនាក់គាត់នៅនុ៎ងដែរ។ បាទ ហើយគាត់នៅរស់ដល់រាល់ថ្ងៃហ្នឹងដែរ។ អ៊ីចឹងខ្ញុំដឹងច្រើនដែរបាទ។

**ស៖** តើលោកបានជួយពួកគាត់ទាំងអស់ហ្នឹងឬទេ ឬក៏ធ្វើរបាយការណ៍ក្លែង ដើម្បីលាក់ការពិតដែលថា ពួកគាត់ធ្លាប់មានទំនាក់ទំនងជាមួយរបបមុនដែរឬទេ?

**ឆ៖** ដូចបាន ខ្ញុំបានជម្រាបពីព្រឹកមិញម្ដងហើយ គឺដូចជាលោក តាឈី ហ្នឹងខាងស្រុកគេថាឲ្យហៅគាត់មកជួយការងារគេ ខ្ញុំស្មានតែជួយការងារមែនទែន គេឲ្យយកទាំងកាំបិតបន្ទោះអីមកទៀតស្រាប់តែគេយកគាត់ទៅបាត់ទៅ។ ហើយដល់ក្រោយមកទៀត ពាក់ព័ន្ធដូចលោក តាហម អីគាត់ចាងហ្វាងសាលាដំបូងចាស់ មានគេរាយការណ៍ឲ្យស្រុកថា គេសួរថាយ៉ាងម៉េចទៅ? ពេលកំពុងតែប្រជុំហ្នឹងគេសួរថា យ៉ាងម៉េចទៅចាងហ្វាងសាលាដំបូងពីមុននោះ? បាន តាវឿន អង្គាល់ហ្នឹងគឺយោធាកាន់អំណាចហើយ។ តាវឿន ថាយីអាហ្នឹងរឿងចាស់តើ! យកមក បញ្ជូនមក។ ដល់អ្នករាយការណ៍វាថាអត់នៅសហករណ៍វាទេ នៅសហករណ៍ខ្ញុំឯណោះ។ ហើយខ្ញុំគ្រាន់តែឮអ៊ីចឹង ខ្ញុំលួចជេរវា រួចថា អានេះដំបៅមិនឈឺយកឈើចាក់ទៀតហើយ។

[១៣:៥៣:៣៦]

បាទ អ៊ីចឹងបានខ្ញុំទាញហេតុផលថា តាហ្នឹងគាត់ដើរជើងបីរាល់ថ្ងៃ គាត់ដើរជើងបីហើយ។

ហើយបើយើងយកគាត់មកទាល់តែយករទេះសេះ ឬយកឡានទៅយក បើមិនអ៊ីចឹងទេមកអត់រួចទេ។ អាហ្នឹងទីមួយ។ ទីពីរទៀត កូនគាត់ធ្វើការនៅខាងពាណិជ្ជកម្មនៅខេត្តក៏មាន ធ្វើការនៅចម្ការកៅស៊ូក៏មាន បើយើងយកមកខ្លាំងទាំងហ្នូងទៀតហើយ។ បើយោបល់ខ្ញុំទេ ទុកបន្តិចទៅគាត់ងាប់ទៅហើយ។ ហើយគេក៏ឯកភាព រួចតាហាម ហ្នឹងគាត់ទើបតែស្លាប់ឆ្នាំទៅនៅភ្នំពេញហ្នឹង។ បាទ គាត់នៅភ្នំពេញហ្នឹងរហូតបានបីទសវត្សរ៍ទៀតហើយ ក្រោយពីពេលនោះមក។ បាទ ខ្ញុំជួយការពារបាន។

[១៣:៥៤:២១]

ហើយដូចមួយទៀត ដូចជាយួនសុទ្ធ ខ្ញុំជួយការពារបានដែរ។ ដូចជាម្ដាយលោក ម៉ក់ តាន់គីមលី មេទាហាននៅក្រចេះរាល់ថ្ងៃហ្នឹង ម្ដាយគាត់ហ្នឹងស្រាប់តែឃើញដើរមកមន្ទីរខ្ញុំ ខ្ញុំសួរថា ចែឯងទៅណា? ថាអ្ហឺ! គេឲ្យខ្ញុំមក។ ពីរនាក់បងប្អូន ឈ្មោះ យាយវ៉េ, យាយវ៉ា។ ខ្ញុំថា អ្ហេ! យាយទៅណា ឥឡូវខ្ញុំអត់ហៅផង ទៅវិញ យាយឯងចាំខ្ញុំហៅ សឹមមក។ ហើយគាត់ទៅនៅ នៅ-- ឥឡូវគាត់ចាស់ងាប់អស់ដែរហើយ កាលពីរបីឆ្នាំហ្នឹងហើយ។ បាទ គាត់បានមកងាប់នៅផ្ទះកូន អត់ងាប់នៅតែហោងទេបាទ។ អ៊ីចឹងខ្ញុំជួយការពារបាន បានច្រើនដែរមនុស្សនៅក្នុង-- ព្រោះខ្ញុំអត់ចេះចាប់គេ បាទ។ អំណាចមានអ៊ីចឹងប៉ុនអត់ៗដែលចាប់ចងអ្នកណាមួយ អត់ចេះធ្វើអាក្រក់ផង រហូតដល់ថ្ងៃណេះ ធ្លាប់តែធ្វើល្អៗ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី ហើយសូមឆ្លើយឲ្យចំនឹងសំណួរ ហើយឲ្យខ្លីជាងហ្នឹងបន្តិច ទីមួយ។ ទីពីរបញ្ជាក់ឡើងវិញ ដូចជាដើម្បីប្រតិចារឹក ដោយសារការស្ដាប់របស់យើង ហាក់ដូចជាមានបញ្ហាប្រើពាក្យមួយ ដែលមិនទំនងជាស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែលបង្ហាញនៅក្នុងដីកាដំណោះស្រាយ គឺលោកប្រើពាក្យអម្បាញ់មិញ "ពាណិជ្ជកម្មខេត្ត" ហើយតាមដែលលោកបានឆ្លើយកន្លងមកនេះ គឺតំបន់ទេ តំបន់ក្រចេះ។ អ៊ីចឹងការបែងចែកភូមិសាស្ត្រនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដូចជាមិនមានពាក្យថាខេត្តទេ គេបែងចែកជាតំបន់។ អ៊ីចឹង ដើម្បីឲ្យជាក់ច្បាស់ហ្នឹង កាលណាវាត្រង់ចំណុចដែលត្រង់ដែរបើថាខេត្ត គឺបញ្ជាក់ថាខេត្ត ប៉ុន្តែបើសិនជាតំបន់ទេ សូមលោកបញ្ជាក់ថា ដូចជា ពាណិជ្ជកម្មតំបន់ដើម្បីឲ្យច្បាស់លាស់ក្នុងការបែងចែកភូមិសាស្ត្រដែនដីនៅក្នុងសម័យកាលនីមួយៗហ្នឹង ឲ្យច្បាស់លាស់ដើម្បីឲ្យខ្លឹមសារនៃការផ្ដល់សក្ខីកម្មរបស់លោកហ្នឹងជាក់ច្បាស់ ហើយសមស្របទៅនឹងអ្វីដែលកើតមាននូវសម័យកាលនោះ។

[១៣:៥៦:១៦]

ហើយដូចគ្នាតំណាងសហព្រះរាជអាជ្ញាសូមមានការប្រយ័ត្នប្រយែងផង ប្រសិនបើមានពាក្យពេចន៍ដែលប្រើប្រាស់ទៅមានការចែកចេញពីស្ថានភាពដែលបង្ហាញនៅក្នុងដីកាដំណោះស្រាយ គួរបញ្ជាក់ផងដែរ អំពីភូមិសាស្ត្រ តំបន់ ហើយនិងខេត្តនេះ។ ពីព្រោះបានបង្ហាញហើយ គឺជាតំបន់ចំណុះឲ្យភូមិភាគពាយ័ព្យ ហើយក្រោយមកមានការទៅជាតំបន់ស្វយ័ត។ អ៊ីចឹង គឺសម័យនោះ គឺមិនមានពាក្យថាខេត្តទេ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

នៅចំណុចនេះ ខ្ញុំសូមសួរលោកសាក្សីអំពីសេចក្ដីដកស្រង់សង្ខេបពីមុន បទសម្ភាសន៍គាត់ពីមុនគឺឯកសារ E3/368។ ជាបទសម្ភាសន៍លើកទីមួយ ដែលនៅក្នុង*ខេស*សំណុំរឿង គឺ D125/184។ សេចក្ដីដកស្រង់ដែលខ្ញុំចង់អាននោះ គឺខ្មែរ ERN 00340159, អង់គ្លេស ERN 00345195 ហើយបារាំង ERN 00404181។ ខ្ញុំមានឯកសារលើក្រដាស ចម្លើយដែលអាចជូនទៅសាក្សីដើម្បីលោកអានហើយនិងសូមអនុញ្ញាតពីតុលាការដើម្បីបង្ហាញឯកសារនេះ នៅលើអេក្រង់ផងដែរ បាទ។

[១៣:៥៧:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ផ្នែកមួយដែលខ្ញុំចង់អាន ហើយនិងសួរសំណួរលោកនោះគឺនៅក្នុងចុងបញ្ចប់នៃបទសម្ភាសន៍នោះ កំណត់ត្រានេះ។ នៅក្នុងចំណុចចាប់ផ្ដើមនោះ គឺដូចដែលលោកបានរៀបរាប់របៀបដែលលោកក្លាយទៅជាគណៈឃុំសំបូរ ហើយបានឃើញប្រហែលជាប្រជាជនថ្មី ១៧មេសា នោះប្រហែលជា១០០គ្រួសារដែលជម្លៀសពីភ្នំពេញទៅ។ ហើយសំណួរនិងចម្លើយពីរខាងក្រោយដែលខ្ញុំនឹងអានជូនលោកហ្នឹង។

សូមដកស្រង់៖ “សំណួរ៖ តើថ្នាក់លើគេមានណែនាំឲ្យលោកធ្វើយ៉ាងម៉េចចំពោះប្រជាជនទាំងនោះ? ឆ្លើយ៖ គេបានណែនាំឲ្យធ្វើប្រវត្តិរូបដើម្បីក្ដាប់ឲ្យបានពីប្រវត្តិនៃបុគ្គលម្នាក់ៗ។ ប្រវត្តិរូបដែលខ្ញុំធ្លាប់បានធ្វើចំពោះប្រជាជនទាំងនោះ រួមមានទាហានលន់ នល់ រាជការ បញ្ញវន្ត និងអ្នករកស៊ីធម្មតា។

សំណួរ៖ ក្រោយពីរកឃើញនូវប្រភេទតាមប្រវត្តិរូបនោះហើយ តើថ្នាក់លើគេបានណែនាំឲ្យធ្វើយ៉ាងម៉េចទៀត? ឆ្លើយ៖ ខ្ញុំដឹងថា អ្នកកាន់កាប់ឃុំសំបូរជំនាន់មុនខ្ញុំ អ្នកដែលគេរកឃើញថាជាទាហានត្រូវគេចាប់យកទៅសម្លាប់។ តែនៅពេលដែលខ្ញុំមកកាន់កាប់ ដោយដឹងថា រកឃើញទាហានត្រូវគេយកទៅសម្លាប់នោះ ខ្ញុំបានធ្វើរបាយការណ៍បិទបាំង ហើយណែនាំពួកនោះឲ្យរក្សាការសម្ងាត់ដើម្បីសេចក្ដីសុខផ្ទាល់ខ្លួន និងកុំឲ្យរាយការណ៍ពីគ្នាឯងថា អ្នកនេះធ្វើអីអ្នកនោះអីអ៊ីចឹងទៅ"។ ចប់សេចក្ដីដកស្រង់។

ដូច្នេះសំណួរទីមួយរបស់ខ្ញុំហ្នឹង គឺសួរថា តើលោកដឹងដោយវិធីណាដែលថាអតីតទាហាន លន់ នល់ ត្រូវបានគេសម្លាប់ បានន័យថាសម្លាប់ដោយគណៈឃុំសំបូរចាស់នោះ តើលោកដឹងដោយវិធីណា?

[១៤:០០:៤៣]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានៅឃុំសំបូរ គណៈឃុំសំបូរចាស់ដែលធ្វើប្រវត្តិរូប ហើយមានការចាប់ចងនេះ ខ្ញុំដឹងមិនសូវច្បាស់លាស់ប៉ុន្មានដែរ ប៉ុន្តែគ្រាន់តែថាដឹងតាមរយៈបងប្អូនយើងនិយាយថា មានកាប់សម្លាប់ខ្លះៗអ៊ីចឹងជំនាន់លោក សំផន ដែលធ្វើជាលេខាឃុំសំបូរបាទ។ បាទ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកជម្រាបដល់សហចៅក្រមស៊ើបអង្កេតថា លោកធ្វើរបាយការណ៍បិទបាំង តើលោកចង់មានន័យយ៉ាងដូចម្ដេចដែរ? តើលោកធ្វើយ៉ាងដូចម្ដេចដែរ ដើម្បីជួយមនុស្សទាំងនេះនៅពេលដែលលោកនិយាយថារបាយការណ៍បិទបាំងនោះ?

**ឆ៖** ពាក់ព័ន្ធនឹងការបិទបាំងប្រវត្តិរូបបងប្អូនយើងនេះ គឺនៅពេលដែលខ្ញុំទៅរស់នៅក្នុងឃុំសំបូរក្នុងឋានៈជាមេឃុំនេះ គឺបានទទួលការអុចអាលគ្នា។ អុចអាលគ្នា បានន័យថាបន្តិចអ្នកនេះមករាយ-ការណ៍ប្រាប់ថាអ្នកនោះធ្វើនេះពីជំនាន់ លន់ នល់ ពិសេសធ្វើទាហាន ថាអ្នកនេះស័ក្ដិបី អ្នកនោះស័ក្ដិបួនអ៊ីចឹងបាទ។ ដល់ក្រោយមក ខ្ញុំក៏បានណែនាំទៅវិញថា យើងនាំគ្នាធ្វើយ៉ាងម៉េចគិតតែការងាររបស់យើងទៅ គេឲ្យធ្វើអីយើងធ្វើហ្នឹងទៅ មិនបាច់ចាំ កុំឲ្យមានរាយការណ៍ពីគ្នាទៅវិញទៅមក។ បើយើងរាយការណ៍អ៊ីចឹង នាំតែងាប់ទាំងអស់គ្នាទេ។ បាទដល់អ៊ីចឹង បងប្អូនយើងក៏បានស្ងប់ស្ងៀមមិនមានបញ្ហាអីដែលធ្វើឲ្យប៉ះពាល់គ្នាទៅវិញទៅមកទៀត។ ដែលខ្ញុំទៅនៅដំបូង គេរាយការណ៍អ៊ីចឹង តិចអ្នកនេះមក នេះស័ក្ដិបួន អានេះស័ក្ដិបីបាទ។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៤:០៣:០៥]

**ស៖** តើលោកចាំឈ្មោះមនុស្សដែរឬទេ តើគឺថាមនុស្សដែលលោកការពារ គឺមនុស្សដែលលោក

ជួយដោយបិទបាំង ឬក៏លាក់នូវប្រវត្តិរូបរបស់គាត់ ដែលជាអតីតទាហាន លន់ នល់ នោះ តើលោកចាំឈ្មោះពួកគាត់នោះដែរឬទេ?

**ឆ៖** ខ្ញុំយូរពេក ភ្លេចឈ្មោះអ្នកដែលនៅជាមួយខ្ញុំនោះអស់ហើយបាទ។

**ស៖** តើមានអ្វីកើតឡើងចំពោះលោកដែរ លោកសាក្សី ប្រសិនបើថ្នាក់លើគាត់រកឃើញថាលោកធ្វើរបាយការណ៍បិទបាំង ដោយលាក់លៀមរក្សាការណ៍សម្ងាត់របស់អ្នកអតីតទាហាន លន់ នល់ នោះ តើមានអីកើតឡើងដែរ លោកដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ ព្រោះមានការជំទាស់ពីមេធាវីការ-- មេធាវីការពារក្ដីរង់ចាំអង្គជំនុំជម្រះសម្រេចពីលើសេចក្ដីជំទាស់របស់មេធាវីជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

[១៤:០៤:២១]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ ព្រោះជាសំណួរឧបមាណវិធី។ អ្នកសួរ សួរថាប្រសិនណាបើសិនជាថ្នាក់លើរកឃើញ-- សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់មានប្រសិទ្ធភាព។ សំណួរបែបនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យភាគីសួរតាំងសំណួរចំពោះសាក្សីទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនៅចុងក្រោយដែលសួរដោយតំណាងសហព្រះរាជអាជ្ញាទេ។ សហព្រះរាជអាជ្ញាមានសំណួរអាចតាំងសំណួរផ្សេងទៀតបាន។

[១៤:០៥:១០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ក្នុងនាមលោកជាប្រធានឃុំ តើលោកត្រូវតែគោរពនូវបញ្ជា ឬក៏ការណែនាំពីថ្នាក់លើដែរឬទេ? តើលោកត្រូវគោរពតាមបញ្ជា និងការណែនាំពីថ្នាក់លើដែរឬទេ?

**លោក យុន គីម៖**

**ឆ៖** ជាគោលការណ៍ គឺក្នុងនាមជាគណៈឃុំ ត្រូវតែស្ដាប់បទបញ្ជាពីលើ ប៉ុន្តែកន្លងមកនេះមានចំណុចមួយចំនួន ដែលជាចំណុចខ្ញុំគិតថា ធ្វើទៅវាខ្លាំងហួសហេតុពេក ក៏មានការបន្ធូរពីសាលាខ្លះ

ដែរ ពីព្រោះខ្ញុំគិតថា ថ្នាក់លើមិនដែលមកជាប់នឹងយើងឯណា គឺសំខាន់ គឺប្រជាពលរដ្ឋជាមួយនឹងថ្នាក់ដឹកនាំនៅមូលដ្ឋាននេះហើយ ដែលជាអ្នកសម្រេចលើការងារផ្សេងៗ។ ខ្ញុំសូមមានមតិប៉ុននេះ។

**សៈ** នៅពេលដែលលោកធ្វើបែបនេះ នៅពេលដែលលោកការពារបែបនេះ តើលោកមានការភ័យខ្លាចអំពីសុវត្ថិភាពផ្ទាល់ខ្លួនដែរឬទេ?

**ឆៈ** កន្លងមកនេះ ខ្ញុំដូចជារឿងធម្មតា ពីព្រោះដាក់ស្លែង គឺខ្ញុំនៅកន្លែងណា ហូបបាយកន្លែងនុ៎ង ហើយខ្ញុំគិតថា បើថ្នាក់លើស្ដីបន្ទោសម៉េច ក៏ខ្ញុំថាមានគ្រោះថ្នាក់យ៉ាងម៉េចដល់ខ្លួន ក៏តាមដំណើរព្រោះគិតថា មួយជីវិតធ្វើការដូរបាយ ឯណាមិនបានទេ។ គ្រាន់តែធ្វើការចង់ងាប់ ហើយរកបាយស៊ីមិនបាន មិនកើតទេ។ អ៊ីចឹងស្រុកគេណែនាំឲ្យហូបបបរអ៊ីចឹង ខ្ញុំថា បើចង់ហូបបបរ ទាល់តែដកខ្ញុំពីមេ បើឲ្យខ្ញុំទៅធ្វើកូនទេ ស៊ីអីស៊ីទៅ បើឲ្យខ្ញុំនៅធ្វើមេ គឺខ្ញុំដាច់ខាតអត់ៗធ្វើតាមខាងស្រុកណែនាំឲ្យហូបបបរអ៊ីចឹងទេ ពីព្រោះខ្ញុំជឿថាថ្នាក់លើមិនបញ្ជាឲ្យហូបបបរអ៊ីចឹងទេ។ អ្ហឹ!ប្រាកដជាថ្នាក់ស្រុកហ្នឹងច្នៃប្រឌិត។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៤:០៧:៣៣]

**សៈ** ខ្ញុំមានសំណួរមួយទៀត ទៅលើប្រធានបទនេះ ដើម្បីឲ្យច្បាស់លាស់។ នៅពេលដែលលោកបង្ហាញប្រាប់សហចៅក្រមស៊ើបអង្កេតថា លោកធ្វើរបាយការណ៍បិទបាំង ការពារបុគ្គលទាំងអស់នោះ។ ថាតើវាជាការត្រឹមត្រូវដែរឬទេ? តើលោកធ្វើរបាយការណ៍បិទបាំង ផ្ញើទៅខាងថ្នាក់ស្រុកឬក៏យើងអាចនិយាយម្យ៉ាងទៀតថា លោកបិទបាំងថ្នាក់ស្រុកមិនឲ្យដឹងដោយការពារបុគ្គលដែលជាអតីតកម្លាំង ឬក៏ជាមន្ត្រីរាជការសម័យមុនហ្នឹង តើជាការត្រឹមត្រូវដែរឬទេ?

**ឆៈ** ពាក់ព័ន្ធនឹងបញ្ហានេះ ការធ្វើប្រវត្តិរូបនេះ គេមានធ្វើតាំងពីមុនខ្ញុំទៅម្ល៉េះ ព្រោះបងប្អូន១៧មេសា ទៅដល់គេធ្វើហើយ។ ពេលដល់សម័យខ្ញុំទៅនៅសំបូរនេះ គឺគ្រាន់តែគេឲ្យចុចប្រជាជនចាស់យើងខ្លះ ដែលត្រូវគេចង់តាមដានប្រវត្តិរូប គេឲ្យធ្វើ មិនជាទូទៅទេ។ ដូច្នេះ ពាក់ព័ន្ធនឹងរបាយការណ៍បិទបាំងនេះ គឺកន្លង ពេលធ្វើលើកមុនក៏មិនអស់ដែរ ត្រូវធ្វើបន្តទៀត ប៉ុន្តែគេអត់មានណែនាំអី បង្គាប់បញ្ជាឲ្យដាច់ខាតនោះទេ។ ពីព្រោះហើយ ខ្ញុំគិតថា ការធ្វើនេះ ក៏ដូចជាគ្មានន័យដែរពេលនោះ ពីព្រោះគណៈស្រុកមួយឡើងបានតិចៗចាប់គ្នាបាត់មួយពួកហ្នឹងទៅ បន្តិចឡើងមកទៀត។ ដល់អ៊ីចឹង ដូចតែខ្ញុំបិទបាំងអ៊ីចឹងដែរ ពីព្រោះរាយការណ៍ជាមាត់ទទេ អត់មានដែលសរសេរជាលាយលក្ខណ៍អក្សរទៅជូនថ្នាក់លើពីប្រវត្តិរូបរបស់បងប្អូនទាំងអស់នោះផង។ ខ្ញុំសូមអស់មតិ។

[១៤:០៩:៣៤]

**ស៖** សូមអរគុណ។ លោកបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍របស់លោកថា នៅចុងឆ្នាំ៧៧ ឃុំសំបូរត្រូវបានចែកចេញជាពីរសហករណ៍ គឺសហករណ៍សំបូរ និងសហករណ៍ខ្សឿន ហើយលោកក្លាយទៅប្រធានសហករណ៍ស្រែខ្សឿន នៅក្នុងចុងឆ្នាំ៧៧ ហើយនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ៧៧។ សំណួរដែលខ្ញុំចង់សួរគឺថា តើមានហេតុផលអ្វីទើបឃុំសំបូរ ត្រូវបែងចែកជាពីរសហករណ៍នៅក្នុងចុងឆ្នាំ១៩៧៧នោះ?

**ឆ៖** ដោយឃុំសំបូរនេះជាឃុំមួយធំជាងគេនៅក្នុងស្រុកសំបូរ ហើយវាមានសរុបទាំងអស់ប្រាំបីភូមិ អ៊ីចឹងគេចែកបួនភូមិខាងលើៗសាលាស្រុកសំបូរបច្ចុប្បន្ននេះ ទៅជាសហករណ៍សំបូរ។ ឯពីក្រោមសាលាស្រុកមកក្រោម គេកំណត់ថាជាសហករណ៍ស្រែខ្សឿន ដោយក្នុងមួយសហករណ៍នេះមានបួនភូមិបាទ។ នេះតាមជាទស្សនៈរបស់ខ្ញុំទេ គឺថាដើម្បីងាយស្រួលដំណើរការការងារ។ ដោយឃុំធំពេកវាមានការលំបាក។ នេះជាទស្សនៈខ្ញុំយល់ឃើញអ៊ីចឹង បានជាគេបែងចែកទៅជាពីរសហករណ៍អ៊ីចឹង។ ខ្ញុំសូមអស់មតិ។

[១៤:១១:១៩]

**ស៖** តើលោកទទួលខុសត្រូវលើមនុស្សប្រហែលជាប៉ុន្មាននាក់ដែរនៅក្នុងសហករណ៍ស្រែខ្សឿននោះ?

**ឆ៖** បាទ តាមខ្ញុំស្មានប្រហែលជា ៣០០០នាក់ បាទ។ នៅសហករណ៍ស្រែខ្សឿននុ៎ង ប្រហែលមនុស្ស ៣០០០នាក់ ពីព្រោះសរុបរួមជាង ៦០០០នាក់កាលពីជំនាន់នោះ។

**ស៖** ក្នុងរយៈពេលដែលលោកជាប្រធានសហករណ៍ស្រែខ្សឿន តើលោកនៅតែបន្តរាយការណ៍ទៅលេខាស្រុកសំបូរបន្តទៀត ឬមួយក៏យ៉ាងណា?

**ឆ៖** ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង។ កាលពីនៅសហករណ៍ អ៎! នៅជាឃុំរួមគ្នាទាំងអស់ក៏មួយអាទិត្យមានការជួបជុំគ្នាម្ដង ដល់ទៅជាសហករណ៍ហ្នឹងក៏មួយអាទិត្យជួបជុំគ្នាម្ដងដែរ។ ការរាយការណ៍គឺយើងរាយការណ៍ផ្ទាល់បាទ អត់មានសរសេរជាលាយលក្ខណ៍អក្សរទេ។

[១៤:១២:៣៨]

**ស៖** លោកបានបញ្ជាក់ថា លោកបានបញ្ចប់ការងារជាមេសហករណ៍ស្រែខ្សឿន នៅថ្ងៃទី១១ ខែមិថុនា ៧៨ ហើយបន្ទាប់មកត្រូវតែងតាំងទៅជាប្រធាននៅការដ្ឋាន ប-៣។ តើលោកអាចចាំ-- អាចប្រាប់បានដែរឬទេថា ហេតុអ្វីបានជាលោកចាំច្បាស់ថាគេៗបញ្ឈប់ការងាររបស់លោកនៅថ្ងៃទី១១ ខែ

មិថុនា ឆ្នាំ៧៨ ហើយផ្ទេរទៅនោះ? តើមូលហេតុអ្វីទើបលោកចាំ?

**ឆ៖** នៅថ្ងៃ១១ ខែមិថុនា ឆ្នាំ១៩៧៨ ហ្នឹងទៅប្រជុំ ដល់ទៅប្រជុំគេថាឲ្យខ្ញុំហ្នឹងចេញពីសហករណ៍ហ្នឹងទៅនៅការដ្ឋានដែលគេបានប្រមូលយុវជន យុវនារីហើយនៅកន្លែងគេហៅ ប-៣ ហ្នឹងកន្លែងអតីតអ្នកទោសរបស់កម្មាភិបាលដែលគេយកទៅដាក់ទោស។ ប-៣ ហ្នឹងគឺកន្លែងដេលគេប្រមូលកម្មាភិបាលមួយស្រុកទៅដាក់នៅកន្លែងហ្នឹង។ រួចទៅដល់គេដកអ្នកទោសនៅ-- កម្មាភិបាលទាំងអស់ហ្នឹងចេញអស់ទៅ គេយកយុវជន-នារីទៅដាក់។ នៅខែ៤ គេយកយុវជន យុវនារីទៅដាក់នៅនុ៎ង ហើយគេឲ្យទាហានគ្រប់គ្រង។ ដល់ទាហានគ្រប់គ្រងវាអត់កើត បាទផ្ដាច់ការទៅលើក្មេងៗនុ៎ងវាមានភាពមិនស្រួល បានគេដកទាហានហ្នឹងចេញទៅគេយកខ្ញុំទៅនៅគ្រប់គ្រងយុវជន យុវនារី កន្លែងនុ៎ងនៅថ្ងៃ១១ ខែ៦ ឆ្នាំ១៩៧៨ ហ្នឹង។ បាទ គេដកថ្ងៃត្រង់ ថ្ងៃល្ងាចខ្ញុំទៅដល់កន្លែងនុ៎ង។

[១៤:១៤:៣៧]

**ស៖** តើអ្នកណានៅក្នុងកិច្ចប្រជុំនេះ ដែលបានប្រាប់លោកឲ្យផ្លាស់ទៅ ប-៣ នោះ? តើអ្នកណាជាអ្នកប្រាប់លោក?

**ឆ៖** លោក វឿន ដែលជាលេខាស្រុកថ្មីហ្នឹងបាទ។ គាត់ជាយោធាមកទទួលលេខាស្រុក បញ្ជាឲ្យទៅ។

**ស៖** នៅពេលដែលលោកនិយាយថា ទាហានជាអ្នកគ្រប់គ្រង ប-៣ កាលពីមុននោះ តើលោកសំដៅទៅលើទាហានតំបន់ ឬមួយក៏កងពលទាហាន កងពលយោធាដែលមកពីខាងក្រៅនោះ?

**ឆ៖** ខ្ញុំអត់បានដឹងច្បាស់ថាទាហានឈ្មោះ សារិន ហ្នឹងជាទាហានកងទ័ពតំបន់ ឬក៏កងទ័ពមកពីខាងណាទេ គ្រាន់តែដឹងថា សារិន ហ្នឹងជាទាហានបាទ។ គេថា សារិន ទាហានហ្នឹងជាទាហានហើយប្រធាន "គ" កាលពីមុន។ ដល់អ៊ីចឹង ហើយខ្ញុំអត់ដឹងថាគាត់មកពីកងពល ឬក៏ខាងអីទេ។ ខ្ញុំសូមអស់មតិ។

**ស៖** លេខាស្រុកថ្មី លោក វឿន តើលោកដឹងទេថាលោក វឿន ហ្នឹងគាត់មកពីណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងប្រវត្តិរូបរបស់គាត់ច្បាស់ គ្រាន់តែឃើញគាត់មក អង្គាល់ហ្នឹងគាត់មកលោក វឿន និងលោក ឈូក ហ្នឹង មកទទួលស្រុកសំបូរហ្នឹង ហើយមិនដឹងជាគាត់មកពី-- ស្រុកកំណើតគាត់នៅខាងណា អត់ដឹងៗថាគាត់មកទទួលនៅសំបូរហ្នឹងប៉ុណ្ណឹង។ ខ្ញុំសូមអស់មតិ។

[១៤:១៦:៥៦]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរពីរបីសំណួរអំពីប្រធានបទពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំនៅក្នុងខេត្ត-- នៅក្រចេះ។ តើលោកអាចប្រាប់ខ្ញុំបានដែរឬទេថា តើស្រុកនីមួយៗនៅក្នុងតំបន់ក្រចេះនោះមានមន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំកែប្រែផ្ទាល់ខ្លួនដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាមន្ទីរសន្តិសុខ ខ្ញុំ-- ស្រុកផ្សេងៗខ្ញុំក្តាប់អត់បានទេ ដោយឡែកស្រុកសំបូរមានទីតាំងសន្តិសុខពីរកន្លែង។ មួយកន្លែងគឺនៅគោកក្តួច និងមួយកន្លែងទៀតនៅប្រាស្រាល។ ប្រាស្រាលនេះបានន័យថា អ្នកដែលមានកំហុសសីលធម៌អីផ្សេងៗហ្នឹង គេយកទៅដាក់នៅប្រាស្រាល ពួកនេះគឺមានតួនាទីអ្នកលើកទំនប់ផង បង្កបង្កើនផលផង។

ហើយមន្ទីរសន្តិសុខមួយទៀតនៅគោកក្តួចនេះ ពិតមែនតែខ្ញុំនៅ ទៅនៅសំបូរ នៅក្បែរអាកន្លែងគោកក្តួចហ្នឹង ប៉ុន្តែមិនដឹងជាគេកំណត់ថាអ្នកទោសប្រភេទណាទេ យកទៅដាក់។ ប៉ុន្តែអ្នកនៅគោកក្តួចហ្នឹង មិនសូវរួចខ្លួនទេ។ បាទ ភាគច្រើនគឺគេសម្លាប់ជាក់ស្តែងដូចខ្ញុំជម្រាបពីព្រឹកអីចឹងថាដូច លោកជន, លោកឈីន នេះដែលជាមេឃុំនៅវឌ្ឍនៈ ក្រោយពីលោក អ៊ុង សាម៉ុន នេះក៏គេសម្លាប់នៅគោលក្តួចហ្នឹងដែរ។

[១៤:១៨:៤៨]

**ស៖** តើ អ៊ុង សាម៉ុន ហ្នឹងគឺជាអ្នកណាដែរ? ហើយតើគេចាប់ខ្លួនគាត់នៅពេលណា? ហើយគេបញ្ជូនគាត់ទៅគោកក្តួចហ្នឹងនៅពេលណាដែរ?

**ឆ៖** ចំពោះ អ៊ុង សាម៉ុន នេះគាត់ជាអតីតសន្តិសុខស្រុកសំបូរ។ នៅពេលដែលខ្ញុំត្រូវផ្លាស់ទៅនៅឃុំសំបូរ គេឲ្យ អ៊ុង សាម៉ុន ហ្នឹងទៅធ្វើមេឃុំវឌ្ឍនៈ ហើយក្រោយមកគេចាប់ខ្លួន។ ចាប់ខ្លួន បើតាមខ្ញុំស្មានមើលទៅប្រហែលជាចុង៧៧ហើយ ព្រោះបាត់ខ្លួនទៅ ព្រោះដល់ដើមឆ្នាំ៧៨ ខ្ញុំចុះទៅឃុំវឌ្ឍនៈ ដើម្បីទៅវាស់ស្ទង់រៀបចំកសាងទំនប់ទឹកមួយ អត់ឃើញ អ៊ុង សាម៉ុន ឃើញ ជន និង ឈីន នៅឯនុំងវិញ។ អីចឹងបានន័យថារវាងឆ្នាំ៧៧ ហ្នឹង ដែលចាប់ខ្លួន ព្រោះដើម៧៧ អ៊ុង សាម៉ុន ទៅនៅឃុំវឌ្ឍនៈ ហើយចុង៧៧ អ៊ុង សាម៉ុន ត្រូវគេចាប់។ ហើយ ជន និង ឈីន នេះគឺក្រោយពី អ៊ុង សាម៉ុន ហ្នឹងចាប់ខ្លួនទៅត្រូវ ជន ហ្នឹងនៅសន្តិសុខស្រុកដែរទៅធ្វើមេឃុំនៅវឌ្ឍនៈទៀត ជាមួយ ជា ឈីន ហ្នឹងគាត់នៅនឹងវឌ្ឍនៈស្រាប់។ ហើយដល់មក ប្រហែលជាពាក់កណ្តាល៧៨ ហ្នឹងបានគេចាប់ពីរនាក់ហ្នឹងទៀត។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១៤:២០:៣២]

**សៈ** តើលោកដឹងថាហេតុអ្វីបានជាគេចាប់ខ្លួន អ៊ុំង សាម៉ុន ហើយគេបញ្ជូនគាត់ទៅគោកក្តួចទេ?

**ឆៈ** ចំពោះ អ៊ុំង សាម៉ុន ខ្ញុំក្តាប់មិនបាន មិនដឹងជាមានមូលហេតុអីដែលគេចាប់ បាទ។ តាមខ្ញុំស្មានទេ ប្រហែលជាចាប់តាមខ្សែ។ ពេលគេចាប់ តាចែត ដែលជាលេខាបក្សស្រុក ហើយដែលគេផ្លាស់ពីសំបូរទៅនៅក្រចេះ ហើយគេចាប់ខ្លួនលោក ចែត ហ្នឹងបានគេចាប់ អ៊ុំង សាម៉ុន ហ្នឹងតទៅទៀត ព្រោះជាខ្សែបណ្តាញរបស់គាត់។ ហើយអាពេលចាប់ អ៊ុំង សាម៉ុន ពីវត្តរនះទៅ មិនជាគេយកទៅគោកក្តួច ឬយកទៅណា ខ្ញុំអត់ប្រាកដទេ ចំពោះ អ៊ុំង សាម៉ុន។

[១៤:២១:១៩]

ដោយឡែកលោក ជន និង ឈឹន នេះដែលគេចាប់ទៅនោះ យកទៅគោកក្តួច ហើយលោក ជន លោក ឈឹន គេចាប់ហ្នឹងដូចខ្ញុំបានជម្រាបអ៊ីចឹង មានឈ្មោះ ប៊ុន រាយការណ៍ឲ្យលោក វឿន ថា ជន, ឈឹន ប្រុងក្បត់។ ដល់ប្រុងក្បត់អ៊ីចឹង ចាប់ ជន, ឈឹន ទៅ។ ដល់ក្រោយមករកឃើញថា ជន, ឈឹន ហ្នឹងអត់ក្បត់ទេ ថាអាប៊ុន ហ្នឹងវារាយការណ៍ភូតគេ គេចាប់ អាប៊ុន ទៅវ៉ៃចោលទៅទៀត បាទ។ ខ្ញុំសូមអស់មតិ។

[១៤:២២:០៩]

**សៈ** យើងនឹងនិយាយនៅពេលបន្តិចអំពីការចាប់ខ្លួននិងការបោសសម្អាត។ តើលោកអាចប្រាប់បានដែរឬទេ ថាតើមន្ទីរសន្តិសុខគោកក្តួចហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆៈ** មន្ទីរសន្តិសុខគោកក្តួចនេះនៅក្នុងភូមិកែងប្រាសាទ។ ភូមិកែងប្រាសាទនេះនៅចម្ងាយពីទីរួចស្រុកសំបូរ-- ជាប់នឹងទីរួមស្រុកសំបូរ ខាងត្បូងទីរួមស្រុកសំបូរ ឯមន្ទីរគោកក្តួចនេះមានចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីទីរួមស្រុកសំបូរ ហើយដើរចូលទៅខាងក្នុង បាទឆ្លងទំនប់មួយគេហៅថាទំនប់អូរប៉ាក់។ ផុតពីទំនប់អូរប៉ាក់ហ្នឹងបានដល់គោកក្តួច។ បានន័យថាប្រហែលជាពីរគីឡូម៉ែត្រពីមាត់ទន្លេទៅដល់ទីតាំងហ្នឹង។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**សៈ** ចុះប្រាសាល គឺមន្ទីរសន្តិសុខប្រាស្រាលហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆៈ** ប្រាស្រាលនេះ គឺជាឈ្មោះអូរមួយ។ អូរហ្នឹងគឺមានទំហំធំល្មមដែរ ចម្ងាយពីមាត់ទន្លេទៅបើដើរចំស្រុក-- ទីរួមស្រុកសំបូរបច្ចុប្បន្ននេះប្រហែលជាប្រាំគីឡូម៉ែត្រ យើងអាចទៅដល់មាត់អូរហ្នឹង។ មាត់អូរហ្នឹង គឺនៅខាងលិចមាត់អូរ គឺជាទីតាំងសន្តិសុខរបស់ស្រុកនៅសម័យនោះ។ ហើយឆ្លងអូរហ្នឹងទៅម្ខាងទៀត ជាភូមិថ្មីមួយដែលយកប្រជាពលរដ្ឋពីភូមិកោះរាល ទៅដាក់គោកក្តួចដែរ គោកក្តួចខាង

ប្រជាពលរដ្ឋ មួយគោកក្ដួចខាងសន្តិសុខ។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៤:២៤:២៦]

**ស៖** តើលោកដឹងថា មានមនុស្សប្រហែលប៉ុន្មាននាក់ដែលគេឃុំ ដែលគេទុកនៅមន្ទីរសន្តិសុខគោកក្ដួច និងនៅមន្ទីរប្រាស្រាលហ្នឹង? តើមានមនុស្សប្រហែលប៉ុន្មាននាក់?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ ដូចខ្ញុំបានជម្រាបពីមុនហ្នឹង ខ្ញុំអត់ដែលបានចូលទៅកន្លែងសន្តិសុខហ្នឹង។ ហើយខ្ញុំអត់ ក្ដាប់អត់បានទេ អត់ដឹងថាតើនៅខាងគោកក្ដួចឯណោះមានប៉ុន្មាននាក់? ហើយនៅខាងប្រាស្រាលមានប៉ុន្មាននាក់ទេ។ បាទ សូមអស់មតិ។

**ស៖** តើលោកដឹងថា កម្មាភិបាលរូបណាដែលជាអ្នកប្រតិបត្តិការ ឬក៏អ្នកគ្រប់គ្រងទៅលើមន្ទីរសន្តិសុខនោះ?

**ឆ៖** មន្ទីរសន្តិសុខគោកក្ដួច ពីមុនមាន អ៊ុង សាម៉ុន ហ្នឹង ដល់ អ៊ុង សាម៉ុន ទៅធ្វើមេឃុំនៅវត្តស្បែះទៅ គេឲ្យ គិន ជន ទទួលនាទីខាង-- នៅមន្ទីរសន្តិសុខគោកក្ដួចហ្នឹង។ ដល់គេឲ្យ គិន ជន ហ្នឹងទៅធ្វើមេឃុំវត្តស្បែះក្រោយពីចាប់ អ៊ុង សាម៉ុន ទៅ ខ្ញុំក្ដាប់អត់បាន មិនដឹងជាពីណាឡើងធ្វើទេ ប៉ុន្តែគ្រាន់តែដឹងថា មានម្នាក់ដែលធ្លាប់នៅសហករណ៍-- ធ្វើគណៈសហករណ៍ជាមួយខ្ញុំឈ្មោះ បេ ម៉េងអាន ហ្នឹងគេឲ្យមកនៅគោកក្ដួច ធ្វើជាលេខានៅគោលក្ដួចហ្នឹង។ ហើយគ្រាន់តែដឹងថា មានម្នាក់ឈ្មោះ សារឿនហ្នឹង គាត់នៅប្រចាំការនៅកន្លែងគោកក្ដួចហ្នឹង។ បាទ សូមអស់មតិ។

[១៤:២៦:២៦]

**ស៖** តើលោកដឹងដែរឬទេថា ខាងស្រុកខាងផ្នែកតំបន់នោះ តើផ្នែកតំបន់ហ្នឹងគាត់មានមន្ទីរសន្តិសុខ ឬក៏មន្ទីរលត់ដំផ្ទាល់ខ្លួនរបស់តំបន់ដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងសន្តិសុខនៅតំបន់នេះ ខ្ញុំក្ដាប់អត់បានច្បាស់ទេ។ បាទ មិនដឹងជា មានទីតាំងនោះនៅកន្លែងណា។ ខ្ញុំសូមអស់មតិ។

**ស៖** តើលោកអាចជម្រាបបានដែរឬទេថា នៅពេលដែលគេចាប់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើគេចាប់ខ្លួនប្រជាជនហ្នឹងដោយរបៀបណា? តើលោកអាចជម្រាបឲ្យបានលម្អិតបន្តិចបានទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាចាប់ប្រជាជន ខ្ញុំក្ដាប់មិនសូវបានទេ ប៉ុន្តែបើពាក់ព័ន្ធនឹងចាប់កម្មាភិបាលហៅមកប្រជុំ។ បាទ ដល់ហៅមកប្រជុំរួច គេសុំឲ្យនៅនឹងកន្លែងហ្នឹងសិនទៅបាទ។ បើថាគេឃាត់អត់

ឲ្យទៅវិញ បានន័យថា ចាប់ខ្លួនហើយ។ ឯប្រជាពលរដ្ឋគេឲ្យ ដូចជាម្នាក់នៅខាងខ្ញុំនោះ មិនជាប្រជាពលរដ្ឋទេ វាជាគណៈដែលហ្នឹង គេឲ្យសន្តិសុខស្រុកហ្នឹងអ្នកទៅយក បាទ ទៅហៅ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ នៅដែលលោកនិយាយថា សម្រាប់កម្មាភិបាលគឺគេនឹងធ្វើការប្រជុំ។ តើលោកចង់មានន័យថា គេហៅទៅមន្ទីរស្រុកដើម្បីប្រជុំ ហើយចាប់ខ្លួននៅទីនោះ តើបែបហ្នឹងមែនទេ?

**ឆ៖** បាទៗ ដូចអ៊ីចឹងហើយ គេហៅចូលទៅកន្លែងមន្ទីរគេហ្នឹង ទៅដល់ប្រជុំរួចអ្នកណាដែលត្រូវគេចាប់ខ្លួន គេឃាត់នៅនុំងតែម្តង។

**ស៖** លោកបានប្រាប់យើងរួចមកហើយ នៅពេលព្រឹកនេះ ថា គឺនិយាយអំពីហេតុការណ៍ទាក់ទងនឹង តាឈី-- ឥឡូវនេះ-- តាឈីម-- ឥឡូវនេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ ដើម្បីឲ្យច្បាស់ ថាតើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ ដែលថា គេឲ្យលិខិតទៅ តាឈី ហើយហៅគាត់មកមន្ទីរស្រុកនោះ។ តើត្រឹមត្រូវដែរឬទេ?

[១៤:២៩:២២]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកមានឃើញ តាឈី ម្តងទៀតទេ បន្ទាប់ពីគាត់ទៅមន្ទីរស្រុករួចហើយហ្នឹង ក្រោយមកហ្នឹង តើលោកដែលឃើញ តាឈី ទៀតទេ?

**ឆ៖** ខ្ញុំអត់ដែលបានឃើញគាត់ទៀតទេបាទ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយដល់រយៈពេលចុងឆ្នាំ៧៧ និងដើមឆ្នាំ៧៨។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ថា បានបញ្ជាក់ពីកម្មាភិបាលមួយចំនួនដែលត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួននៅក្នុងរយៈពេលនោះ។ ឥឡូវនេះខ្ញុំចង់លើកយកចំណុចនេះ ហើយសួរលោកបញ្ហាជាក់លាក់មួយចំនួន ទាក់ទងទៅនឹងហេតុការណ៍ទាំងអស់នោះ។ ឥឡូវនេះខ្ញុំសូមចាប់ផ្តើមជាមួយនឹងផ្នែកតំបន់ គឺបុគ្គលដែលស្ថិតនៅក្នុងគណៈតំបន់។ តើលោកអាចជម្រាបយើងបានដែរឬទេ ថាតើមានអ្វីកើតឡើងចំពោះលេខាតំបន់ឈ្មោះ យី នៅក្នុងដើមឆ្នាំ៧៨?

**ឆ៖** សភាពការណ៍នៅក្នុងខេត្តក្រចេះហ្នឹង គឺមានការច្របូកច្របល់នៅដើមឆ្នាំ៧៨ ហ្នឹង។ លោក យី ហ្នឹងគាត់ជាលេខាបក្សខេត្ត អ៎!បក្សតំបន់ ជាលេខាតំបន់ ហើយនៅឆ្នាំ៧៨ ហ្នឹង គឺខាងយោធាចូលទៅហ្នឹង គឺចាប់ទាំងអស់ ហើយលោក យី ហ្នឹងមិនដឹងគេចាប់បាននៅឯណា ឮ គ្រាន់ឮថាបើកកាណូតមកភ្នំពេញ ហើយគេចាប់តាមផ្លូវទៅ។ ឯលោក គួន នោះគេចាប់នឹងកន្លែង។ ឯអ្នកផ្សេង

ទៀត ខ្ញុំក្តាប់មិនបានដែរ។ ប៉ុន្តែក្រោយពីសភាពការណ៍ហ្នឹង ដូចជានៅសំបូរអីអ៊ីចឹង ឈ្មោះ ភឿន ឈ្មោះ នី អីហ្នឹងគេចាប់នៅនឹងកន្លែងស្រុកហ្នឹងតែម្តង។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៤:៣១:៥៦]

**ស៖** ឥឡូវនេះ នៅពេលដែលលោកនិយាយថា ស្ថានភាពនោះវាច្របូកច្របល់នៅដើមឆ្នាំ១៩៧៨ តើលោកចង់សំដៅច្របូកច្របល់ដូចម្តេច?

**ឆ៖** ស្ថានភាពច្របូកច្របល់នៅដើមឆ្នាំ៧៨ នេះគឺ ខាងយោធាទៅហ្នឹងគឺកាន់កាប់អំណាចម្តង ចាប់ពួកអ្នកគណៈស្រុក គណៈខេត្តពីមុន បាទ។ ច្របូកច្របល់អ៊ីចឹង។ ដល់អ៊ីចឹងរត់-- ខ្លះរត់លូន ពួនសំងំនៅក្នុងខេត្តហ្នឹងស្ងាត់ជ្រងំហើយ។ ខ្ញុំដឹងតាមគេដែរ នៅស្រុកក៏អ៊ីចឹងដែរ ព្រោះខ្ញុំនៅនឹងកន្លែងស្រុកដែរអង្កាល់ហ្នឹង។ ដូចនៅកន្លែងខ្ញុំអីចាប់តាំងពីអនុប្រធានខ្ញុំ ចាប់តាំងពីមន្ទីរពេទ្យខ្ញុំ ដោយឡែកខ្ញុំអីគេអត់ចាប់ផងអង្កាល់ហ្នឹង។ កុំអីអត់បានមកទេ។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** តើគេចាប់មនុស្សច្រើនទេ នៅក្នុងសម័យពេលនោះនោះ?

**ឆ៖** ក្នុងសភាពការណ៍ហ្នឹង គឺចាប់ភាគច្រើនចាប់ថ្នាក់ដឹកនាំ។ បាទ ថ្នាក់ដឹកនាំស្រុក គឺចាប់អត់មានសល់ទេ។ ថ្នាក់ដឹកនាំខេត្តក៏អត់មានសល់ដែរ។ បាទ ហើយក្រៅពីហ្នឹងក្នុងឃុំក៏មានចាប់ខ្លះដូចជានៅឃុំខ្ញុំហ្នឹងចាប់ពេទ្យខ្ញុំ។ ពេទ្យនៅនឹងឃុំហ្នឹងក៏ចាប់ដែរ ប្រធានពេទ្យ។ រួចខ្ញុំអត់ដឹងគេចាប់រឿងអីផង រឿងចាប់ប្រធានពេទ្យនៅឃុំខ្ញុំអីហ្នឹង ស្រាប់តែបាត់។ ដល់សភាពការណ៍វាស្ងប់ស្ងាត់ទៅស្រាប់តែបាត់មនុស្សមួយចំនួន។ ខ្ញុំសូមអស់មតិ។

[១៤:៣៣:៥៧]

**ស៖** នៅពេលដែលលោកនិយាយថា យោធាគេចូលមកកាន់ក្តាប់អំណាចនោះ គឺថា ធ្វើការចាប់ខ្លួនមនុស្សនោះ តើលោកនិយាយសំដៅពួកយោធាហ្នឹងប្រធានគេហ្នឹងគឺឈ្មោះអ្វី? កងពល? មកពីៗតំបន់ផ្សេងទៅក្រចេះ ឬក៏យោធាមកពីខាងណា?

**ឆ៖** កាលពីពេលនោះគឺមាន យោធា គឺថាពាក់អាវពណ៌បៃតង។ បៃតងហ្នឹងគេថាមកពីភូមិភាគណាទេ ខ្ញុំដូចជាភ្លេចភ្លាំងដែរ។ ពួកហ្នឹងនិយាយជាមួយនឹងប្រជាពលរដ្ឋថា “ញោម”ៗ។ បាទ និយាយ ញោមៗ ហ្នឹង។ ហើយយោធាខេត្តក្រចេះក៏គេចាប់ដែរ មិនមែនតែចាប់តែយោធាដែល-- មិនមែនចាប់តែគណៈឯណា ចាប់ទាំងយោធាមេៗ គេចាប់ទាំងអស់។ មេយោធានៅនឹងខេត្តហ្នឹង។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** លោកបានបញ្ជាក់ប្រាប់យើងខ្ញុំពីខាងដើមថា បុគ្គលម្នាក់ឈ្មោះនៅថ្នាក់តំបន់នោះ គឺ ឈ្មោះ ឃឿន ដែលជាអ្នកទទួលខុសត្រូវខាងយោធា បាទ គឺឈ្មោះ គួន។ បាទ ក្រោយមក គួន ហ្នឹង គាត់ជួបបញ្ហាអ្វីនៅក្នុងពេលដែលថាគេចាប់មនុស្ស ដែលថាបោសសម្អាតហ្នឹង?

**ឆ៖** នៅពេលបោសម្អាតហ្នឹង គួន ហ្នឹង គេចាប់ បាទ។ ខ្ញុំឮថា គេចាប់បោសសម្អាតវិញដែរ។ ចាប់ទៅ បាត់ខ្លួនរហូតមិនដែលបានជួប ហើយឈ្មោះ ភឿន នោះ វាជាយោធាស្រុកទេ ហ្នឹងក៏គេចាប់ ដែរ។

**ស៖** ខ្ញុំនឹងសួរលោកអំពីមនុស្សនៅក្នុងឋានៈស្រុក។ ប៉ុន្តែឥឡូវនេះ ខ្ញុំសូមសួរលោកតែនៅក្នុង តំបន់។ មនុស្សមួយផ្សេងទៀត ដែលលោកបាននិយាយឈ្មោះដែរនោះ គឺនៅគណៈតំបន់នោះ គឺ កង។ កង គឺនៅនោះ។ តើ កង ហ្នឹង នៅពេលដែលមានចលាចលហ្នឹង គឺ កង ហ្នឹង យ៉ាងម៉េចដែរ?

[១៤:៣៦:៣០]

**ឆ៖** កង ទទួលសន្តិសុខមួយខេត្ត គឺតាមខ្ញុំដឹង ដូចជាចាប់ខ្លួនតាំងពីមុនសភាពការណ៍ ដែល ចាប់ គួន ហ្នឹងទៀត។ បាទ បាត់ខ្លួនដូចបន្តបន្ទាប់តាំងពីជាមួយ ចែត ម៉្លេះបាទ។ តាមមើលបាត់ខ្លួនតាំង ពី៧៦។

**ស៖** ដើម្បីរំឭកការចងចាំពីពេលវេលានៃការចាប់ខ្លួននោះ ខ្ញុំសូមជម្រាបលោកថា យើងមាន នៅក្នុងឯកសារសំណុំរឿង គឺថាចម្លើយសារភាព ស-២១ មកពី បាន សារឿន ហៅ គង់ ប្រធាន តំបន់៥០៥ ពីខែកុម្ភៈ ឆ្នាំ១៩៧៨។ យើងក៏មានបញ្ជីអ្នកទោស ស-២១ ឈ្មោះ ឃួន-- គួន ជាលេខា អនុលេខាដែលទទួលបន្ទុកខាងយោធា ដែលបញ្ជាក់ថា គាត់ចូលដល់ ស-២១ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៨។ ហើយយើងក៏មានកំណត់ត្រាដែលចង្អុលបង្ហាញថា លេខាឈ្មោះ យី ក៏បានមកដល់ ស-២១ នៅថ្ងៃដប់ពីរ-- អ៎! ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៨៧ ហើយគាត់ចុះហត្ថលេខាលើចម្លើយសារភាពនៅ ខែមេសា ឆ្នាំ១៩៧៨។ អ្វីដែលខ្ញុំចង់សួរលោកនោះ គឺថាកាលបរិច្ឆេទដែលខ្ញុំលើកឡើង គឺពីខែកុម្ភៈ ដល់ ខែមីនា ឆ្នាំ១៩៧៨។ តើវាស្រប ស៊ីសង្វាក់ទៅនឹងការចងចាំរបស់លោកទេ ទាក់ទងទៅនឹងការចាប់ខ្លួន មនុស្សចេញពីតំបន់ដែលលោកនៅនោះ បាទ?

[១៤:៣៨:៤១]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ គឺតាមឯកសារហ្នឹង ខ្ញុំសូមស្របហើយ ពីព្រោះខ្ញុំមិនច្បាស់លាស់។ ខ្ញុំដឹងតែថា ដើមឆ្នាំ៧៨ហ្នឹង បាទ។ អ៊ីចឹង វានៅក្នុងវង្វង់ហ្នឹងដែរ។ បាទ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**លោក ខេល លីសាក់៖**

មុននឹងសម្រាក លោកប្រធាន ខ្ញុំសូមអានឯកសារសំណុំរឿង គឺឯកសារ ស-២១ គឺដែលខ្ញុំយោងគឺចំពោះ កង ជាប្រធានសន្តិសុខហ្នឹង គឺថានៅក្នុងបញ្ជីសួរចម្លើយចុះថ្ងៃទី០២ កុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ D108/26.147។ ចម្លើយសារភាព ស-២១ ចុះថ្ងៃ២៣ កុម្ភៈ ឆ្នាំ១៩៧៨ ឯកសារ D159/5.3។

[១៤:៣៩:៥៧]

ចំពោះអនុលេខាស្រុក-- អនុលេខាឈ្មោះ គួន នោះ គឺថាបញ្ជីអ្នកទោស ស-២១ ចង្អុលបង្ហាញថា គាត់ចូលថ្ងៃទី២១ មីនា ឆ្នាំ១៩៧៨ ឯកសារ IS16.71។ ហើយបញ្ជីចម្លើយសារភាព ស-២១ របស់គាត់ គឺចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៨ ឯកសារ D366/7.1.1.16។ ហើយនិងលេខាស្រុកឈ្មោះ យី គឺយើងចម្លើយសារភាពនៅស-២១ របស់គាត់ គឺឯកសារ D159/5.6 ហើយនិងគាត់បានមកដល់ៗបញ្ជី ស-២១ ដែលកែតម្រូវដោយសហព្រះរាជអាជ្ញា គឺ E3/342 នៅទំព័រ 0029(ស៊ីក) ហើយនិងឯកសារ បាទ 00329602 ហើយនិងលេខរៀង ១៥១ នៅលើបញ្ជីនោះ។

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរបន្ត ឬក៏ខ្ញុំអាចចាប់ផ្តើមបន្ទាប់ពីសម្រាក បាទ?

[១៤:៤១:២៤]

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវី ក៏មេធាវីប្រឹក្សាសាក្សីនៅបន្ទប់រង់ចាំសម្រាកសាក្សីនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២នាទី ដល់ម៉ោង១៥:០៣នាទី)*

[១៥:០៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមអរគុណចំពោះសាក្សីដែលបានខិតខំប្រឹងប្រែងឆ្លើយតបនឹងសំណួរ ហើយនិងបានអនុវត្តល្អនូវការពន្យឺតពេលវេលាក្នុងការឆ្លើយតបនូវពេលវេលាដែលបាន-- ក្បាលមីក្រូបានធ្វើប្រតិបត្តិការទើបឆ្លើយ។ ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកបន្ថែមថា ដើម្បីឲ្យល្អជាងនេះទៀតហ្នឹង គប្បីនិយាយឲ្យបានយឺតជាមុនបន្តិចទៀតរឹតតែល្អ ពីព្រោះមានបញ្ហាក្នុងការបកប្រែ។ ហើយអង្គជំនុំនឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយអង្គជំនុំជម្រះអាចជម្រាបដល់អង្គជំនុំជម្រះបានទេ តំណាងសហព្រះរាជអាជ្ញា ថាតើក្រុមតំណាងសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ?

[១៥:០៥:១៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងបញ្ចប់នៅថ្ងៃនេះ គឺមួយល្ងាចនេះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តការតាំងសំណួរដេញដោល តំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន និងលោក លោកស្រីចៅក្រម។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក យុន គីម យើងបានពិភាក្សាគ្នាអំពីការចាប់ខ្លួនសមាជិកគណៈតំបន់៥០៥។ បញ្ហាបន្ទាប់ ដែលខ្ញុំចង់សួរលោកនោះគឺថាតើលោកបានដឹង ឬក៏មិនបានដឹងអំពីប្រពន្ធរបស់លេខា យី និង អនុលេខា គួន ប្រពន្ធរបស់គាត់ ជួបនូវជោគវាសនាដូចម្តេចដែរ?

[១៥:០៦:២០]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងគ្រួសារកម្មាភិបាលថ្នាក់តំបន់ ដែលត្រូវចាប់ខ្លួននេះ ចំពោះបញ្ហាចាប់ខ្លួន ឬមិនចាប់ខ្លួននោះ ខ្ញុំអត់បានដឹង បាទអត់បានដឹងថាតើវាសនាអ្នកទាំងអស់នោះយ៉ាងណាទេបាទ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** ខ្ញុំនឹងជួយរំឭកការចងចាំរបស់លោក គឺថាបញ្ជីរាយឈ្មោះអ្នកទោស ស-២១ ឯកសារ D108/6.296 គឺបញ្ជីអ្នកទោសជាស្ត្រី មានមនុស្សពីរនាក់ដែលគេរាយនៅលើបញ្ជីនេះ ដែលខ្ញុំនឹងចង់សួរលោក ទីមួយឈ្មោះគាត់នោះ ឈ្មោះ ហឿន ហៅ កេង ដែលគេដាក់ថាសមាជិកនៃ-- ហើយសមាជិកគណៈតំបន់ ហើយប្រពន្ធរបស់អា យី គេដាក់អ៊ីចឹង។ គឺថាបញ្ជីនេះ ក៏បង្ហាញថាគាត់មកដល់ ស-២១ ឈ្មោះ ប៊ុន ឡេ ហៅ-- បញ្ជាក់ថា គាត់ជាប្រធានក្រុមដេរ ហើយជាប្រពន្ធរបស់អា គួន។ តើលោកបានដឹងថា ប្រពន្ធរបស់ យី និង គួន ហ្នឹងក្រោយមកបាត់ ឬក៏យ៉ាងដូចម្ដេចទេ?

[១៥:០៨:០៧]

**ឆ៖** ខ្ញុំសូមជម្រាបថា គ្រួសាររបស់ យី និង គួន នេះខ្ញុំអត់បានស្គាល់ពួកគាត់ផងបាទ អត់បានស្គាល់ទេ អ៊ីចឹងបាត់ មិនបាត់ ខ្ញុំអត់បានដឹង។ បាទ សូមមានមតិប៉ុណ្ណឹង។

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ ថាជាធម្មតាទេ កាលណាកម្មាភិបាលត្រូវបានគេបោសសម្អាត ហើយប្រពន្ធ ឬក៏ប្ដីក្រុមគ្រួសារហ្នឹងត្រូវបានគេចាប់ខ្លួនបន្ទាប់ហ្នឹងដែរ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ គឺមានកម្មាភិបាលខ្លះ ដូចជាបាត់ទាំងប្រពន្ធ បាត់ទាំងកូន។ ប៉ុន្តែមានកម្មាភិបាលថ្នាក់ស្រុកមួយចំនួន គេចាប់យកតែបុគ្គលហ្នឹងទៅ ឧទាហរណ៍ដូចជា អ៊ំ សាម៉ុន គាត់អតីតកម្មាភិបាលផ្នែកសន្តិសុខនៅសំបូរហ្នឹង គេចាប់តែខ្លួនគាត់ទេ ប្រពន្ធគាត់នៅ។ ឯនៅតាមសហករណ៍អ៊ីចឹងដែរ ដូច ជន ហើយនិង ឈឿន អីគេចាប់តែ ជន និង ឈឿន ប្រពន្ធនៅបាទ។ នេះខ្ញុំបានឃើញតែអ៊ីចឹង។ មានខ្លះក៏បាត់ទាំងអស់ ខ្លះក៏មាននៅ។ ខ្ញុំសូមអស់មតិ។

[១៥:០៩:៤៥]

**ស៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់បានឮពាក្យស្លោកបដិវត្តន៍ថា "កាលណាយើងដកស្មៅ យើងដកយកទាំងឫស"។ តើលោកធ្លាប់ឮពាក្យហ្នឹងដែរឬទេ?

**ឆ៖** ពាក្យហ្នឹងធ្លាប់ពួកខាងស្រុកគេនិយាយអ៊ីចឹងដែរ គេថាបើដកស្មៅ ឱ្យដកទាំងឫស បាទមានធ្លាប់ ធ្លាប់ឮសួរបាទ។ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**សៈ** តើលោកយល់ពាក្យស្លោកនោះមានន័យដូចម្ដេចទេកាលនោះ?

**ឆៈ** កាលនោះ ខ្ញុំយល់ថា ពាក្យស្លោកនេះ ជាពាក្យស្លោកមួយដែលមានសភាពធ្ងន់ធ្ងរ បានន័យថា ឧទាហរណ៍ថា បើមានចាប់កម្មាភិបាលណាមួយហើយ អ្នកដែលពាក់ព័ន្ធជាខ្សែបណ្ដាញ បានន័យថា បដិវត្តន៍គេចូលបន្តគ្នា ទាក់ទងគ្នា ឧបមាចូលតាមរយៈអ្នកនេះ ចូលតាមរយៈអ្នកនោះ បើអ្នកនាំគេចូលហ្នឹងត្រូវចាប់ខ្លួនហើយ អ្នកដែលខាងក្រោមហ្នឹង ដូចជាអត់ស្វរួចខ្លួនដែរ។ អាបញ្ហានេះហើយដែលធ្វើឲ្យមនុស្សស្លាប់ ស្លាប់ច្រើន ដោយចាប់ជាខ្សែសង្វាក់ទៅតាមរយៈអ្នកដែលនាំចូលហ្នឹង។ ខ្ញុំសូមអស់មតិ។

[១៥:១១:២២]

**សៈ** សូមអរគុណលោក យុន គីម។ ឥឡូវនេះយើងនិយាយអំពីមនុស្សដែលគេបាន ត្រូវបានគេចាប់ខ្លួននៅថ្នាក់តំបន់ នៅដើមឆ្នាំ១៩៧៨។ ឥឡូវនេះ ខ្ញុំត្រឡប់ទៅរកឈ្មោះមនុស្សមួយចំនួនដែលលោកបានបញ្ជាក់ថា នៅក្នុងឃុំសំបូរ ស្រុកសំបូរ។ មនុស្សមួយចំនួនដែលខ្ញុំនឹងសួរហ្នឹង គឺថាមនុស្សពីរនាក់ដំបូង លោកបានបញ្ជាក់ថា មនុស្សម្នាក់ឈ្មោះ នី ជាប្រធានមន្ទីរសន្តិសុខស្រុក ហើយជាស្ដីទីជាដើមហ្នឹង។ ហើយលោកបានបញ្ជាក់ម្នាក់ទៀតឈ្មោះ ភឿន។ បាទៗ ភឿន ហ្នឹងដែលជាប្រធានមន្ទីរសន្តិសុខស្រុក ថាតើ នី និងភឿន ហ្នឹងដើមឆ្នាំ១៩៧៨ហ្នឹង តើពួកគាត់មានបញ្ហាដូចម្ដេចដែរ?

**ឆៈ** ឈ្មោះ នី។ នីហ្នឹងគឺមិនមែនជាផ្នែកសង្គមកិច្ច គឺគាត់ជាទទួលខាងសេដ្ឋកិច្ច ហើយនិងជាដល់ក្រោយមក គឺគាត់ដូចជាប្រធានស្រុកផង ទទួលសេដ្ឋកិច្ចផងក្រោយពី ផាន ត្រូវផ្លាស់ទៅក្រចេះមក ហើយមានមកកម្មាភិបាលមួយទៀតឈ្មោះ ម៉ុក ហ្នឹងដល់ ម៉ុក ហ្នឹងគេចាប់បាត់ទៅ តានី ហ្នឹងគាត់ទទួលខុសត្រូវ។ តានី ហ្នឹងអ្ហឹ ហើយនិង ភឿន ភឿនហ្នឹងទទួលខាងយោធា។ យោធាផង ក៏ដូចជាសន្តិសុខផងពេលហ្នឹងវា ព្រោះកម្លាំងនៅខ្វះ។ អ៊ីចឹងពួកពីរនាក់នេះ គេចាប់ក្នុងសភាពការណ៍ដើមឆ្នាំ៧៨ហ្នឹង ក្រោយពីគេចាប់ឈ្មោះ យី និងឈ្មោះ គួន ទៅឈ្មោះ នី ហើយនិងឈ្មោះ នែ៎! ភឿនហ្នឹងក៏ត្រូវចាប់ខ្លួនទៀត។ ហើយឈ្មោះ នី និងឈ្មោះ ភឿន ហ្នឹងគាត់រត់ហើយដំបូង។ ស្រាប់តែដល់ពេលគេអំពាវនាវឲ្យមកវិញ គាត់មកចូលអាកន្លែងស្រុក។ បាទ ស្រាប់តែបាត់ខ្លួនរហូតទៅ មិនដឹងជាគេយកទៅខាងណា។ ប៉ុន្តែដោយឡែកឈ្មោះ នី ប្រពន្ធគាត់នៅទេ នៅរាល់ថ្ងៃ។ អ៊ូ!ឈ្មោះ នី អត់ទេ ដូចអត់ឃើញនិងប្រពន្ធដែរ។ ប៉ុន្តែមិនដឹងគេចាប់ ឬមិនចាប់មិនដឹងទេ។ ខ្ញុំអត់ដែលបានជួបប្រពន្ធគាត់។ នេះ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១៥:១៤:០២]

**លោក ខេល លីសាក់៖**

ខ្ញុំចង់បង្ហាញជូនលោកនូវឈ្មោះមនុស្សមួយចំនួននៅមន្ទីរអ្នកទោសស-២១ ដើម្បីឲ្យលោកស្ដាប់មើល៍ តើលោកនឹកឃើញថា តើទាក់ទងទៅ នី និងភឿន ដែរឬទេ?

លោកប្រធាន ជាដំបូង គឺឯកសារ ខ្ញុំចង់បង្ហាញជូនសាក្សីនោះ គឺ IS16.116 នៅខ្មែរ ERN 00039750 ហើយអង់គ្លេស ERN 00233693 ហើយនិង ហើយដើម្បីសន្សំពេលនោះខ្ញុំសូមអនុញ្ញាតជូនសាក្សីនូវទំព័រមួយ ឯកសារ D108/26.202។ នៅខ្មែរទំព័រលេខ 00088655 បាទ គឺទំព័រលេខបីនៅក្នុងឯកសារនោះ អង់គ្លេសហ្នឹងគឺលេខ ERN 00167743 បាទ ហើយខ្ញុំសូមអនុញ្ញាតជូនឯកសារលើក្រដាសទៅសាក្សី ហើយនិងសូមអនុញ្ញាតបង្ហាញឯកសារនៅលើអេក្រង់ដើម្បីភាគីបានពិនិត្យផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[១៥:១៦:០០]

**លោក ខេល លីសាក់៖**

លោកប្រធាននៅពេលដែល-- ខ្ញុំចង់បង្ហាញឯកសារទីមួយនេះ គឺខ្ញុំចង់បង្ហាញ គឺថាឯកសារ IS16.116 ហើយទំព័រខ្មែរហ្នឹងគឺ 00039750។ បាទ សូមអនុញ្ញាតតុលាការបង្ហាញឯកសារនេះនៅលើអេក្រង់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោក យុន គីម នៅក្នុងឯកសារដែលបញ្ជាក់ថា ឯកសារ IS16.116 នោះ គឺជាបញ្ជីអ្នកទោស ស-២១ ដែលបានសួរចម្លើយនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៨ នៅទំព័រលេខ 00039750 ដែលមនុស្សមួយចំនួនដែលមានឈ្មោះថា នៅក្នុងនោះមានឈ្មោះថា ផង់ នី ដែលគេបញ្ជាក់ថា សមាជិកស្រុកសំបូរ ហើយបញ្ជាក់ថាគាត់ចូល ស-២១ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៧៨។ តើលោកនៅនឹក

ឃើញឈ្មោះ នី ដែលលោកបានឆ្លើយប្រាប់តុលាការថ្ងៃថា នី ហ្នឹង តើ នី ហ្នឹងដែរឬទេ?

[១៥:១៧:៥១]

**ឆ៖** បាទ ពិតជា នី ហ្នឹងហើយ។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** នៅក្នុងឯកសារមួយទៀតដែលខ្ញុំបានផ្តល់ជូនលោកនោះ ដែលឯកសារ D108/26.202 ហើយលោកចង់មើលក្នុងទំព័រលេខ៣នោះ គឺនៃឯកសារនេះ នេះជាបញ្ជីអ្នកទោស ស-២១ ដែលគេសួរចម្លើយនៅថ្ងៃទី០៧ ខែ-- ថ្ងៃ១១ ខែ៤ (ស៊ីក) ឆ្នាំ៧៨ បាទ ដែលមានឈ្មោះថា អៀ សារាយ ហៅ ភឿន ដែលគេបញ្ជាក់ថា សមាជិកស្រុកសំបូរ តំបន់១០៥ (ស៊ីក) ដែលចូលដល់មន្ទីរ ស-២១ គឺថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ តើលោកនៅចាំទេ ភឿន នេះជា ភឿន ដែលលោកបាននិយាយក្នុងការបញ្ជាក់ប្រាប់តុលាការថ្ងៃនេះដែរឬទេ?

[១៥:១៩:០៧]

**ឆ៖** បាទ ពិតហើយជា ភឿន ហ្នឹងហើយបាទ។ សូមអស់មតិ។

**ស៖** លោកបានជម្រាបសហចៅក្រមស៊ើបអង្កេតថា នី ហើយនិង ភឿន នោះត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួននៅក្នុងប្រហែលពេលជាមួយគ្នាហ្នឹង ហើយបញ្ជីដែលខ្ញុំនឹងបង្ហាញជូនលោកហ្នឹង គឺថា នី មកដល់ ស-២១ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៧៩-- អឺ! ៧៨ ហើយ ភឿន មកដល់នៅថ្ងៃទី០១ ខែ អឺ! ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ តើនេះវាស្របទៅនឹងការចងចាំរបស់លោកថា ពួកគាត់នោះបាត់ខ្លួនក្នុងរយៈកាលហ្នឹងដែរឬទេ?

[១៥:២០:០០]

**ឆ៖** បាទ នេះស្របៗពេលវេលាហើយ ព្រោះក្រោយពីគេចាប់គណៈតំបន់៥០៥រួច គេចាប់ពួកយី អំ ពួក នី ហើយនិង ភឿន ហ្នឹងបន្តទៀត។ បាទ សូមអស់មតិ។

**ស៖** តើលោកបានដឹងពីការចាប់ខ្លួនរបស់ នី និង ភឿន ហ្នឹងដឹងដោយរបៀបណា?

**ឆ៖** ការចាប់ខ្លួនរបស់ ភឿន និង នី នេះគឺនៅពេលដែលខ្ញុំទៅប្រជុំនៅកន្លែងស្រុក។ ថ្ងៃនុំងគឺ ភឿន និង នី ហ្នឹងចូលទៅកន្លែងនុំងតែម្តង។ ដំបូងគាត់រត់ៗបាត់យូរក្រែលដែរ ប្រហែលជាមួយអាទិត្យអីជាង ស្រាប់តែរួចទៅមានខាងស្រុកហ្នឹង គេអំពាវនាវថាឲ្យគាត់មក ដល់គាត់មកគេអត់ធ្វើអីទេ។ ដល់មកដល់គេស្រាប់តែចាប់យកទៅបាត់អស់បាទ។ ខ្ញុំសូមអស់មតិ។

**ស៖** តើពួកគាត់ទាំងពីរនាក់ហ្នឹងគេចាប់ខ្លួននៅក្នុងពេលប្រជុំហ្នឹងតែម្តងឬ?

[១៥:២១:២៨]

**ឆ៖** ពេលប្រជុំដែលពួកខ្ញុំទៅប្រជុំហ្នឹង គេអត់ឲ្យគាត់ចូលទៅប្រជុំទេ ថ្ងៃហ្នឹងគេឲ្យគាត់អង្គុយនៅលើក្នុងរោងមួយ ក្នុងរោងមួយដោយឡែកទេ។ ដល់ពួកខ្ញុំចេញផុតអស់មក បានគេហៅទៅមិនដឹងជាចាប់ចង ឬក៏យ៉ាងម៉េច ខ្ញុំអត់ដឹងដែរ ប៉ុន្តែគ្រាន់តែដឹងថា ពួកខ្ញុំចេញអស់ហើយបានគាត់-- ពួកគាត់គេហៅចូលទៅ គេគ្រាន់តែឲ្យមានអ្នកយាមគាត់នៅខាងក្រៅ មុនពេលដែលពួកខ្ញុំប្រជុំចប់។ ខ្ញុំសូមអស់មតិ។

**ស៖** ថាតើអ្នកណាដែលជាអ្នកចាប់ពួកគាត់នៅពេលដែលលោកចេញពីប្រជុំនោះមកនោះ?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ថា តើអ្នកណាចាប់ ប៉ុន្តែគ្រាន់ដឹងពេលនោះគឺមានលោក វឿន ហ្នឹងជាប្រធាន ហើយលោក ឈូក ជាអនុប្រធានស្រុកទទួលខាងយោធា។ ខ្ញុំសូមអស់មតិ។

**ស៖** សូមអរគុណលោកសាក្សី។ លោកក៏បាននិយាយថ្ងៃនេះផងដែរ អំពីបុគ្គលម្នាក់ឈ្មោះ ផាន ដែលជា-- នៅពេលមួយគឺជាៗប្រធានស្រុកសំបូរ ហើយលោកបាននិយាយថា ក្រោយមកគាត់ក្លាយទៅជាលេខាស្រុក ស្រុកក្រចេះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយទៀត គឺIS16.104 ហើយខ្មែរ ERN នោះគឺ 00039737, អង់គ្លេស ERN 00802413 ហើយដូចដែលពីមុនដែរ ខ្ញុំនឹងសូមជូនឯកសារលើក្រដាសទៅលោកសាក្សី ហើយនិងសូមអនុញ្ញាតតុលាការដើម្បីបង្ហាញឯកសារលើអេក្រង់ផងដែរ។

[១៥:២៣:៥១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំបានជូនទៅលោកសាក្សីនោះ គឺៗបញ្ជីអ្នកទោស ស-២១ ដែលសួរចម្លើយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨។ ហើយនៅក្នុងឯកសារខ្មែរ ERN នោះគឺទំព័រ 00039737 គឺបុគ្គលម្នាក់ដែលឈ្មោះ ដែលគេដាក់នៅក្នុងបញ្ជីនោះឈ្មោះ ឈី ហ៊ា ហៅ ផាន សមាជិកស្រុកក្រចេះ តំបន់--បាទដែលចូលមកដល់ស-២១ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨។ តើលោកអាចជម្រាបតុលាការបាន

ដែរទេ ដែលថាហ្នឹងជាឈ្មោះ ផាន ដែលលោកបានឆ្លើយប្រាប់តុលាការថ្ងៃនេះនោះ? មែនឬទេ?

**លោក យុន គីម៖**

**ឆ៖** បាទ ឈ្មោះ ហ៊ា នេះគឺប្រាកដជាឈ្មោះ ផាន ហ្នឹងហើយបាទ។ គាត់ឈ្មោះដើមគាត់ឈ្មោះ ហ៊ា អ៊ីចឹង បាទ ឪពុកគាត់ចិន ម្ដាយគាត់កួយ។ បាទ ហើយគាត់មកធ្វើលេខាបក្សស្រុកក្រចេះក្រោយពីគាត់ធ្វើលេខានៅ-- ប្រធានស្រុកសំបូរ ត្រូវបានមកក្រចេះ ហើយក្រោយមកបានត្រូវចាប់ខ្លួន។ បាទ ខ្ញុំសូមអស់មតិ។

[១៥:២៥:៥៣]

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេ អំពីពេលវេលាដែលគេចាប់ខ្លួន យី នេះហើយពេលដែលគាត់បាត់ខ្លួននោះ ដែលហៅ ផាន ហ្នឹងគឺក្នុងអំឡុងពេលណាដែរបាទ?

**ឆ៖** ការចាប់ខ្លួនឈ្មោះ ផាន នេះគឺចាប់នៅពេលដែលគេចាប់ យី គួន ហើយ គេមកចាប់ ផាន មុនគេ។ ផាន នេះពីមុនគាត់នៅធ្វើជាប្រធានស្រុកសំបូរ ក្រោយមកគាត់មកធ្វើប្រធានស្រុកក្រចេះ ហើយនៅពេលដែលគេប្រមូលកម្មាភិបាល គេចោទថាកម្មាភិបាលដែលមិនល្អ ធ្វើជាអ្នកទោសហ្នឹង យកទៅដាក់នៅ ប-៣ កន្លែងដែលខ្ញុំទៅនៅហ្នឹង។ មុនខ្ញុំទៅនៅហ្នឹង គឺគេដក ផាន ពីចៅហ្វាយស្រុកក្រចេះមកធ្វើជាអ្នកទោសដែរ ដើម្បីដឹកនាំក្រុមអ្នកទោសទាំងអស់នៅដែលជាកម្មាភិបាលហ្នឹងនៅប-៣ ហ្នឹង។ ហើយដល់ពេលគេចាប់ មិត្តភក្តិខ្ញុំមួយចំនួនដែលគេដឹង គេប្រាប់ថា គ្រាន់តែចាប់ខាងតំបន់ឯណោះរួច ស្រាប់តែមានឡានមួយចូលទៅចាប់ ផាន មុនគេតែម្ដង នៅកន្លែងប-៣ ហ្នឹងបណ្ដោយ។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៥:២៧:២៤]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចប្រាប់ខ្ញុំបានទេ គឺថាក្រៅពីកម្មាភិបាលដែលយើងបានពិភាក្សាថាគេបានចាប់ខ្លួននៅក្នុងតំបន់ក្រចេះនៅក្នុងឆ្នាំ១៩៧៨ ក្រោយពីចាប់អស់ទៅ តើពួកខាងណាគឺមកជំនួសពួកគាត់នោះ?

**ឆ៖** ក្រោយពីចាប់គណៈតំបន់ គណៈស្រុកអីអស់ហ្នឹង នៅក្រចេះនេះគឺខ្ញុំគ្រាន់តែបានឮគេថា នៅខេត្តនេះមានឈ្មោះ មឿន, ឈ្មោះ មឿន មកធ្វើប្រធាន ហើយឈ្មោះ យុន មកទទួលខាងឃោធា ហើយម្នាក់ទៀតឈ្មោះ យ៉េង។ ហើយខ្ញុំអត់ដែលបានឃើញមុខពួកគេហ្នឹងទេ គ្រាន់តែដឹង ដឹងតែឈ្មោះ អ៊ីចឹង បីនាក់ហ្នឹង។ ហើយដល់ទៅសំបូរខ្ញុំ ឃើញ តាវឿន, តាឈូក ហ្នឹងគាត់ទៅ។ ឯស្រុកផ្សេងទៀត

ខ្ញុំអត់បានដឹងដែរ។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** លោកបានបញ្ជាក់ថា មានមនុស្សមួយចំនួនច្រើនដែលមកជំនួសកម្មាភិបាលដែលត្រូវបានគេចាប់ខ្លួន ហើយពួកនោះមកពីខាងយោធា។ ថាតើលោកអាចបញ្ជាក់បានទេថា ពួកគេនោះមកពីកងពលណានៃយោធា? ឬក៏លោកដឹងថាកម្មាភិបាលថ្មីនេះ មកពីកងពលណាមួយរបស់កងទ័ពបដិវត្តន៍កម្ពុជាដែរឬទេ?

[១៥:២៩:០៧]

**ឆ៖** ពាក់ព័ន្ធនឹងក្រុមយោធាដែលចុះមកខេត្ត-- មកតំបន់៥០៥នេះ ខ្ញុំក្តាប់អត់បានដែរ ខ្ញុំអត់ដឹងច្បាស់ថាតើពួកនេះមកពីភូមិភាគណា ឬក៏មកពីតំបន់ណា។ គ្រាន់តែដឹងថា ពួកហ្នឹងមកនិយាយសុទ្ធតែញោមៗ ប៉ុន្តែមិនដឹងមកពីខាងណា។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** ផ្អែកទៅលើភាសាដែលនិយាយរបស់គាត់នោះ តើលោកអាចសម្គាល់ថាពួកគាត់នោះមកពីតំបន់ ឬក៏ខេត្តណានៃប្រទេសកម្ពុជាដែរឬទេ សំឡេងដែលគេហៅថា "ញោម" ហ្នឹងបាទ?

**ឆ៖** ខ្ញុំក្តាប់អត់បានច្បាស់ដែរ មិនហ៊ានថា ខ្លាចខុស។ បាទ គ្រាន់ដឹងថា ច្រើនតែនិយាយញោម អ៊ីចឹង។ បាទ សូមអស់មតិ។

**ស៖** តើលោកយល់ឃើញថាយ៉ាងដូចម្តេចដែរ នៅពេលដែលមានកម្មាភិបាលជាច្រើននៅក្នុងតំបន់ក្រចេះត្រូវបានគេចាប់នៅក្នុងឆ្នាំ៧៨ហ្នឹង តើលោកយល់ឃើញយ៉ាងដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ! ការតាំងសំណួរឲ្យសាក្សីផ្តល់នូវសេចក្តីសន្និដ្ឋាន គឺមិនអនុញ្ញាតទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកមានដឹងអំពីការវាយប្រយុទ្ធដែលកើតឡើងរវាងវៀតណាម ជាមួយនឹងកម្លាំងយោធាកម្ពុជាប្រជាធិបតេយ្យនៅចុងឆ្នាំ៧៧ នៅក្នុងខេត្តក្រចេះដែរឬទេ?

[១៥:៣១:២១]

**លោក យុន គីម៖**

**ឆ៖** ខ្ញុំបានឮគេថាដែរ គឺពេលហ្នឹងគឺមានឮថាមានសង្គ្រាមរវាងកម្ពុជាជាមួយវៀតណាម បាទ។ កាលហ្នឹង គឺមានប្រមូលកងទ័ព ប្រមូលឈ្លបអីពីសហករណ៍អីទៅដែរ ហើយក្រោយមកថា សង្គ្រាម

ហ្នឹងចប់ទៅ ក៏កម្លាំងទាំងអស់ហ្នឹង ក៏អត់ទាន់រំសាយដែរ បាទ នៅខេត្ត-- នៅក្នុងស្រុកសំបូរខ្ញុំនេះ គេឲ្យនៅម្តុំសិន ទៅជួបធ្វើទំនប់ ធ្វើអីប្រជាពលរដ្ឋសិន។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** តើលោកដឹងថាមានបញ្ហាអ្វីកើតឡើងនៅក្នុងកម្លាំងទាហានតំបន់ នៅពេលវាយប្រយុទ្ធជាមួយនឹងវៀតណាមនៅចុងឆ្នាំ៧៧នោះដែរទេ?

**ឆ៖** ខ្ញុំក្លាប់មិនបានច្បាស់ដែរបញ្ហានេះ។ ខ្ញុំសូមអស់មតិ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ក្នុងពេលនេះ ខ្ញុំសូមបង្ហាញដល់សាក្សីនូវសេចក្តីដកស្រង់កាលពីខែប្រាំ ដល់ខែប្រាំមួយ ឆ្នាំ៧៨ គឺទស្សនាវដ្តីទង់បដិវត្ត។ ឯកសារ E3/727 ហើយដែលពីដើមគេហៅថា IS11.14 ហើយខ្ញុំសូមដកស្រង់ពីរចំណុចដែលខ្ញុំសូមដកស្រង់។ ទីមួយ គឺមានលេខ ERN 0064559, ភាសាអង់គ្លេស 00185326 ហើយនិងភាសាបារាំង គឺ 00524453 ហើយសេចក្តីដកស្រង់ ទីពីរ គឺឯកសារតែមួយ ដែលមានខ្មែរ ERN 0064577, ភាសាអង់គ្លេស គឺមានលេខ 00185341 និងភាសាបារាំង គឺមានលេខ 00524468 ហើយខ្ញុំមានឯកសារជាក្រដាស ដើម្បីជូនដល់សាក្សី ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ។

[១៥:៣៤:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** គឺមានឯកសារពីរផ្នែកដែលខ្ញុំចង់អានជូនលោក ហើយខ្ញុំនឹងសួរសំណួរបន្ទាប់មក។ ផ្នែកទីមួយ គឺភាសាខ្មែរទំព័រ 64559 ដែលជាផ្នែកនៃទស្សនាវដ្តីទង់បដិវត្ត ដែលនិយាយអំពីការក្បត់នៅក្នុងកងកម្លាំងទាហានកម្ពុជាប្រជាធិបតេយ្យ ដែលគេជឿជាក់ថា កើតឡើងនៅក្នុងការវាយប្រយុទ្ធជាមួយវៀតណាម។ ខ្ញុំសូមដកស្រង់ ហើយខ្ញុំសូមអានដូចតទៅនេះ “ក្នុងអង្គភាពយោធានៅបូព៌ា ក្នុងមួយវរសេនាធំ វាចាត់តាំងមួយវរសេនាតូចមកវាយយើងពីក្រោយខ្នង ហើយមួយស្រុកៗវាចាត់តាំងមួយអនុសេនាធំវាយយើងពីខាងក្រោយខ្នងទៀត។ ខាងក្រចេះក៏ដូច្នេះដែរ”។ ហើយនៅក្នុងផ្នែកតែមួយនៃទស្សនាវដ្តីទង់បដិវត្តនេះ ប្រសិនបើយើងមើលទៅលើទំព័រ 64557 គឺទស្សនាវដ្តីទង់បដិវត្តមានចែង

មានរៀបរាប់ដូចតទៅ គឺនៅទំព័រ 64577 នៃទស្សនាវដ្ដីទង់បដិវត្តដែលមានរៀបរាប់ដូចតទៅ "យើងបានកម្ទេចពួកក្បត់ដែលៗដឹកនាំនៅៗៗទូទាំងប្រទេស ដែលដឹកនាំក្បាលម៉ាស៊ីននៅទូទាំងប្រទេស--"។

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឱ្យខាងសហព្រះរាជអាជ្ញាគាត់អានឱ្យបានយឺតបន្តិច លោកប្រធាន។

[១៥:៣៦:៥៤]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអានឯកសារឡើងវិញ! ញាប់ពេក អត់មានការបកប្រែទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សេចក្ដីដកស្រង់ទីពីរគឺទស្សនាវដ្ដីទង់បដិវត្ត ខ្ញុំសូមអានដូចតទៅនេះ "យើងបានកម្ទេចនូវជនក្បត់ដែលជាក្បាលម៉ាស៊ីននៅទូទាំងប្រទេស រួមជាមួយនឹងបក្សពួករបស់ពួកគេ។ ជាៗរួមពួកកម្លាំងក្បត់គឺនៅខាងបូព៌ា និងខាងៗបស្ចិម ហើយនៅភ្នំពេញគឺនៅក្រចេះផងដែរ គឺតំបន់២៥"។ សំណួរដែលខ្ញុំចង់សួរលោកគឺថាតើលោកចាំដែរឬទេ ថាបានឮនៅពេលណាមួយដែលថាមានក្បាលម៉ាស៊ីនដឹកនាំក្បត់ត្រូវបានកម្ទេច គឺនៅក្នុងខេត្តក្រចេះចុង-- នៅដើមឆ្នាំ១៩៧៨? ដោយសារតែមានការកើតឡើងនូវជម្លោះប្រដាប់អាវុធជាមួយនឹងប្រទេសវៀតណាម ហើយមេដឹកនាំបក្សបានសម្រេចថាមានកម្លាំងក្បត់នៅក្នុងភូមិភាគដែលទាក់ទងជាមួយវៀតណាម។ តើលោកធ្លាប់ឮអំពីបញ្ហានេះពីអ្នកណាម្នាក់និយាយប្រាប់លោកដែរឬទេ?

[១៥:៣៨:២៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់មេធាវីការពារក្ដីសិន។ សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្ដម៖**

សូមអរគុណលោកប្រធាន។ ព្រះរាជអាជ្ញាទើបបានប្រគល់ឯកសារទៅឱ្យសាក្សី។ សូមលោកប្រធានមេត្ដាអនុវត្តបញ្ញត្តិពីមុនដែលថា សាក្សីបានអាន បានដឹងឮឯកសារនេះពីមុនមកឬអត់? បើសិនមាន ឬគ្មានសូមអនុវត្តបញ្ញត្តិដែលមានរួចហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងបញ្ហានេះ។ នេះមិនមែនបរិបទដែលដូចករណីដែលយើងបានលើកឡើងពីមុនៗទេ។ នេះជាការដកស្រង់នូវខ្លឹមសារព័ត៌មានមួយចំនួនដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងតំបន់ក្រចេះ ពាក់ព័ន្ធទៅនឹងបញ្ហាជម្លោះប្រដាប់អាវុធដែលកើតមានឡើងរវាងភាគីកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។

[១៥:៣៩:៤០]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាខាងលើនេះ គឺទំនាស់រវាងប្រដាប់អាវុធនៅក្នុងតំបន់៥០៥ នេះ ដោយស្រុកសំបូរខ្ញុំ វានៅអត់ជិតកន្លែងប្រយុទ្ធ នៅដាច់ពីខេត្តទៅទៀត ហួសខេត្តទៅទៀតបានទៅដល់កន្លែងខ្ញុំ។ អ៊ីចឹងខ្ញុំអត់បានក្តាប់អីបានទាំងអស់។ ខ្ញុំការយល់ដឹងពីបញ្ហាទំនាស់គ្នានេះ ខ្ញុំមិនបានដឹងច្បាស់លាស់ទេបាទ។ សូមអស់មតិប៉ុណ្ណឹង។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងបញ្ហាមួយនេះ មុននឹងខ្ញុំពិភាក្សាពីបញ្ហាមួយផ្សេងទៀតហ្នឹង គឺថាតើលោកធ្លាប់ឮអំពីកម្មាភិបាល ឬក៏អ្នកដឹកនាំថ្មីដែលមកជំនួសកម្មាភិបាលតំបន់ ឬក៏កម្មាភិបាលស្រុក។ តើកម្មាភិបាលថ្មីហ្នឹងធ្លាប់និយាយប្រាប់ថា ហេតុអ្វីទើបមេដឹកនាំចាស់ ឬក៏អ្នកដឹកនាំចាស់ហ្នឹងត្រូវបានគេចាប់ខ្លួនដែរឬទេ?

**ឆ៖** ជារឿងធម្មតានៅក្នុងរបបខ្មែរក្រហមទៅហើយ ឲ្យតែមានការចាប់គ្នាទៅ អ្នកថ្មីមកតែងតែថាអ្នកចាស់នោះក្បត់។ បាទ ដល់បន្តិចទៅ ចាប់អ្នកហ្នឹងទៅទៀត អ្នកមកមួយទៀតថាអ្នកនោះក្បត់ទៀត។ អ៊ីចឹងតែងតែឮតែអ៊ីចឹង បាទ ខ្ញុំសូមអស់មតិ។

[១៥:៤១:២០]

**ស៖** លោកស្គាល់មនុស្សជាច្រើនដែលគេចាប់ខ្លួន តើលោកជឿជាក់ថា ពួកគាត់ហ្នឹងគឺជាជនក្បត់មែនឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំយល់ថាមិនមែនសុទ្ធតែអ្នកក្បត់ទាំងអស់នោះទេ ពីព្រោះធ្លាប់រួមរស់នៅជាមួយ ពិសេសដូចជាលោក ផាន អីអ៊ីចឹង លោក នី។ បាទ បើខ្ញុំពិនិត្យ គឺល្អមែនទែន ពិសេសលោក ផាន ហ្នឹងជាគំរូមួយនៅក្នុងស្រុកហ្នឹង ពលកម្មក៏ដោយ ស្មីក៏ដោយ គាត់ដើរតួ ហើយសុភាពរាបសាល្អណាស់។ បាទ អ៊ីចឹងគឺបានន័យថា មិនមែនសុទ្ធតែក្បត់ទាំងអស់ទេ។ ការចោទគ្នាថាក្បត់នេះ

ខ្ញុំមិនដឹងជា ចំពោះខ្ញុំរកៗពិបាកណាស់ ពីព្រោះម្នាក់ៗនៅសម័យនោះព្រួយបារម្ភដែលខ្លាចថា គ្រោះថ្នាក់ដល់ខ្លួនដែរ ដូចខ្ញុំ ក៏មានការបារម្ភដែរ ចេះតែប្រយ័ត្នប្រយែងអ៊ីចឹង។ ប៉ុន្តែមិនជឿថា ចេះតែ នេះក្បត់ នោះក្បត់តែទាំងអស់គ្នានោះទេបាទ។ អាចមានការភ័ន្តច្រឡំលើបញ្ហាហ្នឹងខ្លះ។ ខ្ញុំសូមអស់មតិ។

[១៥:៤២:៤៨]

**សៈ** ឥឡូវនេះ ខ្ញុំចង់និយាយអំពីរយៈពេលដែលលោកនៅ ប-៣ គឺនៅការដ្ឋាន ប-៣ ដែលលោកបាននិយាយថា គេបញ្ជូនទៅធ្វើជាប្រធានក្រុមនៅ ប-៣ ខែមិថុនា ឆ្នាំ៧៨ ហើយលោកក៏បានជម្រាបយើងផងដែរថា នៅការដ្ឋាន ប-៣ ពីមុន គឺគេប្រើប្រាស់ដើម្បីឃុំខ្លួនអ្នកទោសជាកម្មាភិបាល។ សំណួរសួរថា តើលោកដឹងថា ប-៣ ត្រូវបានគេប្រើប្រាស់ជាកន្លែងឃុំខ្លួនអ្នកទោសជាកម្មាភិបាលហ្នឹងដោយរបៀបណា?

**ឆៈ** ពាក់ព័ន្ធនឹងបញ្ហា ប-៣ នេះខ្ញុំក្តាប់មិនបានច្បាស់ដែរ ប៉ុន្តែគ្រាន់តែដឹងថា គេថាកម្មាភិបាលដែលក្បត់ៗ គេប្រមូលយកទៅដាក់នៅ ប-៣ បាទនៅ ប-៣។ ប៉ុន្តែយកទៅដាក់នោះ មិនដឹងជាផែនការគេឲ្យអ្នកទាំងអស់នោះធ្វើស្អីក៏មិនដឹង ពីព្រោះក្នុងរយៈពេលទៅនៅនោះ ក៏ខ្ញុំអត់ដឹងពីថ្ងៃណាដែរ។ ហើយខ្ញុំហ្នឹងក៏អត់ដឹងថាមាន ប-៣ ហ្នឹងផង។ ស្រាប់តែពេលគេថា ឲ្យខ្ញុំហ្នឹងទៅប្រធាន ប-៣ ហ្នឹង បានខ្ញុំដឹងថា អ៊ូ! មាន ប-៣ អីពីអង្កាល់ណា។ គេថា អ្អេ គេប្រមូលពួកកម្មាភិបាលតាមមូលដ្ឋាន តាមឃុំតាមស្រុកមួយចំនួនយកទៅដាក់នៅនុ៎ង ដោយឲ្យ ផាន ហ្នឹងធ្វើជាប្រធាននៅកន្លែង ប-៣ ហ្នឹង។ អ៊ីចឹងបានន័យថា ខ្ញុំអត់បានច្បាស់លាស់ពីបញ្ហា ប-៣ នេះមុនដែលខ្ញុំទៅនៅទេ។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៥:៤៤:៣៤]

**សៈ** លោកក៏បានជម្រាបយើងផងដែរថា នៅពេលដែលគេស្នើឲ្យលោកទទួលខុសត្រូវនៅ ប-៣ គឺលោក គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហាន។ ខ្ញុំចង់សួរលោកថា តើប-៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហានទាំងស្រុង ទាំងពេលជាការគ្រប់គ្រងរបស់លោក ក៏ដូចជាពេលនៅ-- ជាការឃុំខ្លួនកម្មាភិបាល តើមែនឬទេ?

**ឆៈ** កន្លែង ប-៣ នេះកាលពីនៅកម្មាភិបាលដែលគេកំណត់ថា ជាអ្នកទោសយកទៅដាក់នោះ គឺការគ្រប់គ្រងផ្សេង។ អាហ្នឹងគេកំណត់ថា ជាទីតាំងអ្នកទោស។ ដល់ពេលគេដកអស់គេយកយុវជនយុវនារីទៅដាក់ គេឲ្យទាហានម្នាក់ធ្វើជាមេនៅហ្នឹងឈ្មោះ សារិន ហ្នឹងធ្វើមេ។ ហើយដល់ សារិន ហ្នឹង

វាគ្មានលទ្ធភាពក្នុងការដឹកនាំយុវជន យុវនារី ហ្នឹង ពីព្រោះតាំងពីអាកប្បកិរិយា ពាក្យសម្ដីជាទាហានទាំងអស់ធ្វើឱ្យមានការអត់-- នៅកន្លែងនុ៎ងធ្វើការងារវាអត់ទៅមុខ ដល់អ៊ីចឹងបានគេដកខ្ញុំពី សហករណ៍មកឱ្យជំនួស សារិន ហ្នឹង។ បាទ ហើយ សារិន ហ្នឹងពេលខ្ញុំមកដល់កន្លែងការដ្ឋានហ្នឹងក៏អត់ឃើញ សារិន ហ្នឹង។ មិនដឹង សារិន ហ្នឹងមុខអាម៉េចផង គ្រាន់តែគេប្រាប់ថា សារិន ទាហាននៅគ្រប់គ្រងមុនខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង។ បាទ សូមអរសមតិ។

[១៥:៤៦:១៤]

**ស៖** នៅពេលដែលលោកមកដល់ ប-៣ តើលោកអាច ៗ ពណ៌នាបានដែរឬទេ អំពី ប-៣ ហ្នឹង តើប-៣ ហ្នឹងជាការដ្ឋានដែលមានទំហំធំ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបអំពីបញ្ហា ប-៣ នៅពេលដែលខ្ញុំមកដល់កន្លែង ប-៣ ហ្នឹងគឺមានដីដែលគេស្ដាយហើយជាស្រែនោះបួនហិកតា ហើយគេដាក់ផែនការឱ្យខ្ញុំហ្នឹងរើរានឱ្យបាន ១០០ហិកតានៅថ្ងៃ១១ ខែ៦ ៧៨។ ខ្ញុំចូលមកថ្ងៃ១១ ខែ៦ ៧៨ គេប្រាប់ថា ឱ្យរានដី ១០០ហិកតា បាទ។ ហើយដល់មកដល់ហ្នឹងឧបករណ៍អត់មានទេ មានតែកាំបិតដប់ ដងពូថៅដប់ អ៊ីចឹងខ្ញុំគិតថា វាអាចគ្រោះថ្នាក់ដល់ខ្លួនហើយ ១០០ហិកតា រួចនៅសហករណ៍គេចាប់ស្នូងខ្លះ រួចយើងមិនទាន់នឹងរានដីផង។ អ៊ីចឹងខ្ញុំបានទៅសុំគេវិញ សូមឱ្យគេឱ្យជាងដែក គេឱ្យជាងដែកមកខ្ញុំហ្នឹងបីនាក់ យកមកវ៉ៃដែក វ៉ៃពូថៅវ៉ៃកាំបិតបាទ។

[១៥:៤៧:២៣]

វាទាន់ដែរ ប្រហែលជា១០ថ្ងៃ ខ្ញុំមានកាំបិត ពូថៅប្រើ ហើយក្រៅពីហ្នឹងទៀត ខ្ញុំសុំដំរីគេបាទ។ គេសួរថា សុំប៉ុន្មាន? ខ្ញុំថា បើបាន ៣០ក៏យក ៤០ក៏យក ឱ្យតែបានដំរីច្រើន ដល់រួចទៅគេរកឱ្យខ្ញុំបាន ១២ក្បាល តាមរយៈដំរីហ្នឹង ខ្ញុំរានស្រែបានជាង ៤០ហិកតាបាទ។ ហើយខ្ញុំធ្វើស្រូវឆ្នាំនោះបាន ៦០០ថាំង។ អ៊ីចឹងបានថា ខ្ញុំឱ្យបងប្អូនយើងគាស់បន្តិចៗទៅដំរីមករុញ រុញឈើនុ៎ងផ្ដួលហើយ កាប់ឈើជាពីរដំរីអូសឡើងទួលបាទ។ អនុវត្តរបៀបហ្នឹង បើមិនធ្វើអ៊ីចឹងទេ មិនបានប្រាំហិកតាផង បើគ្មានគំនិតធ្វើអាតាមជាមួយដំរីទេ។ អ៊ីចឹងបានថា ក្នុងការអនុវត្តនៅស្រែងរុង នេះខាងស្រុកគេគ្រប់គ្រងនេះ គ្រាន់តែថា បើយើងខ្វះស្អី យើងទំនាក់ទំនងជាមួយគេទេ។ ឯការជាក់ស្ដែងនៅលើពួកខ្ញុំអ្នកធ្វើនៅឯនោះ។ ហើយដោយឆ្នាំ៧៨ ហ្នឹងទឹកវាធំ គេប្រមូល សូមយុវជន យុវនារីអស់ៗ ច្រើនពីកន្លែង នៅសល់តែអ្នកឈឺអ្នកថ្កាត់ហ្នឹងប្រហែលជា ១០០នាក់ បាទ។ អ៊ីចឹងយើងរានដីបានប៉ុណ្ណឹង ខ្ញុំមិនតវ៉ាដែរ ខ្ញុំថា បើសិន

ណា ជាដកកម្លាំងអស់អ៊ីចឹង ខ្ញុំមិនអាចវានដីបានតាមផែនការទេ។

[១៥:៤៨:៤១]

បានគេថា ឥឡូវកម្លាំងគេសុំប៉ុន្មានឱ្យមក អត់អីទេ អត់មានបញ្ហាអីទេ ពីព្រោះដាក់ស្តែងអ៊ីចឹង។ ព្រោះសហករណ៍គ្នាត្រូវការកម្លាំង ព្រោះកម្លាំងយុវជន-នារី ប្រមូលពីសហករណ៍អស់ហើយ។ នេះខ្ញុំសូមអស់មតិ។ សូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** ឥឡូវនេះ សហការីខ្ញុំគាត់បាននិយាយ-- បានសួរលោកពីព្រឹករួចមកហើយ ហើយលោកបានផ្តល់សក្ខីកម្មរួចមកហើយអំពីក្រុមយុវជន ប្រហែលជា ២០០នាក់ ត្រូវបានគេបញ្ជូនចេញពី ត្រមូងទៅមន្ទីរ ប-៣ ហើយបន្ទាប់មកយកពួកគាត់ចេញពី ប-៣ ទៅទៀត។ អ្វីដែលខ្ញុំចង់សួរលោកគឺថា តើយុវជនដែលមកពីឃុំត្រមួន ហ្នឹងតើត្រមួនហ្នឹង នៅកន្លែងណា? នៅក្នុងស្រុកអី? នៅក្នុងតំបន់អ្វីដែរ?

[១៥:៤៩:៤៨]

**ផ៖** ពាក់ព័ន្ធនឹងឃុំត្រមូង នេះ។ ឃុំត្រមូង ទន្លូង នេះនៅក្នុងស្រុកមេមត់ ខេត្តកំពង់ចាម នៅជិតព្រំដែនវៀតណាម។ ខ្ញុំអត់ស្គាល់ទេ ប៉ុន្តែដល់ពេលខ្ញុំជិះឡានកាត់តាមនុ៎ងឃើញគេដាក់ឃុំត្រមូង។ បាទ អ៊ីចឹងបានដឹងថា ឃុំត្រមូង នៅត្រង់ហ្នឹង។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** តើត្រមូងហ្នឹង គឺជាផ្នែកនៃភូមិភាគបូព៌ាមែនទេ?

**ផ៖** បាទ ត្រមូងហ្នឹងគឺនៅក្នុងភូមិភាគបូព៌ាបាទ។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ នៅពេលដែលយុវជនមួយក្រុមធំត្រូវបានគេបញ្ជូនទៅ ប-៣ បញ្ជូនពីបូព៌ាមក ប-៣ តើលោកអាចប្រាប់បានដែរទេ ថាមានហេតុផលអ្វីបានគេបញ្ជូនយុវជនហ្នឹងមក ប-៣?

[១៥:៥១:០២]

**ផ៖** ពាក់ព័ន្ធនឹងការបញ្ជូនយុវជនយុវនារី ភាគច្រើនយុវនារីមកពីត្រមូងមក ប-៣ នេះ បើខ្ញុំអត់ដឹងច្បាស់អំពីមូលហេតុទេ ប៉ុន្តែគ្រាន់តែឃើញថាពួកអ្នកមកហ្នឹងមានសភាពស្គាំងស្គមបាទ។ ស្គាំងស្គមខ្វះជីវភាព យ៉ាប់យ៉ឺនខ្លាំងមែនទែន ហើយពេលនោះក៏ឪពុកម្តាយយុវជនយុវនារីហ្នឹងភាគច្រើនមកនៅស្រុកសំបូរដែរបញ្ជូនមកស្រុកសំបូរ។ ដំបូងបញ្ជូនម៉ែឪមកទេ ដល់ក្រោយមកឃើញយុវជនយុវនារីហ្នឹងមកជាមួយដែរ។ មកគេបញ្ជូនទៅនៅជាមួយខាងខ្ញុំហ្នឹងបាទ ខ្ញុំអត់ដឹងថាយ៉ាងម៉េច ស្រាប់តែមកដល់គេថា អ៊ូ សូមឱ្យយុវជនយុវនារីនៅខាងត្រមូង ខាងភូមិភាគបូព៌ាហ្នឹងមកនៅការដ្ឋានជាមួយ

ការដ្ឋានខ្ញុំនេះ។ ហើយដល់ក្រោយមក គេថាឲ្យសូមយកយុវជននារីហ្នឹង គេសុំយកទៅវិញ ទៅបាត់អស់ទៅមិនដឹងទៅខាងណា។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** លោកបានបញ្ជាក់នៅក្នុងកិច្ចសម្ភាសជាមួយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំជឿជាក់ថា នឹងមានការចោទប្រកាន់ថា ជន-- យុវជនយុវនារីទាំងអស់នោះមានទំនាក់ទំនងជាមួយវៀតណាម។ តើអ្នកណាជាអ្នកប្រាប់លោកថា យុវជនយុវនារីនុ៎ង គឺមានទាក់ទងមានជាប់ខ្សែស្រឡាយជាមួយវៀតណាម?

**ឆ៖** ហ្នឹង ថាទាក់ទងហ្នឹងគឺមានតែខាងស្រុកគេឲ្យមកហ្នឹង គេថាពួកហ្នឹងវានៅជិតវៀតណាម ហើយវាមានទំនាក់ទំនងជាមួយវៀតណាម។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៥:៥២:៥៨]

**ស៖** តើយុវជនយុវនារីទាំងអស់នោះនៅ ប-៣ រយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ មុននឹងគេបញ្ជូនចេញទៅទៀត?

**ឆ៖** ពួកយុវជនយុវនារីដែលមកនៅ ប-៣ ហ្នឹង មិនលើសពីបីខែទេមកនៅ។ ពីព្រោះប្រហែលជាខែ៨ៗមកនៅ ខែ៩ ខែ១០ហ្នឹងចេញទៅវិញបាត់អស់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំមានសំណួរមួយទៀត ដែលខ្ញុំចង់ចោទសួរលោក។ សំណួរនេះគឺពាក់ព័ន្ធទៅនឹងឯកសារ ស-២១ មួយទៀត ដែលជាកំណត់ត្រាអ្នកទោសចំនួន ២២នាក់មកពីតំបន់៥០៥ ដែលភាគច្រើនគឺជាប្រធានសហករណ៍ឃុំ ហើយគឺបញ្ជូនមក ស-២១ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ៧៨ គឺប្រហែលជាមួយអាទិត្យមុនពេលរបបខ្មែរក្រហមដួល។

**លោក ខេល លីសាក់៖**

ហើយលោកប្រធានឯកសារនេះគឺមានលេខ D108/26.280 ហើយទំព័រដែលមានបញ្ជីនេះគឺៗមានអ្នកទោស ២២មកពីតំបន់៥០៥។ ខ្មែរមានលេខ 00086833 រហូតដល់ 834 ហើយភាសាអង់គ្លេសគឺមាន 00795508 ដល់ 510។ ខ្ញុំចង់ប្រគល់ឯកសារនេះ ជូនទៅដល់សាក្សី ហើយខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅអេក្រង់។ ហើយខ្ញុំចង់ឲ្យសាក្សីគាត់ពិនិត្យមើលទៅលើបញ្ជីឈ្មោះនៃបញ្ជីនេះ ហើយដើម្បីប្រាប់ថា តើសាក្សីគាត់ស្គាល់ជនអ្នកជាប់ទោសអស់នេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាស ពីតំណាងសហព្រះរាជ

អាជ្ញា យកជូនសាក្សីពិនិត្យ!

[១៥:៥៦:១៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យុន គីម អ្វីដែលខ្ញុំចង់នេះ គឺថាខ្ញុំសូមចាប់ផ្តើម ហើយខ្ញុំសូមឲ្យលោកអានបញ្ជីឈ្មោះទាំង២២រូប មកពីតំបន់៥០៥នោះ ហើយបន្ទាប់មកលោកជម្រាបមកយើង ថាតើលោកស្គាល់ឈ្មោះណាខ្លះនៅក្នុងបញ្ជីនេះ?

*(សាក្សីពិនិត្យមើលឯកសារ)*

**លោក យុន គីម៖**

**ឆ៖** ជម្រាបថាក្នុងចំណោមទាំងអស់នេះខ្ញុំស្គាល់តែ សម្បត្តិ មួយ នៅឃុំសំបុក។ បាទ ខ្ញុំស្គាល់តែម្នាក់ហ្នឹងទេ។

**ស៖** តើលោកធ្លាប់ចាំថាបានឮដែរឬទេ នៅចុងឆ្នាំ៧៨ ដែលប្រធានឃុំ ឬក៏ប្រធានសហករណ៍នោះត្រូវបានគេចាប់ខ្លួន? តើលោកចាំថាធ្លាប់ឮអំពីបញ្ហានេះដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់ឮដែរ នៅពេលដែលគេចាប់គណៈតំបន់ ឃើញថាគេចាប់ហូរហែតគ្នា។ នៅខាងឃុំថ្មគ្រែហ្នឹងក៏ចាប់ ឃុំសំបុកហ្នឹងក៏ចាប់ ហើយឃុំផ្សេងៗទៀត ឃើញតែចាប់ជាបន្តបន្ទាប់ដែរ។ ឯនៅខាងសំបូរខ្ញុំក្រោយពីសភាពការណ៍ហ្នឹងដូចជាមិនសូវមានបញ្ហាប៉ុន្មាននោះទេ។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៥:៥៩:០៤]

**ស៖** នៅក្នុងឯកសារដដែលនេះ គឺនៅទំព័របន្ទាប់ សូមលោកពិនិត្យទៅលើ 00086832, ភាសាអង់គ្លេស គឺ789507 គឺជាបញ្ជីស-២១ ដែលបានបញ្ជាក់អំពីមនុស្សចំនួនពីររូប គឺ ហួន យ៉េង ដែលជាលេខាស្រុកក្រចេះ គឺចូលនៅថ្ងៃ១២ ខែធ្នូ ឆ្នាំ៧៨ ហើយនិងបុគ្គលម្នាក់ទៀតឈ្មោះ ឈុំ ចិន ហៅ ភ័ន ជាលេខាស្រុកស្នួល ដែលចូលមន្ទីរស-២១ នៅថ្ងៃជាមួយគ្នា គឺថ្ងៃ១២ ធ្នូ ឆ្នាំ៧៨។ តើលោកស្គាល់បុគ្គលទាំងពីររូបនេះទេ?

**ឆ៖** បុគ្គលទាំងពីររូបនេះ ខ្ញុំអត់បានស្គាល់ទេ ប៉ុន្តែគ្រាន់តែឈ្មោះ យ៉េង ខ្ញុំធ្លាប់ឮឈ្មោះបាទ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោក យុន គីម ខ្ញុំមិនមានសំណួរបន្តទៅទៀតទេ។ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាក្សីដែលបានអញ្ជើញមកផ្តល់ចម្លើយនៅថ្ងៃនេះ។ លោកប្រធាន លោក លោកស្រីចៅក្រម

ខ្ញុំមិនមានសំណួរអ្វីបន្តទៅទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំះ**

បាទ អរគុណ។ អរគុណសាក្សី។ លោក យុន គីម ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ថ្ងៃពុធ ទី២០ ខែមិថុនា ឆ្នាំ២០១២ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយដូចគ្នានេះដែរ មេធាវីប្រឹក្សាសាក្សី សូមអញ្ជើញចូលរួមសវនាការដើម្បីបន្តប្រឹក្សាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃស្អែក និងថ្ងៃបន្តបន្ទាប់។

[១៦:០១:១៨]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការបញ្ជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺដល់ទី-- ពេលល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២០ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃស្អែកនេះ ដែលនឹងបន្តធ្វើការតាំងសំណួរដេញដោលដោយ ចំពោះសាក្សី យុន គីម ដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងអាចបន្តដោយក្រុមមេធាវីការពារក្តី។ ហើយសូមភាគី និងសាធារណជនជ្រាប។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ទាំងបីនាក់ មកកាន់បន្ទប់សវនាការវិញនេះ-- វិញ នៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី ក្នុងករណីដែលគាត់បានបង្ហាញជំហរច្បាស់លាស់ដូចសព្វដង គឺគាត់បង្ហាញជំហរក្នុងការលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ តាមរយៈដាក់ពាក្យសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់លាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះបានមុនពេល អង្គជំនុំជម្រះចាប់ផ្តើមដំណើរការសវនាការនោះ។

[១៦:០២:៤៩]

អង្គជំនុំជម្រះឲ្យអនុរក្សមន្ទីរឃុំឃាំងទំនាក់ទំនងជាមួយនឹងក្រឡាបញ្ជីសវនាការ ហើយនិងឲ្យនាំលោក អៀង សារី មកត្រឹមតែបន្ទប់ឃុំខ្លួនមួយ ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់

តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយចំណែកឯការសម្រេចលើសំណើសុំ អង្គជំនុំជម្រះនឹងពិនិត្យសម្រេចលើបញ្ហានេះជាមុន មុនពេលដំណើរការសួរដេញដោលសាក្សី។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី)*